ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

* * *

ឆ្នាំទី ៣ លេខ ៣២ ថ្ងៃទី ០៨ ខែ កញ្ញា ឆ្នាំ ១៩៩៥

រាជកិច្ច

រួមមាន :

- ច្បាប់
- ក្រម-ក្រឹត្យ
- អនុក្រឹត្យ
- ប្រកាស
- សេចក្តីសំរេច
- សារាចរ

ផ្សាយចេញពីទីស្តីការគណៈរដ្ឋមន្ត្រីរៀងរាល់សប្តាហ៍

ក

មាតិកា

I - ខុទ្ទកាល័យព្រះមហាក្សត្រ

១ - ព្រះរាជក្រម

០១–៩–៩៥ ព្រះរាជក្រម លេខ នស/រកម/០៨៩៥/០៧ ច្បាប់ស្តីពីរបបសារពត៌មាន ១៦២១

២ - ព្រះរាជក្រឹត្យ

០៧–៩–៩៥ ព្រះរាជក្រឹត្យលេខ នស/រកត/០៩៩៥/៦៤ ១៦៣៤

០៧–៩–៩៥ ព្រះរាជក្រឹត្យលេខ នស/រកត/០៩៩៥/៦៥ ១៦៣៥

០៨–៩–៩៥ ព្រះរាជក្រឹត្យលេខ នស/រកត/០៩៩៥/៦៦ ១៦៤១

០៨–៩–៩៥ ព្រះរាជក្រឹត្យលេខ នស/រកត/០៩៩៥/៦៧ ១៦៤៣

០៨–៩–៩៥ ព្រះរាជក្រឹត្យលេខ នស/រកត/០៩៩៥/៦៨ ១៦៤៧

II - ទីស្តីការគណៈរដ្ឋមន្ត្រី

១ - អនុក្រឹត្យ

០១–៩–៩៥ អនុក្រឹត្យលេខ ១០២ អនក្រ.តត ស្តីពីការលុបឈ្មោះចេញពីក្របខ័ណ្ឌរដ្ឋបាល ១៦៤៨

០៦–៩–៩៥ អនុក្រឹត្យលេខ ១០៣ អនក្រ ស្តីពីការបំពាក់ឋានន្តរសក្តិជូននាយនគរបាលជាតិ ១៦៤៩

០៦–៩–៩៥ អនុក្រឹត្យលេខ ១០៤ អនក្រ ស្តីពីការបំពាក់ឋានន្តរសក្តិជូននាយនគរបាលជាតិ ១៦៥២

២ - សេចក្តីសំរេច

០២–៩–៩៥ សេចក្តីសំរេចលេខ ៦២ សសរ ស្តីពីការប្រគល់ភារកិច្ចបណ្តោះអាសន្ន ១៦៥៤

០៤–៩–៩៥ សេចក្តីសំរេចលេខ ៦៣ សសរ ស្តីពីការបង្កើតគណៈកម្មាធិការពិនិត្យវាយតម្លៃគីតសញ្ញាបត្រនិងលិខិតបញ្ជាក់ការសិក្សា ១៦៥៥

០៦–៩–៩៥ សេចក្តីសំរេចលេខ ៦៤ សសរ ស្តីពីការផ្ទេរសិទ្ធិ ១៦៥៧

III - ការងារបណ្តាក្រសួង

១ - ទីស្តីការរដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

ប្រកាស

០២–៩–៩៥	ប្រកាសលេខ ៣១៥ ប្រក. សហវ. ខ ស្តីពីការបង្កើតគណៈកម្មការរៀបចំកសាងសេចក្តីព្រាងច្បាប់ ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ ១៩៩៦	១៦៥៨
០២–៩–៩៥	ប្រកាសលេខ ៣១៦ ប្រក. សហវ. ពឥ ស្តីពីការតែងតាំងសមាសភាពគណៈកម្មការវាយតម្លៃដីមិនបានប្រើប្រាស់	១៦៦១
០៦–៩–៩៥	ប្រកាសលេខ ១២១ សហវ. ប្រក. ប ស្តីពីការបញ្ជូនលោក ហ៊ឹង ភិរម្យ អោយទៅក្រសួងដើមវិញ	១៦៦៣
០៦–៩–៩៥	សេចក្តីសំរេចលេខ ១២៣ សហវ. លបក. ប ស្តីពីការចាត់តាំងភារកិច្ចមន្ត្រីរាជការចូលរួមក្នុងសមាសភាពការងារ នៃគណៈកម្មការត្រួតពិនិត្យគោលនយោបាយចំពោះជនពលី ពិការ	១៦៦៥
០៨–៩–៩៥	ប្រកាសលេខ ៣២០ ប្រក. សហវ. ថ ស្តីពីការបង្វែរឥណទាន	១៦៦៧
០៨–៩–៩៥	ប្រកាសលេខ ៣២១ ប្រក. សហវ. គរ ស្តីពីការអនុវត្តន៍សេវាអធិការកិច្ចទំនិញមុនពេលផ្ទុកសំរាប់នាំចូលមកក្នុងព្រះរាជាណាចក្រកម្ពុជា	១៦៦៩

២ - ទីស្តីការរដ្ឋមន្ត្រី ក្រសួងពាណិជ្ជកម្ម

ប្រកាស

០២–៩–៩៥	ប្រកាសលេខ ៣៨១ ពណ. ពកប. ប្រក ស្តីពីការបង្កើតគណៈកម្មការរៀបចំការបោះឆ្នោតជ្រើសរើសសមាជិកជ្រើសតាំងសភាពាណិជ្ជកម្ម	១៦៨៧

៣ - ទីស្តីការរដ្ឋមន្ត្រី ក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ

ប្រកាស

០៤–៩–៩៥	ប្រកាស លេខ ០៣៣ កបទ. សអ ស្តីពីការបង្កើតគណៈកម្មការមួយនៅក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ	១៦៨៩

៤ - ទីស្តីការរដ្ឋមន្ត្រី ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

សេចក្តីសំរេច

០៧-៩-៩៥	សេចក្តីសំរេច លេខ ៥៦៧ សសរ.កសក ស្តីពីការបង្កើតគណៈកម្មការ រៀបចំគំរោងអនុវត្តប្រើប្រាស់ថវិកា ដែលជាឥណទានរបស់ធនាគារ ពិភពលោក	១៦៩១

៥ - ទីស្តីការរដ្ឋមន្ត្រី ក្រសួងពត៌មាន

ប្រកាស

០១-៩-៩៥	ប្រកាស លេខ ២១៤/៩៥ ពម.ប្រកស្ថន ស្តីពីការបិទកាសែត « អ្នកជាតិនិយម »	១៦៩៣
០៦-៩-៩៥	ប្រកាស លេខ ២១៥/៩៥ ពម.ប្រកស្ថន ស្តីពីការបិទកាសែត « សង្គមយើង »	១៦៩៤
០២-៩-៩៥	ប្រកាស លេខ ២១៦/៩៥ ពម.ប្រក ស្តីពីការអនុញ្ញាតអោយកាសែត « ថ្ងៃនេះ » បោះពុម្ពផ្សាយ	១៦៩៥
០៤-៩-៩៥	ប្រកាស លេខ ២១៧/៩៥ ពម.ប្រកស្ថន ស្តីពីការបិទកាសែត « អ្នកប្រជាធិបតេយ្យ »	១៦៩៦
០៦-៩-៩៥	ប្រកាស លេខ ២១៨/៩៥ ពម.ប្រក ស្តីពីការយល់ព្រមអោយមន្ត្រីរាជការតាំងស៊ុបក្នុងក្របខ័ណ្ឌក្រសួង	១៦៩៧
០៦-៩-៩៥	ប្រកាស លេខ ២២៣/៩៥ ពម ស្តីពីការអនុញ្ញាតអោយសារពត៌មាន « ភ្នំពេញពិភពលោក » ដំណើរការបោះពុម្ពផ្សាយ	១៦៩៨

៦ - ទីស្តីការរដ្ឋមន្ត្រី ក្រសួងសាធារណការ និង ដឹកជញ្ជូន

ប្រកាស

០៧-៩-៩៥	ប្រកាស លេខ ៦២៩ ប្រក.សក.ខ ស្តីពីការបដិសេធប្រកាសលេខ ៦១៥ ប្រក សក.ហវ ចុះថ្ងៃទី ២៦ - ៨ - ១៩៩៥	១៧០០

៧ - ទីស្តីការរដ្ឋមន្ត្រី ក្រសួងអប់រំ យុវជន និង កីឡា

ប្រកាស

០១–៩–៩៥	ប្រកាស លេខ ១៣៦១ អយក.ប្រក ស្តីពីការប្តូរឈ្មោះវិទ្យាល័យ ថ្មល់កែង ក្នុងស្រុកកំចាយមារ ខេត្តព្រៃវែង ទៅជា «វិទ្យាល័យសខេង»	១៧០១
០២–៩–៩៥	ប្រកាស លេខ ១៣៩៤ អយក.ប្រក ស្តីពីការប្តូរឈ្មោះអនុវិទ្យាល័យ ស្រងែ ក្នុងស្រុកព្រៃឈរ ខេត្តកំពង់ចាម ទៅជា « អនុវិទ្យាល័យ ស្រេងគឹម »	១៧០៣

៨ - ទីស្តីការរដ្ឋមន្ត្រី ក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ

ប្រកាស

០៦–៩–៩៥	ប្រកាស លេខ ១៥៤ ប្រក.វវស.បុ ស្តីពីការផ្លាស់ប្តូរកន្លែងធ្វើការរបស់ មន្ត្រីរាជការ មន្ទីរវប្បធម៌ វិចិត្រសិល្បៈ ខេត្តកំពង់ចាម	១៧០៤

៩ - ទីស្តីការរដ្ឋមន្ត្រី ក្រសួងគ្រប់គ្រងបរិដ្ឋាន

សេចក្តីណែនាំ

០៤–៩–៩៥	សេចក្តីណែនាំ លេខ ១៦០២ បស្ថ អនុវត្តក្នុងឱកាសទិវាអនាម័យ បរិដ្ឋានជាតិ ថ្ងៃទី ២៣–១១–១៩៩៥	១៧០៥
០៥–៩–៩៥	ប្រកាស លេខ ១៦០៤ ចត.បស្ថ ស្តីពីការទទួលស្គាល់ និង ប្រគល់ ភារកិច្ចជូនមន្ត្រីរាជការ	១៧១០

១០ ទីស្តីការ ក្រសួងធម្មការ និង សាសនា

សេចក្តីសំរេច

០៤–៩–៩៥	សេចក្តីសំរេច លខ ១៧៧/៩៥ កធស ស្តីពីការអនុញ្ញាតអោយបង្កើត សមាគមព្រះពុទ្ធសាសនា អ៊ីក្លាន់តាវ	១៧១២

ង

១០ ទីស្តីការ ក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍

ប្រកាស

០៨–៩–៩៥ ប្រកាសលេខ១១២ បទ.ប្រក ស្តីពីការបង្កើតគណៈកម្មការកណ្តាល និង អនុគណៈកម្មការរៀបចំតាំងពិព័រណ៍បង្ហាញសមិទ្ធផលឆ្នាំ ១៩៩៣-១៩៩៥ ១៧១៣

I- ខុទ្ទកាល័យព្រះមហាក្សត្រ

១ - ព្រះរាជក្រម

ព្រះរាជក្រមលេខ នស/រកម/០៨៩៥/០៧

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ វរ្ម័ន

រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍ និករោត្តម

ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

* * *

- បានទ្រង់យល់ រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣
- បានទ្រង់យល់ព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ស្តីពីការតែងតាំង រាជរដ្ឋាភិបាលកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែ សំរួលសមាសភាព រាជរដ្ឋាភិបាលកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១០៩៤/៩០ ចុះថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា
- តាមសេចក្តីក្រាបបង្គំទូលស្នើសុំអំពីសម្តេចនាយករដ្ឋមន្ត្រីទាំងពីរ និង រដ្ឋមន្ត្រីក្រសួងពត៌មាន

ប្រកាសអោយប្រើ

ច្បាប់ដែលបានអនុម័តដោយរដ្ឋសភា នៅថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ ១៩៩៥ ស្តីពី របបសារពត៌មាន ដែលមានសេចក្តីទាំងស្រុងដូចតទៅ :

ច្បាប់
ស្តីពី
របបសារព័ត៌មាន

ជំពូកទី ១
សិទ្ធិនិងសេរីភាពខាងសារព័ត៌មាន

មាត្រា ១.-

ច្បាប់នេះកំណត់របបសារព័ត៌មាននិងធានារ៉ាប់រងសេរីភាពសារព័ត៌មាន និង សេរីភាពខាងការបោះពុម្ពផ្សាយឲ្យបានសមស្របតាមមាត្រា ៣១ និងមាត្រា ៤១ នៃរដ្ឋធម្មនុញ្ញនៃ ព្រះរាជាណាចក្រកម្ពុជា ។

មាត្រា ២.-

សារព័ត៌មានមានសិទ្ធិរក្សាការសម្ងាត់ស្តីពីប្រភពព័ត៌មានរបស់ខ្លួន ។

មាត្រា ៣.-

ដើម្បីរក្សាឯករាជ្យនៃសារព័ត៌មាន ការត្រួតពិនិត្យមុនពេល បោះពុម្ពផ្សាយ ត្រូវហាមឃាត់ ។

មាត្រា ៤.-

ការបោះពុម្ពផ្សាយនូវព័ត៌មានផ្លូវការដូចជា សេចក្តីថ្លែងការណ៍ ការប្រជុំកំណត់ហេតុប្រជុំឬរបាយការណ៍ណាមួយ ។ល។ មិនអាចត្រូវផ្តន្ទាទោសបានឡើយ ប្រសិនបើការផ្សាយនោះមានលក្ខណៈសមស្របតាមសភាពពេញលេញ ឬសេចក្តីសង្ខេបត្រឹមត្រូវតាមរឿងពិត ។

ពត៌មានផ្លូវការដែលជាកម្មវត្ថុនៃមាត្រានេះសំដៅចំពោះ ៖

១- សេចក្តីថ្លែងការណ៍ ការប្រជុំ កំណត់ហេតុប្រជុំ ឬរបាយការណ៍ របស់រដ្ឋសភារាប់ទាំងគណៈកម្មាធិការ ឬគណៈកម្មការនានារបស់ រដ្ឋសភាផង លើកលែងតែក្នុងករណីរដ្ឋសភាធ្វើ ការប្រជុំសម្ងាត់ដូចមានចែងក្នុងមាត្រា ៨៨ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ។

២- សេចក្តីថ្លែងការណ៍ ការប្រជុំ កំណត់ហេតុប្រជុំ ឬរបាយការណ៍នៃផ្នែក នីតិប្រតិបត្តិ រួមទាំងសេចក្តីថ្លែងការណ៍របស់រដ្ឋមន្ត្រី និងមន្ត្រីនានាផង ។

៣- គ្រប់ទិដ្ឋភាពនៃដំណើរការរបស់តុលាការ រាប់ទាំងនីតិវិធីទាំងឡាយផង លើកលែងតែក្នុងករណី ដូចខាងក្រោមនេះ ៖

- តុលាការហាមមិនឲ្យបើកចំហដល់សាធារណជន
- បញ្ញត្តិដោយមាត្រា ១៦ នៃច្បាប់នេះដែលទាក់ទងទៅនឹងអាថ៌កំបាំងរបស់បុគ្គលម្នាក់ៗនៅក្នុងដំណើរការជំនុំជំរះក្តី
- សំណុំរឿងដែលនៅក្នុងការអង្កេតស៊ើបសួររបស់តុលាការនៅឡើយ។

មាត្រា ៥.-

១- គោលការណ៍ទូទៅ

សារពត៌មាន មានសិទ្ធិទទួលពត៌មានដែលស្ថិតក្នុងការគ្រប់គ្រងរបស់រាជរដ្ឋាភិបាល លើកលែងតែពត៌មានណាដែលបណ្តាលឲ្យ ៖

- អន្តរាយដល់សន្តិសុខជាតិ
- អន្តរាយដល់ទំនាក់ទំនងជាមួយប្រទេសដទៃ
- មានការបំពានលើសិទ្ធិរបស់បុគ្គលម្នាក់ៗ ដោយរាប់ទាំងសំណុំរឿងរបស់មន្ត្រីរាជការ សំណុំរឿងពេទ្យ សំណុំរឿង និងឯកសារផ្លូវការសម្ងាត់ៗ ដទៃទៀតជាដើម
- មានការលាតត្រដាងឯកសារសម្ងាត់ផ្នែកពាណិជ្ជកម្ម ផ្នែកហិរញ្ញវត្ថុដែលបានមកពីបុគ្គល ឬអង្គភាពត្រឹមត្រូវតាមច្បាប់ណាមួយ និង

ការលាត់ត្រដាងនូវពត៌មានដែលពាក់ព័ន្ធទៅនឹងបទបញ្ជា ឬការត្រួតពិនិត្យរបស់ស្ថាប័នហិរញ្ញវត្ថុ

- ប៉ះពាល់ដល់សិទ្ធិជនណាម្នាក់ ក្នុងការនាំឲ្យមានជំនុំជំរះក្តីដោយអយុត្តិធម៌
- មានគ្រោះថ្នាក់ដល់មន្ត្រីដែលត្រូវអនុវត្តច្បាប់ ឬត្រូវបំពេញបេសកកម្មរបស់ខ្លួន ។

២- ការស្នើសុំពត៌មាន

ការស្នើសុំពត៌មានត្រូវធ្វើឡើងជាលាយលក្ខណ៍អក្សរ ហើយត្រូវបញ្ជាក់ឲ្យបានច្បាស់លាស់ អំពីពត៌មានដែលស្នើសុំទៅស្ថាប័ននានា ។

មន្ត្រីមានសមត្ថកិច្ចដែលគ្រប់គ្រងស្ថាប័ននោះ ត្រូវឆ្លើយតបទៅនឹងពាក្យសុំក្នុងរយៈពេលសាមសិបថ្ងៃ (៣០ថ្ងៃ) យ៉ាងយូរ ។ ប្រសិនបើការស្នើសុំនោះត្រូវបានបដិសេធទាំងស្រុង ឬខ្លះៗនោះ ហេតុផលនៃការបដិសេធត្រូវបញ្ជាក់ ឲ្យបានច្បាស់លាស់ជាលាយលក្ខណ៍អក្សរ ។

ជំពូកទី ២
ការទទួលខុសត្រូវនៃអ្នកសារពត៌មាន

មាត្រា ៦.-

អ្នកសារពត៌មានមានសិទ្ធិបង្កើតសមាគមអ្នកសារពត៌មាន ។ សមាគមអ្នកសារ ពត៌មាននោះត្រូវមានលក្ខណៈឯករាជ្យ ។ សមាគមអ្នកសារពត៌មាននីមួយៗ ត្រូវអនុម័តលក្ខន្តិកៈ របស់ខ្លួនដែលមិនផ្ទុយនឹងច្បាប់ជាធរមានដោយ មានការយល់ព្រមពីសមាជិកតាមការបោះឆ្នោត ។ អ្នកដឹកនាំសមាគមអ្នកសារពត៌មានដែលជាសមាជិកក្រុមអភិបាល ត្រូវមានការបោះឆ្នោតជ្រើសរើសតាមលក្ខណៈប្រជាធិបតេយ្យ ។

មាត្រា ៧.-

សមាគមអ្នកសារពត៌មាននីមួយៗត្រូវតាក់តែងក្រមសីលធម៌ដើម្បីអនុវត្តក្នុងសមាគមរបស់ខ្លួន ដើម្បីអ្នកសារពត៌មានមានកាតព្វកិច្ចគោរពគោលការណ៍ ចាំបាច់ជាអាទិ៍ដូចតទៅ ៖

១- គោរពសច្ចធម៌និងគោរពសិទ្ធិយល់ដឹងនូវសច្ចធម៌របស់សាធារណជន ។

២- ត្រូវផ្សាយនូវដំណឹងទាំងឡាយដោយសុចរិត ព្រមទាំងធ្វើអត្ថាធិប្បាយ ឬរិះគន់ឲ្យ ត្រឹមត្រូវ និងសមស្របតាមគតិយុត្តិធម៌ ។

៣- ត្រូវរាយការណ៍តែតាមហេតុការណ៍ដែលខ្លួនដឹង ពីប្រភពដើម តែប៉ុណ្ណោះ ។ អ្នកសារពត៌មានមិនត្រូវបំបាត់ចោលនូវពត៌មានសំខាន់ៗ ឬកែបន្លំឯកសារផ្សេងៗ ឡើយ ។

៤- ប្រើវិធីសុចរិតត្រឹមត្រូវដើម្បីស្វែងរកដំណឹង រូបថត និងឯកសារផ្សេងៗ។

៥- ត្រូវធ្វើការកែតម្រូវនូវពត៌មានណាដែលចេញផ្សាយរួចហើយៗមានលក្ខណៈមិនជាក់លាក់ និងនាំឲ្យមានការយល់ច្រឡំ ។

៦- ត្រូវចៀសវាងការផ្សព្វផ្សាយពត៌មាន ដែលញុះញង់ឲ្យមានការប្រកាន់ ពូជសាសន៍ ពណ៌សម្បុរ ភេទ ភាសា ជំនឿ សាសនា មតិ ឬនិន្នាការនយោបាយ ដើមកំណើតជាតិ ឋានៈសង្គម ធនធាន ឬស្ថានភាព ដទៃទៀត ។

៧- ត្រូវគោរពសិទ្ធិនិងសេរីភាពរស់នៅក្នុងជីវភាពឯកជនរបស់បុគ្គល ។

៨- ត្រូវគោរពឲ្យបានហ្មត់ចត់តាមក្បួនវេយ្យាករណ៍ ក្នុងការសរសេរអត្ថបទ ។

៩- ហាមបោះពុម្ពផ្សាយអត្ថបទ ឬរូបភាពអាសអាភាស និងរូបភាពនៃអំពើហិង្សា ។

១០- ហាមរំលោភលើសិទ្ធិ ដើម្បីមានការជំនុំជំរះក្តី ដោយយុត្តិធម៌របស់បុគ្គលម្នាក់ៗដូចមានចែងក្នុងរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា។

១១- ត្រូវចាត់ទុកចំណុចដូចខាងក្រោមនេះ ជាការរំលោភដ៏ធ្ងន់ធ្ងរ ខាងផ្នែកវិជ្ជាជីវៈ របស់អ្នកសារព័ត៌មាន ៖

- ការលួចចម្លងគំនិត ឬស្នាដៃរបស់អ្នកដទៃមកដាក់ថាជារបស់ខ្លួន
- បន្លំឲ្យគេយល់ខុស ដូចជាការសរសេរបញ្ចិតបញ្ចៀងដើម្បីឲ្យអ្នកអានមានការសង្ស័យដោយអយុត្តិធម៌លើបុគ្គលណាម្នាក់ ក្រុម បក្សណាមួយ ។
- ការមួលបង្កាច់ បរិហាកេរ្តិ៍ និងការជេរប្រមាថ
- ការទទួលសំណូកក្នុងបែបណាមួយ ឬការជរិតយកប្រាក់ដើម្បី ជាថ្នូរនឹងការបោះពុម្ពផ្សាយ ឬមិនបោះពុម្ពផ្សាយនូវព័ត៌មានណាមួយ ។

មាត្រា ៨.-

មុនពេលចាប់ផ្តើមចែកចាយសារព័ត៌មាន និយោជក ឬនិពន្ធនាយកត្រូវធ្វើ ពាក្យមួយច្បាប់(០១ច្បាប់) ជូនមកក្រសួងព័ត៌មានដើម្បីបញ្ជាក់អំពីអត្តសញ្ញាណរបស់ខ្លួន ។ ក្រសួងនេះ ត្រូវចេញបង្កាន់ដៃឲ្យទៅសារព័ត៌មានពេលបានទទួលសំណុំបែបបទទាំងមូល ។

ក្នុងករណីដែលនាយកការផ្សាយជាសមាជិករដ្ឋសភា ឬស្ថាប័នដែលមានអភ័យ ឯកសិទ្ធិ សារព័ត៌មាននោះត្រូវចាត់តាំងឲ្យមានសហនាយកការផ្សាយម្នាក់ទៀត ។

និយោជក ឬនិពន្ធនាយកដែលមិនគោរពបែបបទនេះជាមុន ត្រូវផ្តន្ទាទោស ពិន័យជាប្រាក់ ពីប្រាំសែនរៀល(៥០០.០០០រៀល) ទៅមួយលានប្រាំសែនរៀល (១.៥០០.០០០រៀល) ។ ក្នុងករណីមិនរាងចាលត្រូវពិន័យជាប្រាក់ទ្វេឡើង ។

មាត្រា ៩.-

សំណុំបែបបទដែលនិយោជក ឬនិពន្ធនាយក ត្រូវបំពេញមានជាអាទិ៍ :

- អត្តសញ្ញាណប័ណ្ណនៃសារព័ត៌មាន
- ឈ្មោះ និងអាស័យដ្ឋានរបស់និយោជក ឬនិពន្ធនាយក
- ឈ្មោះ និងអាស័យដ្ឋានរបស់រោងពុម្ព
- លិខិតថ្កោលទោស

រាល់ការផ្លាស់ប្តូរព័ត៌មានខាងលើនេះ ត្រូវជូនដំណឹងទៅក្រសួងព័ត៌មានប្រាំថ្ងៃ (៥ ថ្ងៃ) មុន លើកលែងតែករណីប្រធានសក្តិ ។

មាត្រា ១០.-

ជនណាម្នាក់ដែលយល់ថាអត្ថបទណាមួយ ទោះជាសរសេរបញ្ឆិតបញ្ឆៀងក៏ដោយ រូបគំនូរ ឬរូបថតណាមួយនៃសារព័ត៌មានណាមួយដែលមានលក្ខណៈ ខុសពីការពិត ធ្វើឲ្យខូចខាតដល់កិត្តិយសនិងសេចក្តីថ្លៃថ្នូររបស់ខ្លួនមានសិទ្ធិ ទាមទារឲ្យសារព័ត៌មាននោះធ្វើការកែតម្រូវឬមានសិទ្ធិឆ្លើយតប និងធ្វើបណ្តឹង ពីបទបរិហាកេរ្តិ៍ ពីបទមួលបង្កាច់ ឬពីបទជេរប្រមាថ ចំពោះការប៉ះពាល់កិត្តិយសនិងសេចក្តីថ្លៃថ្នូររបស់ខ្លួន ។ ចម្លើយកែតម្រូវ ឬឆ្លើយតបត្រូវចុះផ្សាយក្នុងរយៈ ពេលប្រាំពីរថ្ងៃ (៧ថ្ងៃ) យ៉ាង យូរ ឬនៅលេខបន្ទាប់ ក្រោយពីបានទទួលការទាមទារឲ្យកែតម្រូវ ឬ ឆ្លើយតប ។

ចំពោះករណីដែលពាក់ព័ន្ធដល់បុគ្គលសាធារណៈ គ្រប់ការពោលអះអាងឬការទំលាក់កំហុសដែលអ្នកសារព័ត៌មានយកមកចុះ ផ្សាយដោយផ្ទាល់ ឬក៏យកមកចុះផ្សាយបន្តខុសពីការពិត ក្នុងបំណងបំផ្លាញ បុគ្គលសាធារណៈនោះ គឺជាការមួលបង្កាច់ដែលច្បាប់ហាមឃាត់ ។

បើតុលាការរកឃើញថា ការផ្សាយណាមានលក្ខណៈខុសពីការពិត តាមបណ្តឹងរបស់ដើមបណ្តឹងរដ្ឋប្បវេណី តុលាការអាចបង្គាប់ឲ្យសារព័ត៌មាននោះ ៖

- ចុះផ្សាយនូវការកែតម្រូវ ឬ
- សងជំងឺចិត្ត ឬ
- ចុះផ្សាយនូវការកែតម្រូវផង និងបង់ប្រាក់សងជំងឺចិត្តផង ។

អត្ថបទកែតម្រូវដែលអ្នកសារពត៌មាន មានកាតព្វកិច្ចផ្សាយត្រូវចុះផ្សាយនៅទំព័រដូចគ្នា និងមានទំហំអក្សរប៉ុនគ្នានិងអត្ថបទដែលបានចាត់ទុកថា ជា អត្ថបទធ្វើឲ្យខូចខាតកិត្តិយស និងសេចក្តីថ្លៃថ្នូររបស់គេ ។

លើសពីនេះតុលាការអាចផ្តន្ទាទោសពិន័យជាប្រាក់ពីមួយលានរៀល (១.០០០.០០០ រៀល) ទៅ ប្រាំលានរៀល (៥.០០០.០០០ រៀល) ទៀតក៏បាន ។

ម្យ៉ាងទៀតក្នុងករណីដែលមានការវិនិច្ឆ័យអំពីអំពើណាមួយដែលមានចែងក្នុងកថាខ័ណ្ឌខាងលើ តុលាការអាចបញ្ជាឲ្យបិទផ្សាយសេចក្តីសំរេចរបស់ខ្លួននៅទីកន្លែងទាំងឡាយ ដែលតុលាការនឹងបញ្ជាក់ ដោយឲ្យជនជាប់ចោទទទួលបន្ទុកចេញសោហ៊ុយ ហើយតុលាការអាច ចុះផ្សាយសាលក្រមនេះក្នុងសារពត៌មាន មួយឬច្រើននិងឲ្យជនជាប់ចោទទទួលបន្ទុកចេញសោហ៊ុយទាំងអស់ ដោយកម្រិតត្រឹមមួយលានរៀល (១.០០០.០០០ រៀល) យ៉ាងច្រើន បំផុត ។

មាត្រា ១១.-

សារពត៌មានមិនត្រូវបោះពុម្ពផ្សាយនូវអ្វីដែលនាំឲ្យប៉ះពាល់ដល់សណ្តាប់ធ្នាប់សាធារណៈដោយញុះញង់ដោយផ្ទាល់ឲ្យមនុស្សម្នាក់ ឬច្រើននាក់ប្រព្រឹត្តអំពើ ហិង្សា។

ការប្រព្រឹត្តិបទល្មើសដែលមានចែងខាងលើនេះ ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី មួយលានរៀល (១.០០០.០០០ រៀល) ទៅ ប្រាំលានរៀល (៥.០០០.០០០ រៀល) ។

បុគ្គលរងគ្រោះដោយអំពើខាងលើ មានសិទ្ធិតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីទៅតុលាការ ។

គ្រប់ករណីទាំងអស់ តុលាការត្រូវពិនិត្យទៅលើទំនាក់ទំនងដោយផ្ទាល់រវាងអត្ថបទញុះញង់ នឹងអំពើនោះ ។ អត្ថបទដែលមានចំណាស់លើសពីបីខែ (៣ ខែ) មិនអាចយក មកសំអាងក្នុងការចោទប្រកាន់បានឡើយ ។

មាត្រា ១២.-

សារពត៌មានមិនត្រូវបោះពុម្ពផ្សាយឬផ្សាយបន្តនូវពត៌មានដែលបណ្តាលឲ្យប៉ះពាល់ ដល់សន្តិសុខជាតិ និងស្ថេរភាពនយោបាយ ។

និយោជក និពន្ធនាយក ឬអ្នកនិពន្ធអត្ថបទអាចត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពីប្រាំលានរៀល (៥.០០០.០០០ រៀល) ទៅដប់ប្រាំលានរៀល (១៥.០០០.០០០ រៀល) ដោយមិនទាន់គិតដល់ការផ្តន្ទាទោសតាមច្បាប់ព្រហ្មទណ្ឌ ។

ក្រសួងពត៌មាននិងក្រសួងមហាផ្ទៃ មានសិទ្ធិប្រមូលយកអត្ថបទល្មើស និង សារពត៌មានលេខចេញផ្សាយអត្ថបទល្មើស ដែលចេញផ្សាយដោយសារពត៌មាននោះ ។ ក្រសួងពត៌មាន មានសិទ្ធិផ្អាកការផ្សាយក្នុងរយៈពេលមិនហួសពីសាមសិបថ្ងៃ (៣០ថ្ងៃ) ហើយបញ្ជូន សំណុំរឿងទៅតុលាការ ។

មាត្រា ១៣ .-

សារពត៌មានមិនត្រូវបោះពុម្ពផ្សាយ ឬផ្សាយបន្តការមិនពិតដែលជាការជេរ ប្រមាថ ការមើលងាយដល់ស្ថាប័នជាតិ ។ ការផ្សាយបែបនេះ អាចត្រូវផ្តន្ទាទោស ពិន័យជាប្រាក់ពី ពីរ លានរៀល (២.០០០.០០០ រៀល) ទៅដប់លានរៀល (១០.០០០.០០០ រៀល) ។

មាត្រា ១៤.-

សារពត៌មានមិនត្រូវបោះពុម្ពផ្សាយនូវអ្វីដែលប៉ះពាល់ដល់ប្រពៃណីល្អរបស់សង្គម ជាតិជាអាទិ៍ ៖

- ពាក្យអសុរោះមិនគួរគប្បី ដូចជា អា មីង ជាដើម
- ពាក្យដែលពិពណ៌នាចំៗ អំពីសកម្មភាពរួមរក្ស
- រូបគំនូរ ឬរូបថត ដែលបង្ហាញនូវ គេរ្តិ៍ភេទ ឬរូបអាក្រាត លើកលែងតែ ទិសដៅសំរាប់អប់រំចេញ
- រូបភាពដែលប្រមាថមើលងាយប្រៀបធៀបការរំលោភទៅលើមាត្រា

នេះ អាចត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពីមួយលានរៀល (១.០០០.០០០ រៀល) ទៅ ប្រាំលានរៀល (៥.០០០.០០០ រៀល)។

មាត្រា ១៥.-

លើកលែងតែមានការអនុញ្ញាតពីតុលាការ សារពត៌មានពុំអាចផ្សាយ ដំណឹង រូបថត ឬគំនូរ ដែលអាចឲ្យអ្នកអានស្គាល់ឈ្មោះ និងភិនភាគនៃ ៖

- ភាគីក្នុងរឿងរដ្ឋប្បវេណី ដែលទាក់ទងទៅនឹងបិតុភាព អាពាហ៍ពិពាហ៍ រឿងលែង លះប្តីប្រពន្ធ ឬរឿងអាណាព្យាបាលលើកុមារ
- យុវជនអាយុតិចជាងដប់ប្រាំបីឆ្នាំ (១៨ ឆ្នាំ) ក្នុងរឿងវិវាទរដ្ឋប្បវេណី ឬព្រហ្មទណ្ឌ
- ស្ត្រីដែលទទួលរងគ្រោះដោយអំពើរំលោភលើរាងកាយ ឬអំពើចាប់បង្ខំ សេពសន្ធវៈ ។

ក្នុងករណីដែលសាមីជន ឬអ្នកអាណាព្យាបាលយល់ព្រមជាលាយលក្ខណ៍អក្សរ សារពត៌មានអាចផ្សព្វផ្សាយរឿងនេះបាន លើកលែងតែការផ្សាយនេះ នាំឲ្យប៉ះពាល់ដល់ការស៊ើប អង្កេតរបស់តុលាការ ។

បុគ្គលណា ដែលត្រូវសារពត៌មានបំពានសិទ្ធិខាងលើនេះ មានសិទ្ធិប្តឹងទៅតុលាការដើម្បីទាមទារជម្ងឺចិត្ត ។ ការប្រព្រឹត្តិល្មើសនឹងបទបញ្ញត្តិខាងលើនេះត្រូវផ្តន្ទាទោសពិន័យជាប្រាក់ ពីមួយលានរៀល (១.០០០.០០០ រៀល) ទៅប្រាំលានរៀល (៥.០០០.០០០ រៀល) ។

មាត្រា ១៦.-

ដំណឹងផ្សាយពាណិជ្ជកម្ម អាចចាត់ទុកថាមានលក្ខណៈភូតកុហក បើការផ្សាយនោះ មានន័យបំផ្លើសហួសហេតុអំពីគុណភាព ឬគុណសម្បត្តិ ផលិតផល ឬសេវាណាមួយ បណ្តាលឲ្យអ្នកប្រើប្រាស់មានការភាន់ច្រឡំអំពីគុណភាព ឬគុណសម្បត្តិនោះ ។

ការផ្សាយពាណិជ្ជកម្មរបៀបនេះត្រូវហាមឃាត់ ប៉ុន្តែសារពត៌មានដែលចុះផ្សាយដំណឹងភូតកុហកនេះ មិនមែនជាអ្នកទទួលខុសត្រូវចំពោះមុខច្បាប់ទេលើកលែងតែសារពត៌មាននេះនៅតែបន្តផ្សាយដំណឹងនេះ ក្រោយពីបានទទួលការហាមប្រាមជាលាយលក្ខណ៍អក្សរពី តុលាការ ឬពីក្រសួងមានសមត្ថកិច្ច រួចហើយ ។

ផ្ទុយទៅវិញអ្នកម្ចាស់ឃោសនាពាណិជ្ជកម្ម ជាអ្នកទទួលខុសត្រូវចំពោះមុខច្បាប់ និងចំពោះតុលាការ បើមានការប្តឹងផ្តល់អំពីបុគ្គល ឬសមាគមអ្នកប្រើប្រាស់ណាមួយ ដែលបានទទួលការខូចខាតប្រយោជន៍បណ្តាលមកពីការផ្សាយពាណិជ្ជកម្ម ភូតកុហកនេះ ។

ការផ្សាយពាណិជ្ជកម្មភូតកុហក អាចត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពីមួយលានរៀល (១.០០០.០០០ រៀល) ទៅ ប្រាំលានរៀល (៥.០០០.០០០ រៀល) ។

ជំពូកទី ៣

ការប្រកួតប្រជែង

មាត្រា ១៧.-

បុគ្គលណាក៏ដោយ ទោះជារូបវន្តបុគ្គលក្តី ឬនីតិបុគ្គលក្តី មិនអាចធ្វើជាម្ចាស់ ឬជា អ្នកកាន់កាប់សារពត៌មានជាភាសាខ្មែរលើសពីពីរ (២) ឡើយនៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

មាត្រា ១៨.-

ចំនួនសរុបទាំងអស់នៃសារពត៌មានជាភាសាខ្មែរ ដែលកាន់កាប់ដោយជនបរទេស មិនត្រូវឲ្យលើសពីម្ភៃភាគរយ (២០%) នៃចំនួនសារពត៌មានជាភាសាខ្មែរទាំងអស់ដែលចេញផ្សាយនៅក្នុងព្រះរាជាណាចក្រកម្ពុជាឡើយ ។

សារពត៌មានដែលកាន់កាប់ដោយជនបរទេស ដែលបានអនុញ្ញាតឲ្យចេញផ្សាយរួចហើយ មិនអាចត្រូវបិទដោយមូលហេតុថយចុះចំនួនសរុបទាំងអស់នៃសារពត៌មានជាភាសាខ្មែរនោះទេ ។

ជំពូកទី ៤

ការតម្កល់ទុក

មាត្រា ១៩.-

និពន្ធនាយក ឬនាយកការផ្សាយ ត្រូវតម្កល់ទុកសារពត៌មានរាល់លេខរបស់ខ្លួនចំនួនពីរច្បាប់ (០២ ច្បាប់) នៅបណ្ណាល័យជាតិ និងប្រាំមួយច្បាប់ (០៦ ច្បាប់) ទៀតនៅក្រសួងពត៌មាន ។ ការតម្កល់ទុកនេះត្រូវធ្វើឡើងក្នុងរយៈពេល ដប់ប្រាំថ្ងៃ (១៥ ថ្ងៃ) ចំពោះការបោះពុម្ពនៅ ភ្នំពេញ និងសែសិបប្រាំថ្ងៃ(៤៥ ថ្ងៃ) នៅកន្លែងដទៃទៀត ដោយគិតពីកាលបរិច្ឆេទនៃការចេញផ្សាយ ។

ការប្រព្រឹត្តិល្មើសនឹងបទបញ្ញត្តិខាងលើនេះ ត្រូវផ្តន្ទាទោសពិន័យជាអន្តរការណ៍ ដោយក្រសួងពត៌មានជាប្រាក់ពីបីម៉ឺនរៀល (៣០.០០០ រៀល) ទៅបីសែនរៀល (៣០០.០០០ រៀល) ។

ជំពូកទី ៥

អវសានបញ្ញត្តិ

មាត្រា ២០.-

អំពើប្រព្រឹត្តរបស់និយោជក និពន្ធនាយក ឬអ្នកនិពន្ធអត្ថបទ ដែលរំលោភ ច្បាប់ព្រហ្មទណ្ឌ ត្រូវទទួលទោសតាមច្បាប់ព្រហ្មទណ្ឌ ។ ប៉ុន្តែទោះជាយ៉ាងណាក៏ដោយ ក៏គ្មានជនណាម្នាក់ត្រូវចាប់ចង ឬជាប់ពន្ធនាគារ ដោយសារការបញ្ចេញមតិឡើយ ។

មាត្រា ២១.-

បទបញ្ញត្តិទាំងឡាយដែលមានពីមុនមកហើយទាក់ទងនឹងសារព័ត៌មាន ត្រូវចាត់ទុកជានិរាករណ៍ ។

ធ្វើនៅរាជធានីភ្នំពេញ , នៅថ្ងៃទី ០១ ខែ កញ្ញា ឆ្នាំ ១៩៩៥

ក្នុងព្រះបរមនាម និង តាមព្រះរាជបង្គាប់

ប្រមុខរដ្ឋស្តីទី

ហត្ថលេខា

ជា ស៊ីម

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ

សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ

បានបង្គំទូលថ្វាយ និង ជំរាបជូន

សម្តេចនាយករដ្ឋមន្ត្រីទី ១ និង ទី ២	នាយករដ្ឋមន្ត្រីទី១	នាយករដ្ឋមន្ត្រីទី ២
រដ្ឋមន្ត្រីក្រសួងព័ត៌មាន	ព្រះហស្តលេខា និង ត្រា	ហត្ថលេខា និង ត្រា
ហត្ថលេខា និង ត្រា		
អៀង ម៉ូលី	**នរោត្តម រណឫទ្ធិ**	**ហ៊ុន សែន**

២ - ព្រះរាជក្រឹត្យ

ព្រះរាជក្រឹត្យ លេខ នស/រកត/០៩៩៥/៦៤

យើង

ព្រះបាទសម្តេចព្រះនរោត្តម សីហនុ វរ្ម័ន

រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស

អគ្គមហាបុរសរតន៍ និករោត្តម

ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

- បានឃើញ រដ្ឋធម្មនុញ្ញ នៃ ព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣ .
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា .
- បានឃើញច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី ចុះថ្ងៃទី ១៩ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ .
- យោងតាមសំណើរបស់នាយករដ្ឋមន្ត្រីទី ១ និង នាយករដ្ឋមន្ត្រីទី ២ នៃ រាជរដ្ឋាភិបាលជាតិកម្ពុជា ចុះថ្ងៃទី ៣០ ខែ កក្កដា ឆ្នាំ ១៩៩៥ .

ត្រាស់បង្គាប់

មាត្រា ១ : តែងតាំងឯកឧត្តម **ស៊ុន នីនី** ជាអគ្គនាយកនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ។

មាត្រា ២ : នាយករដ្ឋមន្ត្រីទី ១ និងនាយករដ្ឋមន្ត្រីទី ២ នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តអោយបានសំរេចតាមព្រះរាជក្រឹត្យនេះ ។

មាត្រា ៣ : ព្រះរាជក្រឹត្យនេះ ចូលជាធរមានច្បាប់ចាប់ពីថ្ងៃឡាយព្រះហស្ថលេខានេះតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ , ថ្ងៃទី ០៧ ខែ កញ្ញា ឆ្នាំ ១៩៩៥

ព្រះហស្ថលេខា

នរោត្តម សីហនុ

* * *

ព្រះរាជក្រឹត្យ លេខ នស/រកត/០៩៩៥/៦៥

យើង

ព្រះបាទសម្តេចព្រះនរោត្តម សីហនុ វរ្ម័ន

រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស

អគ្គមហាបុរសរតន៍ និករោត្តម

ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់ រដ្ឋធម្មនុញ្ញ នៃ ព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣ .
- បានទ្រង់យល់ ព្រះរាជក្រឹត្យចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា .
- បានទ្រង់យល់ព្រះរាជក្រឹត្យ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសំរួលសមាសភាព រាជរដ្ឋាភិបាលកម្ពុជា .
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១០៩៤/៩០ ចុះថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា .
- តាមសេចក្តីក្រាបបង្គំទូលស្នើសុំអំពីសម្តេចនាយករដ្ឋមន្ត្រី ទាំងពីរ និង អំពីទេសរដ្ឋមន្ត្រី និងជា រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ .
- គណៈរដ្ឋមន្ត្រីយល់ព្រមផង .

ត្រាស់បង្គាប់

ឧបសម្ព័ន្ធ I

អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន

មាត្រា ១ :

ត្រូវបានបង្កើតអាជ្ញាធរជាតិប្រយុទ្ធប្រឆាំង នឹងគ្រឿងញៀន ដែលមានស្វ័យភាពរដ្ឋបាល និង ហិរញ្ញវត្ថុ ។

មាត្រា ២ :

អាជ្ញាធរជាតិ មានសមាសភាពដូចខាងក្រោម ÷

– សម្តេចក្រុមព្រះនាយករដ្ឋមន្ត្រីទី ១ និងសម្តេចនាយករដ្ឋមន្ត្រីទី ២	សហប្រធាន
– រដ្ឋមន្ត្រីក្រសួងយុត្តិធម៌	អនុប្រធាន
– សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ	សមាជិក
– សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី	សមាជិក
– រដ្ឋមន្ត្រីក្រសួងសុខាភិបាល	សមាជិក
– សហរដ្ឋមន្ត្រីក្រសួងការពារជាតិ	សមាជិក
– រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ	សមាជិក
– រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (ហិរញ្ញវត្ថុ)	សមាជិក
– រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា	សមាជិក
– រដ្ឋមន្ត្រីក្រសួងសង្គមកិច្ចការងារ និងអតីតយុទ្ធជន	សមាជិក
– ទេសាភិបាលធនាគារជាតិ	សមាជិក

រដ្ឋមន្ត្រី និង រដ្ឋលេខាធិការផ្សេងទៀត ដែលពាក់ព័ន្ធ នឹងរបៀបវារៈ អាចត្រូវបាន អញ្ជើញចូលរួមប្រជុំ ។

អាជ្ញាធរជាតិក៏អាចកោះអញ្ជើញបុគ្គលណាមួយអោយចូលរួមប្រជុំ កាលបើយល់ឃើញថាមានការចាំបាច់ ។

អាជ្ញាធរជាតិនេះប្រជុំយ៉ាងតិចពីរដងក្នុងមួយឆ្នាំ ។ បើប្រធានអវត្តមាន អាជ្ញាធរជាតិត្រូវប្រជុំក្រោមអធិបតីភាពនៃអនុប្រធាន ។

អាជ្ញាធរជាតិនេះ មានអគ្គលេខាធិការដ្ឋានមួយដែលទទួលខុសត្រូវក្នុងការដាក់អោយអនុវត្តនយោបាយ និងធានាសម្របសម្រួលជាអចិន្ត្រៃយ៍ នូវវិធានការរបស់រាជរដ្ឋាភិបាល ។

មាត្រា ៣ :

អាជ្ញាធរជាតិកំណត់ន័យ សម្របសម្រួល និងជំរុញអនុវត្តនយោបាយរបស់រាជរដ្ឋាភិបាលក្នុងការប្រយុទ្ធប្រឆាំងនឹងគ្រឿងញៀន ជាពិសេសនៅក្នុងវិស័យខាងក្រោមនេះ ÷

– ការអនុវត្តន៍បទបញ្ញត្តិទាំងឡាយនៃអនុសញ្ញាជាតិ ស្តីពីគ្រឿងញៀន ឆ្នាំ ១៩៦១ ឆ្នាំ ១៩៧១ និងឆ្នាំ ១៩៨៨ ។

– ការបង្កើតនិងការសម្របអត្ថបទច្បាប់ និងបទបញ្ញាស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។

– ការអប់រំ បង្ការកុំអោយមានការប្រើប្រាស់គ្រឿងញៀន ។

– ការលើកទឹកចិត្តដល់គ្រប់អ្នកផ្តួចផ្តើមគំនិតក្នុងការប្រយុទ្ធប្រឆាំងគ្រឿងញៀន ។

– ការប្រយុទ្ធប្រឆាំង និងជំនួញលួចលាក់គ្រឿងញៀន និងសារធាតុសំរាប់ផ្សំថ្នាំញៀន ហើយនឹងការសំអាតប្រាក់បានមកពីជំនួញលួចលាក់នៃគ្រឿងញៀន ដោយមិនទាន់គិតដល់ការដែលត្រូវប្រគល់ជូនមជ្ឈមណ្ឌលបង្ក្រាបជំនួញគ្រឿងញៀន ខុសច្បាប់ និងមិនទាន់គិតដល់មុខការដែលត្រូវប្រគល់ជូនគណៈកម្មាធិការប្រឆាំង និងការសំអាតប្រាក់នោះដែលនឹងត្រូវបង្កើត ។

– ការទទួលព្យាបាល និងការជួយអោយអ្នកញៀនបានមករស់នៅតាមភាពធម្មតាវិញ ។

– ការបណ្តុះបណ្តាលបុគ្គលិក សំរាប់ប្រយុទ្ធប្រឆាំងនឹងការប្រើប្រាស់គ្រឿងញៀន និងការធ្វើជំនួញលួចលាក់នៃគ្រឿងញៀន និងសារធាតុសំរាប់ផលិតគ្រឿងញៀនព្រមទាំងប្រឆាំងនឹងការសំអាតប្រាក់ ដែលបានមកពីជំនួញលួចលាក់នៃគ្រឿងញៀន ។

– ការស្រាវជ្រាវអំពីការញៀនជាតិពុល ។

– ការសហប្រតិបត្តិការអន្តរជាតិ ក្នុងការប្រយុទ្ធប្រឆាំងនឹងគ្រឿងញៀន ។

ម៉្យាងទៀត អាជ្ញាធរជាតិនេះត្រូវធានាធ្វើអោយព្រះរាជាណាចក្រកម្ពុជាបានបំពេញកាតព្វកិច្ចដែលទាមទារក្នុងអនុសញ្ញាអន្តរជាតិ ទាំងក្នុងផ្ទៃប្រទេស ទាំងក្នុងទំនាក់ទំនងជាមួយនឹងប្រទេសឯទៀត ឬអង្គការអន្តរជាតិដែលទទួល

បន្ទុកត្រួតពិនិត្យគ្រឿងញៀន ព្រមទាំងក្នុងការដាក់អោយដំណើរការនូវយន្តការជាតិ និងអន្តរជាតិ សំរាប់ត្រួតពិនិត្យគ្រឿងញៀន ។

ជំពូក II

អំពីប្រភពធនធាន

មាត្រា ៤ :

អាជ្ញាធរជាតិនេះមានថវិកាស្វយ័តមួយ ដើម្បីរ៉ាប់រងការប្រព្រឹត្តិទៅ នៃអគ្គលេខាធិការដ្ឋានរបស់ខ្លួន និងដើម្បីគាំទ្រសកម្មភាពទាំងឡាយប្រយុទ្ធប្រឆាំងនឹងគ្រឿងញៀន ឬការផ្តើមគំនិតរបស់រដ្ឋអំណាចកណ្តាល និង មូលដ្ឋាន គ្រឹះស្ថានសាធារណៈទាំងឡាយព្រមទាំងអង្គការ សមាគម ឬអ្នកចូលរួមជាឯកជនក្នុងការប្រយុទ្ធប្រឆាំង នឹងការប្រើប្រាស់គ្រឿងញៀន ។

ធនធាន និង ថវិកានេះត្រូវបានផ្គត់ផ្គង់ដោយ ÷

- វិភាគទានរបស់ថវិកាជាតិ

- ទ្រព្យ និងរបស់មានតម្លៃដែលបានមកពីការអនុវត្តន៍សេចក្តីសំរេចរឹបអូសរបស់តុលាការពីអ្នកជំនួញខុសច្បាប់ ហើយបញ្ចូលទៅក្នុងមូលនិធិសំរាប់ប្រយុទ្ធប្រឆាំងនឹងគ្រឿងញៀន ។

- ប្រាក់ជំនួយ និងអំណោយដែលផ្តល់ជូនអាជ្ញាធរជាតិនេះ ដោយរដ្ឋាភិបាលបរទេស អង្គការអន្តរជាតិ និងអង្គការមិនមែនរដ្ឋាភិបាលសំរាប់ប្រយុទ្ធប្រឆាំង នឹងគ្រឿងញៀន ។

អាជ្ញាធរជាតិនេះ នឹងត្រួតពិនិត្យការប្រើប្រាស់មូលនិធិខាងលើរបស់អគ្គលេខាធិការសំរាប់ប្រយុទ្ធប្រឆាំងនឹងគ្រឿងញៀន ។ អាជ្ញាធរជាតិមានសិទ្ធិចាត់ចែងលើទ្រព្យសម្បត្តិដែលបញ្ចូលទៅក្នុងមូលនិធិខាងលើ ។

ជំពូក III

ការត្រួតពិនិត្យគណនេយ្យ

មាត្រា ៥ :

ការត្រួតពិនិត្យគណនេយ្យត្រូវប្រគល់អោយស្នងការគណនេយ្យមួយរូប ដែលតែងតាំងដោយក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។

ជំពូក IV

អគ្គលេខាធិការដ្ឋាន

មាត្រា ៦ :

អគ្គលេខាធិការដ្ឋានត្រូវដឹកនាំដោយអគ្គលេខាធិការមួយរូប និងមាន អគ្គលេខារង ជាជំនួយការ ។

អគ្គលេខាធិការមានឋានៈស្មើនឹងអគ្គនាយក ត្រូវបានតែងតាំងដោយព្រះរាជក្រឹត្យតាមសំណើរបស់ប្រធានអាជ្ញាធរជាតិ ។

អគ្គលេខាធិការដ្ឋាន មានទីតាំងនៅទីស្តីការក្រសួងមហាផ្ទៃ ។

សមាជិកនៃអាជ្ញាធរជាតិត្រូវចាត់បញ្ជូនមន្ត្រីតំណាងរបស់ខ្លួនអោយទៅចូលរួមបំពេញការងារជាប្រចាំនៅក្នុងអគ្គលេខាធិការដ្ឋាននេះ ។

មាត្រា ៧ :

អគ្គលេខាធិការមានភារៈកិច្ច :

- រៀបចំការពិភាក្សារបស់អាជ្ញាធរជាតិ រួលរួមពិភាក្សា និងរ៉ាប់រងការ អនុវត្តន៍សេចក្តីសំរេចទាំងឡាយរបស់អាជ្ញាធរនេះ ។
- ជំរុញ និងសម្របសម្រួលជាអចិន្ត្រៃយ៍នូវវិធានការរបស់ក្រសួងមាន សមត្ថកិច្ចនៅក្នុងវិស័យដែលបានចែងខាងលើ ។
- ទទួលបន្ទុកទាក់ទងជាមួយអង្គការអន្តរជាតិនានា ជំរុញ ឬសំរួលការ បញ្ជូនពត៌មាន ឬស្ថិតិដែលមានកំណត់ក្នុងសន្ធិសញ្ញានៅអង្គការអន្តរជាតិនានា ដែលមានសមត្ថកិច្ច ។

– បញ្ជូនទៅអគ្គលេខាធិការ នៃអង្គការសហប្រជាជាតិ នូវអាស័យដ្ឋាន របស់អាជ្ញាធរមានសមត្ថកិច្ច ដើម្បីអនុវត្តបទបញ្ញត្តិ នៃ អនុសញ្ញា ។

មាត្រា ៨ :

អគ្គលេខាធិការប្រើប្រាស់បុគ្គលិកដែលក្រសួងនានា នឹងគ្រឹះស្ថានសាធារណៈពាក់ព័ន្ធបានប្រគល់អោយ ។

ចំនួននិងការបែងចែកបុគ្គលិកអោយទៅអគ្គលេខាធិការដ្ឋាន ត្រូវកំណត់ដោយរដ្ឋមន្ត្រីមានសមត្ថកិច្ច នៅពេលប្រជុំអាជ្ញាធរជាតិ ។

មាត្រា ៩ :

អគ្គលេខាធិការគ្រប់គ្រងថវិកាស្វយ័តរបស់អាជ្ញាធរជាតិបែងចែកមូលនិធិដែលបានផ្តល់អោយសំរាប់ប្រយុទ្ធប្រឆាំងនឹងគ្រឿងញៀន អោយប្រើប្រាស់ទៅតាមគំនិតផ្តើមទាំងឡាយ និងតម្រូវការជាក់លាក់របស់គ្រឹះស្ថានសាធារណៈទាំងឡាយ ឬអ្នកចូលរួមជាឯកជន ក្រោមការត្រួតពិនិត្យរបស់អាជ្ញាធរជាតិ យោងទៅតាមការចង្អុលទិសរបស់អាជ្ញាធរនេះ ឬការសំរេចទាំងឡាយរបស់អាជ្ញាធរនេះ ។

មាត្រា ១០ :

ការរៀបចំ និង ការប្រព្រឹត្តិទៅ នៃអគ្គលេខាធិការដ្ឋានរបស់អាជ្ញាធរជាតិ ត្រូវកំណត់ដោយអនុក្រឹត្យ ។

ជំពូក V

អវសានប្បញ្ញត្តិ

មាត្រា ១១ :

បទបញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

មាត្រា ១២ :

ព្រះរាជក្រឹត្យនេះ មានអនុភាពអនុវត្តចាប់ពីថ្ងៃឡាយព្រះហស្តលេខា ។

មាត្រា ១៣ :

នាយករដ្ឋមន្ត្រីទីមួយ និង នាយករដ្ឋមន្ត្រីទីពីរ សហរដ្ឋមន្ត្រីទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសុខាភិបាល រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ សហរដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា រដ្ឋមន្ត្រីក្រសួងសង្គមកិច្ចការងារ និងអតីតយុទ្ធជន និងទេសាភិបាលធនាគារជាតិ ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ។

ធ្វើនៅរាជធានីភ្នំពេញ , ថ្ងៃទី ០៧ ខែ កញ្ញា ឆ្នាំ ១៩៩៥

ព្រះហស្តលេខា

នរោត្តម សីហនុ

បានបង្គំទូលថ្វាយ និង ជំរាបជូន	បានយកសេចក្តីបង្គំទូលថ្វាយ
សម្តេចនាយករដ្ឋមន្ត្រីទី ១ និងទី ២	សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ
ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងយុត្តិធម៌	នាយករដ្ឋមន្ត្រីទី ១ នាយករដ្ឋមន្ត្រីទី ២
ហត្ថលេខា	ព្រះហស្តលេខា និងត្រា ហត្ថលេខា និង ត្រា
ចែម ស្គួន	**នរោត្តម រណឫទ្ធិ ហ៊ុន សែន**

* * *

ព្រះរាជក្រឹត្យ លេខ នស/រកត/០៩៩៥/៦៦

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ វរ្ម័ន

រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍

និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

- បានឃើញព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើ ប្រាស់ជាផ្លូវការនូវច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញក្រឹត្យចុះថ្ងៃទី ១៩ ខែ តុលា ឆ្នាំ ១៩៩៣ ស្តីពីការរៀបចំសញ្ញា និង រូបភាពឋានន្តរសក្តិនគរបាលជាតិកម្ពុជា
- យោងសំណើរបស់នាយករដ្ឋមន្ត្រីទី១ និង នាយករដ្ឋមន្ត្រីទី២ នៃរាជរដ្ឋាភិបាលកម្ពុជា

ត្រាស់សម្រេច

មាត្រា ១ : ត្រូវបានបំពាក់ឋានន្តរសក្តិថ្នាក់ ឧត្តមសេនីយ៍ឯក ជូនឯកឧត្តមនាយនគរបាលជាតិ ដូចមានរាយនាមខាងក្រោម :

១ – ឯកឧត្តម **ឡុយ សុផាត** អភិបាលខេត្តស្វាយរៀង

២ – ឯកឧត្តម **ជុំ ចន់** ទីប្រឹក្សាផ្ទាល់សម្តេចប្រធានរដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា

៣–ឯកឧត្តម **ឆោ ប៊ុនស្រ៊ី** បេសកជនពិសេសរបស់សម្តេចក្រុមព្រះនាយករដ្ឋមន្ត្រីទី ១ និង សម្តេចនាយករដ្ឋមន្ត្រីទី២

៤–ឯកឧត្តម **ខួន សារ៉េត** ទីប្រឹក្សាសម្តេចនាយករដ្ឋមន្ត្រីទី ២

មាត្រា ២ : ត្រូវបានបំពាក់ឋានន្តរសក្តិថ្នាក់ ឧត្តមសេនីយ៍ទោ ជូនឯកឧត្តម **គន់ គីម** បេសកជនពិសេសរបស់សម្តេចនាយករដ្ឋមន្ត្រីទី ២

មាត្រា ៣ : ត្រូវបានបំពាក់ឋានន្តរសក្តិថ្នាក់ ឧត្តមសេនីយ៍ត្រី ជូនអស់លោកដូចមានរាយនាមខាងក្រោមនេះ :

១–លោក **ម៉ាត់លី វុនស្តាដាវី** ទីប្រឹក្សាឯកឧត្តមរដ្ឋមន្ត្រី

២–លោក **ខៀវ សុគីត** ទីប្រឹក្សាឯកឧត្តមរដ្ឋមន្ត្រី

៣–លោក **ខុច សម្បត្តិ** ទីប្រឹក្សាឯកឧត្តមរដ្ឋមន្ត្រី

៤–លោក **ធម្ម ខន** ទីប្រឹក្សាឯកឧត្តមរដ្ឋមន្ត្រី

៥–លោក **អៅ គឹមឈួន** ទីប្រឹក្សាឯកឧត្តមរដ្ឋមន្ត្រី

៦–លោក **តោ សៀត** ទីប្រឹក្សាឯកឧត្តមរដ្ឋមន្ត្រី

មាត្រា ៤ : នាយករដ្ឋមន្ត្រីទី ១ និង នាយករដ្ឋមន្ត្រីទី ២ នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវទទួល បន្ទុកអនុវត្តអោយបានសំរេចតាមព្រះរាជក្រឹត្យនេះ ។

មាត្រា ៥ : ព្រះរាជក្រឹត្យនេះចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្ថលេខានេះតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ , ថ្ងៃទី ០៨ ខែ កញ្ញា ឆ្នាំ ១៩៩៥

ព្រះហស្តលេខា

នរោត្តម សីហនុ

* * *

ព្រះរាជក្រឹត្យ លេខ នស/រកត/០៩៩៥/៦៧

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ វរ្ម័ន

រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍

និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើប្រាស់ជាផ្លូវការនូវច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញក្រឹត្យ ចុះថ្ងៃទី ១៩ ខែ តុលា ឆ្នាំ ១៩៩៣ ស្តីពីការរៀបចំសញ្ញា និងរូបភាពឋានន្តរសក្តិនគរបាលជាតិកម្ពុជា
- យោងសំណើរបស់នាយករដ្ឋមន្ត្រីទី១ និងនាយករដ្ឋមន្ត្រីទី២ នៃរាជរដ្ឋាភិបាលកម្ពុជា

ប្រកាសបង្គាប់

មាត្រា ១ : ត្រូវបានបំពាក់ឋានន្តរសក្តិថ្នាក់ ឧត្តមសេនីយ៍ឯក ជូនឯកឧត្តម **សូរ ផន** អគ្គាធិការ នៃអគ្គាធិការដ្ឋានកិច្ចការនយោបាយ រដ្ឋបាល និង នគរបាល ។

មាត្រា ២ : ត្រូវបានបំពាក់ឋានន្តរសក្តិថ្នាក់ ឧត្តមសេនីយ៍ទោ ជូនអស់លោកនាយនគរបាលជាតិ ដូចមានរាយនាមខាងក្រោម :

១-លោក **គេច សាមឡូ** អគ្គនាយករងនៃអគ្គនាយកដ្ឋាននគរបាលជាតិ

២-លោក **គីម សំណាង** អគ្គនាយករងនៃអគ្គនាយកដ្ឋាននគរបាលជាតិ

៣-លោក **សខ្វារ ជីឡូម៉េស** អគ្គាធិការរងនៃអគ្គាធិការដ្ឋានកិច្ចការនយោបាយរដ្ឋបាល និង នគរបាល

៤-លោក **រស់ សារ៉ី** អគ្គាធិការរងនៃអគ្គាធិការដ្ឋានកិច្ចការនយោបាយរដ្ឋបាល និង នគរបាល

៥-លោក **ឈឹម ជួន** ប្រធាននាយកដ្ឋានកណ្តាលមធ្យោបាយ

៦-លោក **យូ ស៊ុនឡុង** ទីប្រឹក្សាសម្តេចនាយករដ្ឋមន្ត្រីទី ២ និង ជាប្រធាននាយកដ្ឋានកណ្តាលសន្តិសុខ

៧-លោក **ឈុយ សាខុន** ប្រធាននាយកដ្ឋានកណ្តាលនគរបាលយុត្តិធម៌

៨-លោក **ឈុម ស៊ុណន** ប្រធាននាយកដ្ឋានកណ្តាលសណ្តាប់ធ្នាប់សាធារណៈ

៩-លោក **គឹម អាន់** ប្រធាននាយកដ្ឋានកណ្តាលនគរបាលព្រំដែន

មាត្រា ៣ : ត្រូវបានបំពាក់ឋានន្តរសក្តិថ្នាក់ ឧត្តមសេនីយ៍ត្រី ជូនអស់លោកនាយនគរបាលជាតិដូចមានរាយនាមខាងក្រោម ÷

១-លោក **ហ៊ុល សម្លា** អនុប្រធានទី ១ នាយកដ្ឋានកណ្តាលមធ្យោបាយ

២-លោក **ចាន់ អ៊ាន** អនុប្រធានទី១ នាយកដ្ឋានកណ្តាលនគរបាលព្រំដែន

៣-លោក **យុន ឈុន្នី** អនុប្រធានទី ១ នា[illegible]យក[illegible]លសណ្តាប់ធ្នាប់សាធារណៈ

៤–លោក ម៉ៅ ចំនួនតារា អនុប្រធានទី ១ នាយកដ្ឋានកណ្ដាលនគរបាលយុត្តិធម៌

៥–លោក ហង់ យុទ្ធ អនុប្រធានទី ១ នាយកដ្ឋានកណ្ដាលសន្តិសុខ

៦–លោក ឌុល គឿន អនុប្រធាននាយកដ្ឋានកណ្ដាលមធ្យោបាយ

៧–លោក ឈុម ឈាត អនុប្រធាននាយកដ្ឋានកណ្ដាលមធ្យោបាយ

៨–លោក ស៊ីន្ត គីរី អនុប្រធាននាយកដ្ឋានកណ្ដាលនគរបាលព្រំដែន

៩–លោក ពត ឃួច អនុប្រធាននាយកដ្ឋានកណ្ដាលនគរបាលព្រំដែន

១០–លោក ហ៊ីង ឆន អនុប្រធាននាយកដ្ឋានកណ្ដាលសណ្ដាប់ធ្នាប់សាធារណៈ

១១–លោក រស់ ចន្ថា អនុប្រធាននាយកដ្ឋានកណ្ដាលសណ្ដាប់ធ្នាប់សាធារណៈ

១២–លោក ថន អ៊ឹម អនុប្រធាននាយកដ្ឋានកណ្ដាលនគរបាលយុត្តិធម៌

១៣–លោក ចន្ទ ឫទ្ធី អនុប្រធាននាយកដ្ឋានកណ្ដាលនគរបាលយុត្តិធម៌

១៤–លោក អ៊ឹក គីមឈេង អនុប្រធាននាយកដ្ឋានកណ្ដាលសន្តិសុខ

១៥–លោក សួន រ័ត្នសារាយ អនុប្រធាននាយកដ្ឋានកណ្ដាលសន្តិសុខ

១៦–លោក ម៉ៅ ប៊ុនណារិន ប្រធាននាយកដ្ឋានបុគ្គលិក

១៧–លោក រ័ត្ន ម៉ែន ប្រធាននាយកដ្ឋានបណ្ដុះបណ្ដាល និង វិក្រឹត្យការ

១៨–លោក ចក់ ឡេង ប្រធាននាយកដ្ឋានភស្តុភារ និង សំភារៈបច្ចេកទេស

១៩–លោក អ៊ុន សាម៉ុន ប្រធានសេនាធិការដ្ឋាន

២០–លោក យិន ស្រ៊ាន ប្រធានអង្គភាពអន្តរាគមន៍

២១–លោក ម៉ែន អ៊ាន ប្រធាននាយកដ្ឋាននគរបាលព្រំដែនគោក

២២–លោក គីម សាង ប្រធាននាយកដ្ឋាននគរបាលព្រំដែនទឹក

២៣–លោក គីត ឈីមហៃ ប្រធាននាយកដ្ឋាននគរបាលបច្ចេកទេសព្រំដែន

២៤-លោក ឃុន សារឿន ប្រធាននាយកដ្ឋានសន្តិសុខសង្គម

២៥-លោក ស៊ីម សុផល ប្រធាននាយកដ្ឋាននគរបាលការពារ

២៦-លោក ហ៊ុយ ហឿន ប្រធាននាយកដ្ឋាននគរបាលរដ្ឋបាល

២៧-លោក ចៅ ឫទ្ធិសក្តិ ប្រធាននាយកដ្ឋានសណ្តាប់ធ្នាប់

២៨-លោក ថោង លឹម ប្រធាននាយកដ្ឋាននគរបាលព្រហ្មទណ្ឌ

២៩-លោក ឈឹម ជាងឿង ប្រធាននាយកដ្ឋាននគរបាលសេដ្ឋកិច្ច

៣០-លោក ម៉ោយ ម៉ាន ប្រធាននាយកដ្ឋាននគរបាលបច្ចេកទេស វិទ្យាសាស្ត្រ

៣១-លោក សុខ ផល ប្រធាននាយកដ្ឋានពត៌មានទូទៅ

៣២-លោក គន្ធ សំអឿន ប្រធាននាយកដ្ឋានប្រឆាំងភេរវកម្ម

៣៣-លោក ឈួ រ៉ាមីន ប្រធាននាយកដ្ឋានជនបរទេស

៣៤-លោក ឈន់ ណេត ប្រធាននាយកដ្ឋានអង្គរក្ស

៣៥-លោក គីម សំណាង ប្រធាននាយកដ្ឋានផែនការសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

៣៦-លោក គួយ យ៉ារី ប្រធាននាយកដ្ឋានវិទ្យុទាក់ទង

៣៧-លោក អ៊ុក សារ៉ូត ប្រធាននាយកដ្ឋានបំភ័ន្តអក្សរ

៣៨-លោក អុន ឈឿន ប្រធាននាយកដ្ឋានផ្សព្វផ្សាយអប់រំ

៣៩-លោក អ៊ុក ប្រណិត ប្រធាននាយកដ្ឋាននីតិកម្ម

៤០-លោក រស់ សារី ប្រធាននាយកដ្ឋានសុខាភិបាល

៤១-លោក អ៊ុម ស៊ា ប្រធាននាយកដ្ឋានស្ថាបនា

៤២-លោក ណា សាំងហ៊ាង ប្រធាននាយកដ្ឋានពន្ធនាគារ

៤៣-លោក ហេង ហាក់ នាយករងខុទ្ទកាល័យ

៤៤-លោក ឆ្លុង គីមឆុន នាយករងខុទ្ទកាល័យ

៤៥-លោក ខិន សុផា ប្រធានការិយាល័យបុគ្គលិក ភស្តុភារ គណនេយ្យ

៤៦-លោក នេត សាវឿន ស្នងការនគរបាលរាជធានីភ្នំពេញ

៤៧-លោក គីម ចាន់នី ប្រធានការិយាល័យនគរបាលអន្តរជាតិ

៤៨-លោក ប្រាក់ សារឹម ប្រធានការិយាល័យទំនាក់ទំនងអន្តរជាតិ

៤៩-លោក ម៉ូ លីជា ប្រធានអង្គភាពប្រឆាំងគ្រឿងញៀន

មាត្រា ៤ : នាយករដ្ឋមន្ត្រីទី ១ និង នាយករដ្ឋមន្ត្រីទី ២ នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តអោយបានសំរេច តាមព្រះរាជក្រឹត្យនេះ ។

មាត្រា ៥ : ព្រះរាជក្រឹត្យនេះចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ , ថ្ងៃទី ០៨ ខែ កញ្ញា ឆ្នាំ ១៩៩៥

ព្រះហស្ថលេខា

នរោត្តម សីហនុ

* * *

ព្រះរាជក្រឹត្យ លេខ នស/រកត/០៩៩៥/៦៨

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ វរ្ម័ន រាជហរិវង្ស

ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍ និករោត្តម

ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១០៩៤/៨៣ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា
- យោងតាមសំណើរបស់នាយករដ្ឋមន្ត្រីទី ១ និង នាយករដ្ឋមន្ត្រីទី ២ នៃរាជរដ្ឋាភិបាលកម្ពុជា

ប្រកាសបង្គាប់

មាត្រា ១ : តែងតាំង លោក **សូរ ផន** ជាអគ្គាធិការនៃអគ្គាធិការដ្ឋានកិច្ចការនយោបាយ រដ្ឋបាល និងនគរបាលនៃក្រសួងមហាផ្ទៃ ជំនួសឯកឧត្តមឧត្តមសេនីយ៍ឯក **យ៉េង ម៉ារ៉ាឌី** ដែលត្រូវចាត់អោយបំពេញមុខងារផ្សេងទៀត ។

មាត្រា ២ : នាយករដ្ឋមន្ត្រីទី ១ និង នាយករដ្ឋមន្ត្រីទី ២ នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ។

មាត្រា ៣ : ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ , ថ្ងៃទី ០៨ ខែ កញ្ញា ឆ្នាំ ១៩៩៥

ព្រះហស្តលេខា

នរោត្តម សីហនុ

* * *

II - ទីស្តីការគណៈរដ្ឋមន្ត្រី

១ - អនុក្រឹត្យ

រាជធានីភ្នំពេញ , ថ្ងៃទី ០១ ខែ កញ្ញា ឆ្នាំ ១៩៩៥

អនុក្រឹត្យ លេខ ១០២ អនក្រ.គគ

ស្តីពីការលុបឈ្មោះចេញពីក្របខ័ណ្ឌរដ្ឋបាល

រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា .

- បានឃើញច្បាប់ ស្ដីពីការរៀបចំ និង ការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- តាមសំណើរបស់សហរដ្ឋមន្ត្រី ក្រសួងមហាផ្ទៃ

សំរេច

មាត្រា ១ : ត្រូវបានលុបឈ្មោះចេញពីក្របខ័ណ្ឌរដ្ឋលោក **ឆែ ឃាន** អភិបាលស្រុកសែនមនោរម្យ ខេត្តមណ្ឌលគីរី ដែលបានទទួលមរណភាព កាលពីថ្ងៃទី ១៣ ខែ កុម្ភៈ ឆ្នាំ ១៩៩៥ ។

មាត្រា ២ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួង សេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ និង ក្រសួងសង្គមកិច្ច និង អតីតយុទ្ធជន ត្រូវអនុវត្តតាមអនុក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្ថលេខា និង ចុះហត្ថលេខាតទៅ ។

នាយករដ្ឋមន្ត្រីទី ១	នាយករដ្ឋមន្ត្រីទី ២
ព្រះហស្ថលេខា និង ត្រា	ហត្ថលេខា និងត្រា
នរោត្តម រណឫទ្ធិ	**ហ៊ុន សែន**

* * *

រាជធានីភ្នំពេញ , ថ្ងៃទី ០៦ ខែ កញ្ញា ឆ្នាំ ១៩៩៥

អនុក្រឹត្យ លេខ ១០៣ អនក្រ

ស្ដីពី

ការបំពាក់ឋានន្តរសក្តិជូននាយនគរបាលជាតិ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណា ព្រះបាទសម្ដេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

- បានឃើញច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ដែល ប្រកាសអោយប្រើតាមព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- បានឃើញក្រឹត្យ ចុះថ្ងៃទី ១៩ ខែ តុលា ឆ្នាំ ១៩៩៣ ស្តីពីការរៀបចំសញ្ញា និង រូបភាពឋានន្តរសក្តិនគរបាលជាតិកម្ពុជា
- យោងសំណើរបស់សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

សំរេច

មាត្រា ១ ត្រូវបានបំពាក់ឋានន្តរសក្តិថ្នាក់ វរៈសេនីយ៍ឯក ជូនអស់លោកនាយនគរបាល ជាតិ ដូចមានរាយនាមខាងក្រោមនេះ :

១–លោក ម៉ៅ មុន្នី		អនុប្រធានទី ១ នាយកដ្ឋានបុគ្គលិក
២–លោក យុន ឈៃយ៉ា		អនុប្រធានទី ១ នាយកដ្ឋានបណ្តុះបណ្តាល និង វិក្រឹត្យការ
៣–លោក យក់ ហុង		អនុប្រធានទី ១ នាយកដ្ឋានភស្តុភារ និង សំភារៈបច្ចេកទេស
៤–លោក សុខ សួស្តី		អនុប្រធានទី ១ សេនាធិការដ្ឋាន
៥–លោក សេខ សាន្តផល្លី		អនុប្រធានទី ១ អង្គភាពអន្តរាគមន៍
៦–លោក ជ័យ មុន្និដា		អនុប្រធានទី១ នាយកដ្ឋាននគរបាលព្រំដែនគោក
៧–លោក ទិម ចំរើន		អនុប្រធានទី១ នាយកដ្ឋាននគរបាលព្រំដែនទឹក
៨–លោក យិន សុវណ្ណ		អនុប្រធានទី ១ នាយកដ្ឋានបច្ចេកទេសព្រំដែន
៩–លោក ម៉ាន់ ណារី		អនុប្រធានទី ១ នាយកដ្ឋានសន្តិសុខសង្គម
១០–លោក ឌូ ខន		អនុប្រធានទី ១ នាយកដ្ឋានសណ្តាប់ធ្នាប់
១១–លោក ទែស ម៉ារ៉ា		អនុប្រធានទី១ នាយកដ្ឋាននគរបាលព្រហ្មទណ្ឌ
១២–លោក ម៉ា ឈឿន		អនុប្រធានទី ១ នាយកដ្ឋាននគរបាលសេដ្ឋកិច្ច
១៣–លោក ជា ផាន់ឌី		អនុប្រធានទី១ នាយកដ្ឋាននគរបាលបច្ចេកទេស វិទ្យាសាស្ត្រ
១៤–លោក ជួន ស៊ីទុទ្ធ		អនុប្រធានទី ១ នាយកដ្ឋានពត៌មានទូទៅ

១៦-លោក ហេង សំណាង អនុប្រធានទី ១ នាយកដ្ឋានប្រឆាំងភេរវកម្ម

១៧-លោក ពេជ្រ តាសនា អនុប្រធានទី ១ នាយកដ្ឋានជនបរទេស

១៨-លោក ហង្ស វិបុលបញ្ញា អនុប្រធានទី ១ នាយកដ្ឋានអង្គរក្ស

១៩-លោក ជា ផលធិរៈ អនុប្រធានទី ១ នាយកដ្ឋានផែនការ សេដ្ឋកិច្ច និងហិរញ្ញវត្ថុ

២០-លោក ឆូ ឫស អនុប្រធានទី ១ នាយកដ្ឋានវិទ្យុទាក់ទង

២១-លោក កែច ជួប អនុប្រធានទី ១ នាយកដ្ឋានបំពាក់អាវុធ

២២-លោក សួន គល់ អនុប្រធានទី ១ នាយកដ្ឋានផ្សព្វផ្សាយអប់រំ

២៣-លោក កែន គុន អនុប្រធានទី ១ នាយកដ្ឋានសុខាភិបាល

២៤-លោក យ៉ាច សុធា អនុប្រធានទី ១ នាយកដ្ឋានស្ថាបនា

២៥-លោក ឡាំ ប៊ុនថា អនុប្រធានទី ១ ការិយាល័យនគរបាលអន្តរជាតិ

២៦-លោក កែច កុសល អនុប្រធានទី ១ អង្គភាពប្រឆាំងគ្រឿងញៀន

២៧-លោក មុំ សាមាន ស្នងការនគរបាលខេត្តកណ្តាល

២៨-លោក ពេជ្រ ជីវ័ន ស្នងការនគរបាលខេត្តព្រៃវែង

២៩-លោក ឡុង ពេជ្ររតនៈ ស្នងការនគរបាលខេត្តស្វាយរៀង

៣០-លោក សួន ឈានលី ស្នងការនគរបាលខេត្តកំពង់ចាម

៣១-លោក ស៊ីន សំឡ ស្នងការនគរបាលខេត្តកំពង់ធំ

៣២-លោក សត ណារី ស្នងការនគរបាលខេត្តសៀមរាប

៣៣-លោក សុខ សារ៉េត ស្នងការនគរបាលខេត្តបន្ទាយមានជ័យ

៣៤-លោក ទីន ឈុនលី ស្នងការនគរបាលខេត្តបាត់ដំបង

៣៥-លោក យិន ខាងហៃ ស្នងការនគរបាលខេត្តពោធិសាត់

៣៦-លោក សុទ្ធ សាត ស្នងការនគរបាលខេត្តកំពង់ឆ្នាំង

៣៧-លោក ណុប វឿន ស្នងការនគរបាលខេត្តកំពង់ស្ពឺ

៣៨-លោក សេង សុគន្ធ ស្នងការនគរបាលខេត្តកំពត

៣៩–លោក ឡេង ហ៊ា ស្នងការនគរបាលខេត្តតាកែវ
៤០–លោក ម៉ែម ឡឿង ស្នងការនគរបាលខេត្តកោះកុង
៤១–លោក ចាន់ គីមសេង ស្នងការនគរបាលខេត្តស្ទឹងត្រែង
៤២–លោក ខាំ ខឿន ស្នងការនគរបាលខេត្តរតនគីរី
៤៣–លោក ចាន់ យឿន ស្នងការនគរបាលខេត្តមណ្ឌលគីរី
៤៤–លោក ស៊ីន សុផាត ស្នងការនគរបាលខេត្តក្រចេះ
៤៥–លោក ឡុង សារឿន ស្នងការនគរបាលខេត្តព្រះវិហារ
៤៦–លោក ឯម ប៊ុនសាត ស្នងការនគរបាលក្រុងព្រះសីហនុ
៤៧–លោក អ៊ី ហៃ ស្នងការនគរបាលក្រុងកែប
៤៨–លោក យ៉េត វ៉ាចក្រាត់ ស្នងការរងទី ១ នៃស្នងការដ្ឋាននគរបាលរាជធានីភ្នំពេញ

មាត្រា ២ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងនិង ប្រធានស្ថាប័នពាក់ព័ន្ធ និង អស់លោកដែលមានឈ្មោះ ដូចក្នុងមាត្រា ១ ត្រូវអនុវត្តតាមអនុក្រឹត្យនេះ ចាប់ពីថ្ងៃឡាយហស្តលេខា និង ចុះហត្ថលេខាតទៅ ។

នាយករដ្ឋមន្ត្រីទី ១
ព្រះហស្តលេខា និង ត្រា
នរោត្តម រណឫទ្ធិ

នាយករដ្ឋមន្ត្រីទី ២
ហត្ថលេខា និងត្រា
ហ៊ុន សែន

* * *

រាជធានីភ្នំពេញ , ថ្ងៃទី ០៦ ខែ កញ្ញា ឆ្នាំ ១៩៩៥

អនុក្រឹត្យ លេខ ១០៤ អនក្រ

ស្ដីពី

ការបំពាក់ថ្នាក់ងារសក្ដិជូននាយនគរបាលជាតិ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ របស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើតាមព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- បានឃើញក្រឹត្យ ចុះថ្ងៃទី ១៩ ខែ តុលា ឆ្នាំ ១៩៩៣ ស្តីពីការរៀបចំសញ្ញា និង រូបភាពឋានន្តរសក្តិនគរបាលជាតិកម្ពុជា
- យោងសំណើរបស់សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

សំរេច

មាត្រា ១ : ត្រូវបានបំពាក់ឋានន្តរសក្តិថ្នាក់ វរៈសេនីយ៍ឯក ជូនអស់លោកនាយ នគរបាល ជាតិ ដូចមានរាយនាមខាងក្រោមនេះ :

១-លោក **ញឹម**	**គីមញៀល**	ជំនួយការឯកឧត្តមរដ្ឋមន្ត្រី
២-លោក **ឡៅ**	**ស៊ុនប៉ា**	ទីប្រឹក្សាឯកឧត្តមរដ្ឋលេខាធិការ
៣-លោក **ស៊ន**	**សុខណា**	ជំនួយការឯកឧត្តមរដ្ឋលេខាធិការ
៤-លោក **ម៉ុន**	**សុខណ្ណ**	ជំនួយការឯកឧត្តមរដ្ឋលេខាធិការ
៥-លោក **កៅ**	**យុនសារ៉េត**	ទីប្រឹក្សាឯកឧត្តមរដ្ឋលេខាធិការ
៦-លោក **ឌិន**	**ទ៉ាន់ដេន**	ជំនួយការឯកឧត្តមរដ្ឋលេខាធិការ
៧-លោក **ឆូច**	**លន់**	ជំនួយការឯកឧត្តមរដ្ឋលេខាធិការ
៨-លោក **យ៉េន**	**ឈយានលី**	ទីប្រឹក្សាឯកឧត្តមរដ្ឋលេខាធិការ
៩-លោក **សួស**	**អេង្គារ៉**	ជំនួយការឯកឧត្តមរដ្ឋលេខាធិការ
១០-លោក **សួន**	**គីមស្រ៊ន**	ជំនួយការឯកឧត្តមរដ្ឋលេខាធិការ
១១-លោក **ម៉ៅម**	**សាម៉ុខ**	ជំនួយការឯកឧត្តមរដ្ឋលេខាធិការ
១២-លោក **ខ្មៅ**	**សំឡុត**	ជំនួយការឯកឧត្តមរដ្ឋលេខាធិការ
១៣-លោក **រស់**	**សំអុល**	ជំនួយការឯកឧត្តមរដ្ឋលេខាធិការ

១៤-លោក **សួង ឆាសេនា** ជំនួយការឯកឧត្តមរដ្ឋលេខាធិការ

មាត្រា ២ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងនិង ប្រធានស្ថាប័នពាក់ព័ន្ធ និងអស់លោកដែលមានឈ្មោះដូច ក្នុងមាត្រា ១ ត្រូវអនុវត្តតាមអនុក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខា និង ចុះហត្ថលេខាតទៅ ។

នាយករដ្ឋមន្ត្រីទី ១ នាយករដ្ឋមន្ត្រីទី ២
ព្រះហស្តលេខា និង ត្រា ហត្ថលេខា និងត្រា
នរោត្តម រណឫទ្ធិ **ហ៊ុន សែន**

* * *

២ - សេចក្តីសំរេច

រាជធានីភ្នំពេញ ,ថ្ងៃទី ០២ ខែ កញ្ញា ឆ្នាំ ១៩៩៥

សេចក្តីសំរេច លេខ ៦២ សសរ

ស្តីពីការប្រគល់ភារកិច្ចបណ្តោះអាសន្ន

* * *

រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- ផ្អែកតាមការចំបាច់

សំរេច

ប្រការ ១ : ប្រគល់ភារកិច្ចជូនឯកឧត្តម **នូច ឆានុន** រដ្ឋលេខាធិការទទួលបន្ទុកទីស្តី ការគណៈរដ្ឋមន្ត្រី ជារដ្ឋមន្ត្រីស្តីទី ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ចាប់ពីថ្ងៃទី ២៥ ខែ សីហា ឆ្នាំ ១៩៩៥ រហូតដល់ថ្ងៃឯកឧត្តម ពូ សុធិរៈ

ត្រឡប់មកពីបំពេញបេសកកម្មនៅទីក្រុងប៉ារីសវិញ ។

ប្រការ ២ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួងរដ្ឋលេខាធិការ អនុរដ្ឋលេខាធិការគ្រប់រដ្ឋលេខាធិការដ្ឋាន និង ឯកឧត្តម **ឌូច គាឌួន** ត្រូវទទួល អនុវត្តសេចក្តីសំរេច ចាប់ពីថ្ងៃឡាយព្រះហស្ថលេខា និង ចុះហត្ថលេខាតទៅ ។

នាយករដ្ឋមន្ត្រីទី ១	នាយករដ្ឋមន្ត្រីទី ២
ព្រះហស្ថលេខា និង ត្រា	ហត្ថលេខា និងត្រា
នរោត្តម រណឫទ្ធិ	**ហ៊ុន សែន**

* * *

រាជធានីភ្នំពេញ ,ថ្ងៃទី ០៤ ខែ កញ្ញា ឆ្នាំ ១៩៩៥

សេចក្តីសំរេច លេខ : ៦៣ សសរ

ស្តីពីការបង្កើតគណៈកម្មាធិការពិនិត្យទាយតំលៃ

ការគសញ្ញាបត្រ និង លិខិតបញ្ជាក់ការសិក្សា

* * *

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា

– តាមសំណើរបស់រដ្ឋមន្ត្រី ក្រសួងអប់រំយុវជន និង កីឡា

សម្រេច

ប្រការ ១ : បង្កើតគណៈកម្មាធិការចំរុះមួយដែលមានឈ្មោះ « គណៈកម្មាធិការពិនិត្យវាយតំលៃគីរិតសញ្ញាប័ត្រ និង លិខិតបញ្ជាក់ការសិក្សា » ដែលមានសមាសភាពដូចខាងក្រោម :

១–ឯកឧត្តម ឡូ ដារ៉ាន់ អនុរដ្ឋលេខាធិការក្រសួងអប់រំយុវជន និង កីឡា — ប្រធាន

២–លោក ប្រធាននាយកដ្ឋានឧត្តមសិក្សា និង សិក្សាឯកទេស — អនុប្រធាន

៣–លោក តំណាងទីស្តីការគណៈរដ្ឋមន្ត្រី — សមាជិក

៤–លោក តំណាងរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ — សមាជិក

៥–លោក តំណាងក្រសួងសុខាភិបាល — សមាជិក

៦–លោក ប្រធាននាយកដ្ឋានបំណិនទូទៅ និង មធ្យមសិក្សា — សមាជិក

ប្រការ ២ : គណៈកម្មាធិការនេះមានភារកិច្ច វាយតំលៃគីរិតសញ្ញាប័ត្រ និង លិខិតបញ្ជាក់ការសិក្សាក្នុង និង ក្រៅប្រទេស តាមសំណើសុំវាយតំលៃពីបណ្តាស្ថាប័ន នានាទូទាំងប្រទេស ។

– កសាងលក្ខណៈវិនិច្ឆ័យសំរាប់វាយតំលៃគីរិតសញ្ញាប័ត្រ និង លិខិតបញ្ជាក់ការសិក្សាក្នុង និង ក្រៅប្រទេស ។

ប្រការ ៣ : គណៈកម្មាធិការនេះមានទីស្នាក់ការក្នុងក្រសួងអប់រំយុវជន និង កីឡា និង មានសិទ្ធិប្រើប្រាស់ត្រាដើម្បីសំរួលការងារ ។

ប្រការ ៤ : សមាជិកគណៈកម្មាធិការនេះ ត្រូវចូលរួមប្រជុំការងារតាមការអញ្ជើញរបស់ប្រធាន ។ ក្នុងពេលប្រជុំវាយតំលៃគីរិតសញ្ញាប័ត្រ និងលិខិតបញ្ជាក់ការសិក្សា ក្រសួង ឬ ស្ថាប័ន ដែលមានការពាក់ព័ន្ធ នឹងចាត់តំណាងជួយបំភ្លឺ និងផ្តល់ព័ត៌មានដែលចាំបាច់បន្ថែម ។

ប្រការ ៥ : គណៈកម្មាធិការនេះមានសិទ្ធិបង្កើតក្រុមជំនួយការមួយក្រុម ដើម្បីធ្វើជាលេខាធិការ ។

ប្រការ ៦ : សេចក្តីសំរេចលេខ ០៨ សសរ ចុះថ្ងៃទី ១០ ខែ កុម្ភៈ ឆ្នាំ ១៩៩២ របស់ក្រុមប្រឹក្សារដ្ឋមន្ត្រីនិង បទបញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយ នឹងបទបញ្ញត្តិនៃសេចក្តីសំរេចនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

ប្រការ ៧ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំយុវជន និង កីឡា រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការនៃក្រសួងស្ថាប័នពាក់ព័ន្ធ និង ឯកឧត្តម អស់លោកដែលមានរាយនាមក្នុងប្រការ ១ មានភារកិច្ចអនុវត្តសេចក្តីសំរេចនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខា និង ចុះហត្ថលេខាតទៅ ។

នាយករដ្ឋមន្ត្រីទី ១	នាយករដ្ឋមន្ត្រីទី ២
ព្រះហស្តលេខា និង ត្រា	ហត្ថលេខា និងត្រា
នរោត្តម រណឫទ្ធិ	**ហ៊ុន សែន**

* * *

រាជធានីភ្នំពេញ , ថ្ងៃទី ០៦ ខែ កញ្ញា ឆ្នាំ ១៩៩៥

សេចក្តីសំរេច លេខ ៦៤ សសរ

ស្តីពីការផ្ទេរសិទ្ធិ

* * *

រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ ១ស.រកត ១០៩៤/៨៣ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការសំរួលសមាសភាពរាជរដ្ឋាភិបាល
- បានឃើញច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤

- តាមសំណូមពរការងារចាំបាច់

សំរេច

ប្រការ ១ : ត្រូវបានផ្ទេរសិទ្ធិជូនឯកឧត្តម **សុខ អាន** សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រីជាអគ្គទេសាភិបាលស្តីទី នៃធនាគារជាតិកម្ពុជា ជំនួសឯកឧត្តម **ថៅ ប៊ើនឈាត** ដែលជាប់អញ្ជើញទៅបំពេញបេសកកម្មនៅបរទេសចាប់ពីថ្ងៃទី ០៤ ខែ កញ្ញា ឆ្នាំ ១៩៩៥ រហូតដល់ឯកឧត្តមបញ្ចប់បេសកកម្ម ។

ប្រការ ២ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីគ្រប់ក្រសួង រដ្ឋលេខាធិការគ្រប់រដ្ឋលេខាធិការដ្ឋាន និង ឯកឧត្តម ដែលមានឈ្មោះក្នុងប្រការ ១ ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសំរេចនេះតាមភារកិច្ចរៀង ។ ខ្លួន ចាប់ពីថ្ងៃឡាយព្រះហស្តលេខា និង ចុះហត្ថលេខានេះតទៅ ។

នាយករដ្ឋមន្ត្រីទី ១	នាយករដ្ឋមន្ត្រីទី ២
ព្រះហស្តលេខា និង ត្រា	ហត្ថលេខា និងត្រា
នរោត្តម រណឫទ្ធិ	**ហ៊ុន សែន**

* * *

III - ការងារបណ្តាក្រសួង

១- ទីស្តីការរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

ប្រកាស

រាជធានីភ្នំពេញ , ថ្ងៃទី ០២ ខែ កញ្ញា ឆ្នាំ ១៩៩៥

ប្រកាស លេខ ៣១៥ ប្រក.សហវ.ខ

ស្តីពី

ការបង្កើតគណៈកម្មការរៀបចំ កសាង

សេចក្តីព្រាងច្បាប់ ស្តីពីហិរញ្ញវត្ថុ សំរាប់គ្រប់គ្រងឆ្នាំ ១៩៩៦

សេចក្ដីសម្រេច

រដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

- បានឃើញ រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រឹត្យរបស់ព្រះបាទសម្ដេចព្រះ **នរោត្ដម សីហនុ វរ្ម័ន** ព្រះមហាក្សត្រ នៃ ព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល
- បានឃើញ ច្បាប់ស្ដីពីការរៀបចំ និង ការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើ ដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- បានឃើញ ព្រះរាជក្រឹត្យ លេខ នស.រកត ១០៩៤-៨៣ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ ស្ដីពីការកែសម្រួលសមាសភាព រាជរដ្ឋាភិបាល
- ព្រះរាជក្រម លេខ ០១ ន.ស ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣ ប្រកាសអោយប្រើច្បាប់ស្ដីពី ប្រព័ន្ធហិរញ្ញវត្ថុ
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

សម្រេច

ប្រការ ១ : បង្កើតគណៈកម្មការមួយ មានឈ្មោះថា «គណៈកម្មការរៀបចំកសាងសេចក្ដីព្រាងច្បាប់ស្ដីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ ១៩៩៦ » ដែលមានសមាសភាពដូចតទៅ ÷

- ឯកឧត្ដម **នាយ ចិន** អនុរដ្ឋលេខាធិការ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សហប្រធាន
- ឯកឧត្ដម **ខាវ ម៉េងឈាង** អនុរដ្ឋលេខាធិការ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សហប្រធាន
- លោក **សារ៉ាត់ ខាន់** អគ្គនាយក នាយកខុទ្ទកាល័យ ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ អនុប្រធាន
- លោក **ឡោត់ ឡេង** ប្រធានមន្ទីរ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សមាជិក

- លោក **សាម ប៊ុនហេង** ប្រធាននាយកដ្ឋានហិរញ្ញកិច្ច នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ — សមាជិក
- លោក **ឌួច ឡេង** ប្រធាននាយកដ្ឋានថវិកា នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ — លេខាធិការ
- លោក **ហុង ចាវ** ប្រធាននាយកដ្ឋានពន្ធដារ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ — សមាជិក
- លោក **ទូ គឹមឡេង** ប្រធាននាយកដ្ឋានហិរញ្ញវត្ថុក្រៅប្រទេស នៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ — សមាជិក
- លោក **ខិន យន** ប្រធានធនាគារជាតិ — សមាជិក
- លោក **សៀង ឈុនឡី** នាយករងទីចាត់ការគយនិងរដ្ឋាករ — សមាជិក
- លោក **ពាន់ សារខំណន** អនុប្រធាននាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ — សមាជិក

ប្រការ ២ : គណៈកម្មការនេះមានភារកិច្ច ដូចតទៅ :

- កសាងប្រតិទិនសំរាប់រៀបចំ សេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រង ឆ្នាំ ១៩៩៦ និងកម្មវិធីការងារអោយបានច្បាស់លាស់ ផ្អែកតាមច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុ
- សហការជាមួយបណ្តាក្រសួង–ស្ថាប័ន ខេត្ត–ក្រុង ដែលពាក់ព័ន្ធព្រមទាំងជាមួយអ្នក ជំនាញការ ដើម្បីរៀបចំសេចក្តីព្រាងច្បាប់ ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ ១៩៩៦ អោយបានទាន់ពេលវេលាកំណត់ក្នុងប្រតិទិនការងារ
- រាយការណ៍សុំសេចក្តីសំរេចពីទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី និង ឯកឧត្តមរដ្ឋលេខាធិការ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ លើលទ្ធផលការងារ និង សុំយោបល់ដោះស្រាយគ្រប់បញ្ហាដែលមានការពាក់ព័ន្ធទៅនឹងការរៀបចំ សេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការ គ្រប់គ្រងឆ្នាំ ១៩៩៦ ។

ប្រការ ៣ : សមាជិកទាំងអស់របស់គណៈកម្មការ ត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់សហប្រធានណាមួយ នៃគណៈកម្មការ ។ ក្នុងពេលសហប្រធានអវត្តមាន អនុប្រធានគណៈកម្មការជាអ្នកទទួលខុស ត្រូវការងារជំនួស ។

ក្នុងករណីចាំបាច់ ប្រធានគណៈកម្មការមានសិទ្ធិអញ្ជើញមន្ត្រី អ្នកជំនាញគ្រប់នាយកដ្ឋាន គ្រប់អង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ អោយមកចូលរួមធ្វើការងារ តាម ជាក់ស្តែង ។

ប្រការ ៤ : ឯកឧត្តម អស់លោក ដូចមានរាយនាមក្នុងប្រការ ១ និង អស់លោកប្រធាន អនុប្រធានគ្រប់ នាយកដ្ឋាន គ្រប់អង្គភាព ក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវទទួលអនុវត្តតាម ប្រកាសនេះអោយមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ទេសរដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

ហត្ថលេខានិងត្រា

គាត ឈន់

* * *

រាជធានីភ្នំពេញ , ថ្ងៃទី ០២ ខែ កញ្ញា ឆ្នាំ ១៩៩៥

ប្រកាស លេខ ៣១៦ ប្រក.សហវ.៣៥

ស្តីពី

ការតែងតាំងសមាសភាព

គណៈកម្មការទាយតម្លៃដីមិនបានប្រើប្រាស់

* * * *

ទេសរដ្ឋមន្ត្រី

រដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

- បានឃើញ រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រ នៃ ព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

- បានឃើញ ច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើ ដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- បានឃើញ ព្រះរាជក្រឹត្យ លេខ នស.រកត ១០៩៤-៨៣ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសម្រួលសមាសភាព រាជរដ្ឋាភិបាល
- បានឃើញច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ ១៩៩៥ ដែលប្រកាសអោយប្រើដោយព្រះ រាជក្រមលេខ ១១ នស.៩៤ ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៩៤
- បានឃើញអនុក្រឹត្យលេខ ៥៨ អនក្រ ចុះថ្ងៃទី ២៥ ខែ កក្កដា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតគណៈ កម្មការវាយតម្លៃដីមិនបានប្រើប្រាស់

សំរេច

ប្រការ ១ : តែងតាំង :

- ឯកឧត្តម **ជា ម៉េងឈាង** អនុរដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ប្រធាន
- លោក **ស៊ីម គង់** នាយកខុទ្ទកាល័យទេសរដ្ឋមន្ត្រីទទួលបន្ទុកវប្បធម៌ វិចិត្រសិល្បៈ រៀបចំទឹកដីនគរូបនីយកម្ម និង សំណង់ អនុប្រធាន
- លោក **ចាន់ ស៊ី** អនុប្រធាននាយកដ្ឋានពន្ធដារ សមាជិក
- លោក **កាំង ឈាងម៉ុណា** អនុប្រធាននាយកដ្ឋានទ្រព្យរដ្ឋ សមាជិក
- លោក **ហាស់ សុខ** អនុប្រធាននាយកដ្ឋានក្បួនស្រាស្រ្ត សមាជិក
- លោក **សៀក ចន្ថា** អនុប្រធាននាយកដ្ឋានសុរិយោដី សមាជិក
- លោក **ជុំ ចន្ធី** អនុប្រធានការិយាល័យបច្ចេកទេស នាយកដ្ឋានពន្ធដារ សមាជិកទទួលបន្ទុកបូកសរុប

ប្រការ ២ : សមាជិកគណៈកម្មការនេះអនុវត្តភារកិច្ច និងមានសិទ្ធិដូចបានចែងក្នុងមាត្រា២ មាត្រា ៣ និង មាត្រា៤ នៃអនុក្រឹត្យលេខ ៥៨ អនក្រ ចុះថ្ងៃទី ២៥ ខែ កក្កដា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត គណៈកម្មការវាយតម្លៃដីមិនបានប្រើប្រាស់ ។

ប្រការ ៣ : ឯកឧត្តម អស់លោក ដូចមានរាយនាមក្នុងប្រការ ១ និង គ្រប់អង្គភាព នាយកដ្ឋានក្រោមឱវាទ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវទទួលបន្ទុកអនុវត្ត ប្រកាសនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ទេសរដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

ហត្ថលេខានិងត្រា

គាត ឈន់

* * *

រាជធានីភ្នំពេញ , ថ្ងៃទី ០៦ ខែ កញ្ញា ឆ្នាំ ១៩៩៥

ប្រកាស ១២១ សហវ.ប្រក.ប

ស្តីពី

ការបញ្ជូនលោក ហ៊ុន តិរម្យ អោយទៅក្រសួងដើមវិញ

* * * *

ទេសរដ្ឋមន្ត្រី

រដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

- បានឃើញ រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំង រាជរដ្ឋាភិបាល កម្ពុជា
- បានឃើញ ច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រីដែល ប្រកាសអោយប្រើ ដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- បានឃើញព្រះរាជក្រឹត្យ នស.រកត ១០៩៤-៨៣ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការ កែសំរួល សមាសភាពរាជរដ្ឋាភិបាល
- បានឃើញ ប្រកាសលេខ ៣០០០ ប្រក.សកប ចុះថ្ងៃទី ១៧ ខែ តុលា ឆ្នាំ ១៩៩៤ របស់ក្រសួង សាធារណការដឹកជញ្ជូន ស្តីពីការផ្ទេរមន្ត្រីរាជការ

- បានឃើញ ប្រកាសលេខ ២៩៨ ប្រក. សហវ. ប ចុះថ្ងៃទី ១៧ ខែ តុលា ឆ្នាំ ១៩៩៤ របស់ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ស្តីពីការទទួលស្គាល់ លោក ហ៊ីង ភិរម្យ អោយបំរើការងារនៅទី ចាត់ការគយ និង រដ្ឋាករ
- ផ្អែកតាមស្ថិតិលេខ ៣៨៧ សមក្រខ ចុះថ្ងៃទី ១៥ ខែ មិថុនា ឆ្នាំ ១៩៩៥ ស្តីពី អង្គភាព និង ក្របខ័ណ្ឌរបស់អង្គភាពម្ចាស់ការហិរញ្ញវត្ថុ និង ស្វយ័តភិបាល សេដ្ឋកិច្ច របស់រដ្ឋលេខាធិការដ្ឋាន មុខងារសាធារណៈ
- ផ្អែកតាមទិដ្ឋាការលេខ ៦៤៥ មសណ ចុះថ្ងៃទី ២៣ ខែ មេសា ឆ្នាំ ១៩៩៥ របស់រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ លើតារាងប្រៀបធៀបមុខចំណាយ បៀវត្សរ៍ និង ប្រាក់ឧបត្ថម្ភផ្សេងៗ សំរាប់ខែ ឧសភា ឆ្នាំ ១៩៩៥ របស់ទីចាត់ការគយ និង រដ្ឋាករ

សំរេច

មាត្រា ១ : បញ្ជូនលោក ហ៊ីង ភិរម្យ អតីតបុគ្គលិកនាយកដ្ឋានភ្នាក់ងារកម្ពុជានាវាចរណ៍ «កាំសាប» នៃក្រសួងសាធារណការ និងដឹកជញ្ជូនអោយត្រឡប់ទៅ បំរើការងារនៅអង្គភាពដើមវិញ ដោយសាមីជន ស្ថិតក្នុងក្របខ័ណ្ឌអង្គភាពស្វយ័តភិបាលសេដ្ឋកិច្ច ។

មាត្រា ២ : ប្រាក់បៀវត្សរ៍ និង ប្រាក់ឧបត្ថម្ភផ្សេងៗ របស់សាមីខ្លួន ត្រូវបើកនៅអង្គភាពដើមវិញ តាមវិញ្ញាបនប័ត្រផ្តាច់ប្រាក់របស់លោក ហ៊ីង ភិរម្យ ចុះថ្ងៃទី ២០ ខែ តុលា ឆ្នាំ ១៩៩៤ ។

មាត្រា ៣ : នាយកខុទ្ទកាល័យ ប្រធានមន្ទីរ ប្រធាននាយកដ្ឋានបុគ្គលិក ទីចាត់ការគយ និង រដ្ឋាករ និង អង្គភាពពាក់ព័ន្ធ ព្រមទាំងសាមីខ្លួន ដូចក្នុងមាត្រា១ខាងលើ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះ។

ទេសរដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

[illegible]

គាត ឈន់

រាជធានីភ្នំពេញ , ថ្ងៃទី ០៦ ខែ កញ្ញា ឆ្នាំ ១៩៩៥

សេចក្តីសំរេច លេខ ១២៣ សហវ.សបក.ម

ស្តីពី

ការចាត់តាំងភារកិច្ចមន្ត្រីរាជការចូលរួមក្នុងសមាសភាព

ក្រុមការងារ នៃគណៈកម្មការត្រួតពិនិត្យគោលនយោបាយ

ចំពោះ ជនពលី ពិការ

* * * *

ទេសរដ្ឋមន្ត្រី

រដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

- បានឃើញ រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញ ច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយ ព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- បានឃើញ ព្រះរាជក្រឹត្យ លេខ នស.រកក ១០៩៤-៨៣ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការ កែសម្រួលសមាសភាព រាជរដ្ឋាភិបាល
- បានឃើញសេចក្តីសំរេចលេខ ៥៣ សសរ ចុះថ្ងៃទី ២៥ ខែ កក្កដា ឆ្នាំ ១៩៩៥ របស់រាជរដ្ឋាភិបាលកម្ពុជា ស្តីពីការបង្កើតគណៈកម្មការត្រួតពិនិត្យគោលនយោបាយចំពោះ ជនពលី ពិការ

ចាត់តាំងភារកិច្ចមន្ត្រីរាជការចូលរួមក្នុងសមាសភាពក្រុមការងារសំរាប់ជំនួយការងារនៃគណៈ កម្មការត្រួតពិនិត្យគោលនយោបាយ ចំពោះ ជនពលីពិការ រួមមានដូចខាងក្រោម ÷

ក - សមាសភាពចូលរួមការងារ :

+ លោក ម៉ម ឆិន អនុគណៈកម្មាធិការអធិការកិច្ចហិរញ្ញវត្ថុ ជាអនុប្រធានក្រុមការងារ

ខ - សមាសភាពចូលរួមក្នុងជំនួយក្រុមការងារ :

១–លោក សែន ឆាយ ឋានៈប្រធាននាយកដ្ឋាន

២–លោក ហេង គីមអេង ឋានៈអនុប្រធាននាយកដ្ឋាន

៣–លោក សាន់ សារ៉េ ឋានៈអនុប្រធាននាយកដ្ឋាន

៤–លោក ម៉ែន ឃួន ឋានៈអនុប្រធាននាយកដ្ឋាន

៥–លោកស្រី ស៊ុច គីមស៊ាន ឋានៈអនុប្រធាននាយកដ្ឋាន

៦–លោក ឈឹម ប៊ុនហៃ ឋានៈអនុប្រធាននាយកដ្ឋាន

៧–លោក ចាន់ ណារិទ្ធ ឋានៈប្រធានការិយាល័យ

៨–លោក សុខ យ៉ាន ឋានៈប្រធានការិយាល័យ

៩–លោកស្រី គួយ ឡាង ឋានៈប្រធានការិយាល័យ

១០–លោក ហែម ស៊ីថន ឋានៈប្រធានការិយាល័យ

១១–លោក ស៊ិន ណុយ ឋានៈប្រធានការិយាល័យ

១២–លោក ពេជ ឡេងគី ឋានៈអនុប្រធានការិយាល័យ

១៣–លោក ម៉ៅ ប៉ុញ្ញខេត្ត ឋានៈអនុប្រធានការិយាល័យ

១៤–លោក ដា សំអុល ឋានៈអនុប្រធានការិយាល័យ

១៥–លោក ឌា សេ ឋានៈអនុប្រធានការិយាល័យ

១៦–លោក ស្រេង ហាង ឋានៈអនុប្រធានការិយាល័យ

១៧–លោក គាន់ ស្វៃរិន ឋានៈអនុប្រធានការិយាល័យ

១៨–លោក ប៊ុន ឈី ឋានៈអនុប្រធានការិយាល័យ

១៩–លោក ស្រី សារិន ឋានៈអនុប្រធានការិយាល័យ

២០–លោក ឈី ហាច ឋានៈអនុប្រធានការិយាល័យ

២១–លោក ហេង សុផល ឋានៈអនុប្រធានការិយាល័យ

២២-លោក សួស សុខុន ឋានៈអនុប្រធានការិយាល័យ

២៣-លោក ឈឹម គឹមហាន ឋានៈអនុប្រធានការិយាល័យ

ដោយអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រដ្ឋលេខាធិការ

ហត្ថលេខានិងត្រា

ស៊ុន ចាន់ថុល

* * *

រាជធានីភ្នំពេញ , ថ្ងៃទី ០៨ ខែ កញ្ញា ឆ្នាំ ១៩៩៥

ប្រកាស លេខ ៣២០ ប្រក.សហវ.ថ

ស្តីអំពីការបង្វែរឥណទាន

* * * *

ទេសរដ្ឋមន្ត្រី

- **រដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

- បានឃើញ រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រ នៃ ព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល កម្ពុជា
- បានឃើញ ច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើ ដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- បានឃើញ ព្រះរាជក្រឹត្យ លេខ នស.រកត ១០៩៤-៨៣ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសម្រួលសមាសភាព រាជរដ្ឋាភិបាល
- បានឃើញព្រះរាជក្រម លេខ ០១ នស ៩៣ ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣ ដែលប្រកាស អោយប្រើច្បាប់ស្តីអំពីប្រព័ន្ធហិរញ្ញវត្ថុ
- បានឃើញ ព្រះរាជក្រមលេខ ១០ នស ៩៤ ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីអំពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រង ឆ្នាំ ១៩៩៥

- បានឃើញអនុក្រឹត្យរបស់រាជរដ្ឋាភិបាលលេខ ០៩ អនក្រ ចុះថ្ងៃទី ២៣ ខែ មករា ឆ្នាំ ១៩៩៥ ស្តីអំពីការបែងចែកឥណទានតាមជំពូក នៃច្បាប់ហិរញ្ញវត្ថុឆ្នាំ ១៩៩៥
- បានឃើញប្រកាសរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុលេខ ០០៤ ចុះថ្ងៃទី២៦ ខែ មករា ឆ្នាំ ១៩៩៥ ស្តីពីការបែងចែកឥណទានផ្ទៃក្នុង តាមជំពូក ប្រការ កថាខ័ណ្ឌ និង វាក្យខ័ណ្ឌ ជូន បណ្តាក្រសួងតាមឥណទានចែងក្នុងច្បាប់ ហិរញ្ញវត្ថុ សំរាប់ឆ្នាំ ១៩៩៥
- បានឃើញប្រកាសរបស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ លេខ ០០៦ ចុះថ្ងៃទី ០៤ ខែ កុម្ភៈ ឆ្នាំ ១៩៩៥ ស្តីពីការណែនាំអនុវត្តថវិកា ឆ្នាំ ១៩៩៥
- តាមសំណើរបស់ក្រសួងអប់រំយុវជន និង កីឡា លេខ ២២៧៧ អយក.ផក.ហវ ចុះថ្ងៃទី ០១ ខែ កញ្ញា ឆ្នាំ ១៩៩៥ និង លេខ ២១៥៣ អយក.ផក.ហវ ចុះថ្ងៃទី ១៩ ខែ សីហា ឆ្នាំ ១៩៩៥

សំរេច

ប្រការ ១ . ត្រូវបានប្រតិបត្តិនៅក្នុងវង្វង់ថវិកា របស់ក្រសួងអប់រំយុវជន និងកីឡា ផ្នែកអប់រំ សំរាប់ការគ្រប់គ្រងឆ្នាំ ១៩៩៥ នូវការបង្វែរឥណទានដូចបានបញ្ជាក់ខាងក្រោមនេះ

ឯកតា : ពាន់រៀល

ជំពូក	ប្រការ	កថាខ័ណ្ឌ	វាក្យខ័ណ្ឌ	ចំណាត់ថ្នាក់ចំណាយ	ស្ថានភាពឥណទានដើមឆ្នាំ	ការកែប្រែឥណទាន កើន	ការកែប្រែឥណទាន ថយ	ស្ថានភាពឥណទានថ្មី
				ការបង្វែរពីជំពូក ១១			១៥.៦០០	
១១	០១	១៤	០២	បោះពុម្ពសៀវភៅសិក្សា	៤៦៧.០០០		១៥.៦០០	៤៥១.៤០០
				ផលប្រយោជន៍ជំពូក១១		១៥.៦០០		
១១	០១	០១	០១	ឈ្នួលស្នាក់ការរដ្ឋបាល		១៥.៦០០		១៥.៦០០

ប្រការ ២ : ឯកឧត្តមរដ្ឋមន្ត្រីក្រសួងអប់រំយុវជន និងកីឡា ជាអ្នកទទួលបន្ទុកក្នុងការ អនុវត្តន៍សេចក្តីប្រកាស នេះ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រដ្ឋលេខាធិការ

ហត្ថលេខានិងត្រា

ស៊ុន ចាន់ថុល

* * *

រាជធានីភ្នំពេញ , ថ្ងៃទី ០៨ ខែ កញ្ញា ឆ្នាំ ១៩៩៥

ប្រកាសលេខ ៣២១ ប្រក.សហវ.គរ

ស្តីពីការអនុវត្តន៍សេវាអធិការកិច្ចទំនិញមុនពេលផ្ទុក

សំរាប់នាំចូលមកក្នុងព្រះរាជាណាចក្រកម្ពុជា

* * *

ទេសរដ្ឋមន្ត្រី

រដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះបាទសម្តេច ព្រះ នរោត្តម សីហនុ វរ្ម័ន ព្រះមហាក្សត្រនៃ ព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល
- បានឃើញច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាស អោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- បានឃើញព្រះរាជក្រឹត្យ លេខនស.រកត ១០៩៤-៨៣ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពី ការកែសំរួលសមាសភាព រាជរដ្ឋាភិបាល
- បានឃើញ កិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាលកម្ពុជា ជាមួយក្រុមហ៊ុន SGS ចុះថ្ងៃទី ០៨ ខែ មិថុនា ឆ្នាំ ១៩៩៥ ស្តីពីការធ្វើអធិការកិច្ចទំនិញមុនពេលផ្ទុក
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ។

សម្រេច

ប្រការ ១ : ប្រកាសអោយប្រើបទបញ្ជាស្តីពីការអនុវត្តន៍សេវាអធិការកិច្ចទំនិញមុនពេលផ្ទុក (Pre-Shipment Inspection " P.S.I ") ដូចមានខ្លឹមសារក្នុង ឧបសម្ព័ន្ធ ភ្ជាប់ជាមួយសេចក្តីប្រកាសនេះ ។

ប្រការ ២ : បទបញ្ជាដែលជាឧបសម្ព័ន្ធនៃសេចក្តីប្រកាសនេះ គឺជាការណែនាំអនុវត្តកិច្ចព្រមព្រៀងរវាងរាជ រដ្ឋាភិបាលកម្ពុជា ជាមួយក្រុមហ៊ុន SGS ចុះថ្ងៃទី ០៨ ខែ មិថុនា ឆ្នាំ ១៩៩៥ ស្តីពីការធ្វើអធិការកិច្ចទំនិញមុនពេលផ្ទុកចូលមកក្នុងព្រះរាជាណាចក្រកម្ពុជា ។

ប្រការ ៣ : នាយកទីចាត់ការគយនិងរដ្ឋាករ និង ប្រធាន អនុប្រធានគ្រប់នាយកដ្ឋាន អង្គភាពក្រោមឱវាទ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវទទួលបន្ទុកអនុវត្តតាមប្រកាសនេះអោយមានប្រសិទ្ធភាព ។

ប្រការ ៤ : ប្រកាសនេះចូលជាធរមាន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រដ្ឋលេខាធិការ

ហត្ថលេខា និង ត្រា

ស៊ុន ចាន់ថុល

* * *

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

បទបញ្ជា (REGULATION)

ស្តីពីការអនុវត្តន៍សេវាអធិការកិច្ចទំនិញមុនពេលផ្ទុក

(PRE-SHIPMENT INSPECTION " PSI ")

បទបញ្ជានេះ ត្រូវបានតាក់តែងឡើងដោយអាជ្ញាធរ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដើម្បីអនុវត្តនីតិវិធីអធិការ កិច្ចទំនិញមុនពេលផ្ទុក (PSI) នាំចូលមកក្នុងព្រះរាជាណាចក្រកម្ពុជា ។

ជំពូក ១

ការបកស្រាយ (INTERPRETATION)

ប្រការ ១ : និយមន័យ (DEFINITIONS)

១.១ : ទីចាត់ការគយនិងរដ្ឋាករ មានន័យថាទីចាត់ការគយនិងរដ្ឋាករនៃព្រះរាជាណាចក្រកម្ពុជា ។

១.២ : របាយការណ៍មិនស្របគ្នា (Discripancy Report) មានន័យថា របាយការណ៍ធ្វើឡើងដោយក្រុមហ៊ុនអធិការកិច្ច នៅពេលដែលអធិការកិច្ចទំនិញមុនពេលផ្ទុក ចង្អុលបង្ហាញថាមានការមិនស្របគ្នារវាងបរិមាណ ឬគុណភាពពិតប្រាកដ ឬទាំងបរិមាណ ទាំងគុណភាពនៃទំនិញ និងសេចក្តីបញ្ជាក់អំពីយថាប្រភេទទំនិញរបស់អ្នកនាំចូល ។

១.៣ ប្រតិវេទន៍គយ (Déclaration De Dédouanement " DDD ") មានន័យថា បែបបទនៃការនាំចូលដែលបានបំពេញដោយអ្នកនាំចូល ផ្អែកលើពត៌មានក្នុងរបាយ ការណ៍ជាក់ស្តែង (ROF) ។

១.៤ ទំនិញរួចផុតពីអធិការកិច្ចទំនិញមុនពេលផ្ទុក (Exempt Goods)មានន័យថា ទំនិញទាំងឡាយដែលមានចែងក្នុងជំពូក២ ប្រការ៣ ត្រង់ចំណុច ៣-១ ត្រង់ចំណុច ៣-២ ។

១.៥ ទំនិញ មានន័យថា ទំនិញនិងសេវាកម្មពាក់ព័ន្ធ (ក្រៅពីទំនិញរួចផុតពីអធិការកិច្ច) ដែលត្រូវបានស្នើសុំនាំចូលមកក្នុងព្រះរាជាណាចក្រកម្ពុជា ហើយបានប្រកាសតំលៃសរុប ទំនិញតាមកិច្ចសន្យា ឬតំលៃពិតប្រាកដនៃទំនិញដែលផ្ញើ មានចំនួនស្មើ ឬលើសពី ៥.០០០ ដុល្លាអាមេលិក (ប្រាំពាន់) ដោយរាប់បញ្ចូលទាំងតំលៃទំនិញផ្ញើជាផ្នែកៗរួមទាំងសេវាកម្មពាក់ព័ន្ធ ដែលមានតំលៃតិចជាងនោះ ប៉ុន្តែតំលៃសរុបនៃទំនិញដែលផ្ញើជាផ្នែកៗបែបនេះ មានចំនួនស្មើ ឬលើសពី ៥.០០០ ដុល្លាអាមេរិក (ប្រាំពាន់) ។

១.៦ : រដ្ឋាភិបាល (Government) មានន័យថា រាជរដ្ឋាភិបាលនៃ ព្រះរាជាណាចក្រកម្ពុជា ។

១.៧ : <u>ប្រាក់កំរៃលើមុខទំនិញនាំចូល</u> (Import Levy) មានន័យថាការទូទាត់ប្រាក់កំរៃ ១% (មួយភាគរយ) លើតំលៃទំនិញ F.O.B ប្រាក់កំរៃនេះមានកំរិតទាបបំផុត ២០០ ដុល្លាអាមេរិក (ពីររយ) ។

១.៨ : <u>យថាប្រភេទទំនិញរបស់អ្នកនាំចូល</u> (Importer Specifications) មានន័យថា សេចក្ដីបញ្ជាក់អំពីយថាប្រភេទទំនិញ ឬនៅពេលគ្មានសេចក្ដីបញ្ជាក់អំពីយថាប្រភេទទំនិញ ទៅលើការរៀបរាប់អំពីមុខទំនិញដែលអ្នកនាំចូលបានទំនាក់ទំនងជាមួយក្រុមហ៊ុនអធិការកិច្ច ដូចមានចែងក្នុងជំពូក ៣ ប្រការ ៥ ចំណុច ៥.៣ ។

១.៩ : <u>ក្រុមហ៊ុនអធិការកិច្ច</u> (Inspection Company) មានន័យថា ក្រុមហ៊ុនដែលមាន ភារកិច្ចអនុវត្តកិច្ចព្រមព្រៀងជាមួយរាជរដ្ឋាភិបាល លើការងារសេវាអធិការកិច្ចទំនិញមុនពេលផ្ទុក (PSI) ក្នុងនាមនៃរាជរដ្ឋាភិបាលកម្ពុជា ។

១.១០ : <u>ការិយាល័យទំនាក់ទំនងរបស់ក្រុមហ៊ុនអធិការកិច្ច</u> (Inspection Company Liaison Office) មានន័យថា ការិយាល័យទំនាក់ទំនងតាំងនៅក្នុងព្រះរាជាណាចក្រកម្ពុជា ដោយក្រុមហ៊ុនអធិការកិច្ច ដើម្បីសំរបសំរួលអធិការកិច្ចទំនិញមុនពេលផ្ទុក (PSI) ។

១.១១ : <u>ក្រសួងពាណិជ្ជកម្ម</u> មានន័យថា ក្រសួងពាណិជ្ជកម្ម នៃព្រះរាជាណាចក្រកម្ពុជា ។

១.១២ : <u>ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ</u> មានន័យថា ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុនៃព្រះរាជាណាចក្រកម្ពុជា ។

១.១៣ : <u>អធិការកិច្ចទំនិញមុនពេលផ្ទុក</u> (PSI) មានន័យថា អធិការកិច្ចលើបរិមាណ គុណភាពទំនិញនិងសកម្មភាពពាក់ព័ន្ធ ដែលត្រូវបានអនុវត្តដោយក្រុមហ៊ុនអធិការកិច្ច ។

១.១៤ : <u>ការផ្ទៀងផ្ទាត់តំលៃ</u> មានន័យថា ការពិនិត្យផ្ទៀងផ្ទាត់លើតំលៃទំនិញទាំងឡាយ ដើម្បី កំណត់ :

ក – ថាតើទឹកប្រាក់ដែលអ្នកលក់ចុះក្នុងវិក័យប័ត្រទំនិញនោះត្រូវគ្នានឹងតំលៃ ទំនិញនាំចេញទូទៅ នៅក្នុងប្រទេសរបស់អ្នកផ្ដល់ ឬក៏

ត្រូវគ្នានឹងតំលៃទំនិញលើទីផ្សារអន្តរជាតិឬទេ ហើយប្រសិនបើតំលៃទាំងនោះមិនត្រូវគ្នាទេ ត្រូវបញ្ជាក់បង្ហាញអោយឃើញនូវទំហំនៃភាពខុសគ្នាអំពីតំលៃ ។

ខ – តំលៃទំនិញសំរាប់ការយកពន្ធគយ ។

១.១៥ :<u>បែបបទនៃការសុំចុះបញ្ជីនាំចូល</u> (Registered Import Advice " RIA ") មាន ន័យថា ឯកសារបញ្ជាក់ដោយការិយាល័យទំនាក់ទំនងរបស់ក្រុមហ៊ុនអធិការកិច្ច បានចេញអោយ អ្នកនាំចូលដែលពាក់ព័ន្ធទៅនឹងពាក្យស្នើសុំរបស់អ្នកនាំចូល ដើម្បីសុំធ្វើអធិការកិច្ចទំនិញមុនពេល ផ្ទុក (PSI) ។

១.១៦ :<u>របាយការណ៍ជាក់ស្តែង</u> (Report of Findings " ROF ") មានន័យថា លទ្ធផល អធិការកិច្ចទំនិញមុនពេលផ្ទុក (PSI) ចេញដោយក្រុមហ៊ុនអធិការកិច្ច ដរាបណា ការងារ អធិការកិច្ចនេះបានបង្ហាញថា :

ក – មុខទំនិញមានភាពសមស្របទៅនឹងសេចក្តីបញ្ជាក់អំពីយថាប្រភេទទំនិញរបស់អ្នកនាំចូល

ខ – ក្នុងករណីមានភាពមិនសមស្របគ្នារវាងមុខទំនិញ និងសេចក្តីបញ្ជាក់អំពីយថាប្រភេទទំនិញ របស់អ្នកនាំចូល តែបើសិនជាខ្លួនព្រមទទួលស្គាល់លើភាពមិនស្របគ្នានេះ របាយការណ៍ជាក់ ស្តែង (ROF) នៅតែត្រូវចេញជូនអ្នកនាំចូលដដែល ។

១.១៧ :<u>ផ្លាកសញ្ញាធានា</u> (Security Label) មានន័យថាផ្លាកសញ្ញាដែលបានបិទដោយ ក្រុមហ៊ុនអធិការកិច្ចលើវិក័យប័ត្រស្ថាពររបស់អ្នកលក់ ពាក់ព័ន្ធទៅនឹងមុខទំនិញដែលត្រូវបានទទួលរបាយការណ៍ជាក់ស្តែង(ROF) ដើម្បីបញ្ជាក់ថា មុខទំនិញទាំងនោះបានធ្វើអធិការកិច្ចរួចហើយ របាយការណ៍ជាក់ស្តែង (ROF) ក៏នឹងត្រូវចេញជូនដែរ ។

១.១៨ :<u>តារាងពន្ធគយ</u> មានន័យថា តារាងមុខទំនិញសំរាប់បង់ពន្ធគយជាធរមានរបស់ព្រះរាជាណាចក្រកម្ពុជា ។

១.១៩: <u>តំលៃសរុប</u> មានន័យថាតំលៃសរុបនៃមុខទំនិញដែលមានចុះក្នុងកិច្ចសន្យា។

១.២០ : សេចក្ដីយោងទៅលើមនុស្សម្នាក់ (References to a person) រួមបញ្ចូលទាំងនីតិបុគ្គល ក្រុមហ៊ុនចំរុះ ឬក្រុមហ៊ុនស្របច្បាប់ដទៃទៀត ។

១.២១ : សេចក្ដីយោងដល់ប្រការទាំងឡាយ គឺសេចក្ដីយោងដល់ប្រការទាំងឡាយនៃបទ បញ្ញានេះ ។

១.២២. : ចំណងជើងត្រូវបានបញ្ចូល ដើម្បីភាពងាយស្រួល ហើយនិងមិនត្រូវប៉ះពាល់ដល់ ការបកស្រាយនៃបទបញ្ញានេះទេ ។

ជំពូក ២

វិសាលភាពនៃការអធិការកិច្ចទំនិញមុនពេលផ្ទុក (PSI)

(SCOPE OF PRE-SHIPMENT INSPECTION)

ប្រការ ២ : ទំនិញត្រូវទទួលអធិការកិច្ចទំនិញមុនពេលផ្ទុក (PSI)

២.១ : ការចាប់ផ្ដើម (Commencement)

បទបញ្ញានេះត្រូវអនុវត្តលើទំនិញទាំងឡាយណាដែលត្រូវដឹកជញ្ជូនចូលមកព្រះរាជាណាចក្រកម្ពុជា ចាប់ពីថ្ងៃទី ០៨ ខែ កញ្ញា ឆ្នាំ ១៩៩៥ តទៅ ។

២.២ : ការចុះបញ្ជី (Registration)

ទំនិញទាំងអស់ក្រៅពីទំនិញដែលមាន ចែង ក្នុងជំពូក ១ ប្រការ ១ ត្រង់ចំណុច ១.៤ ដែលត្រូវនាំចូលមកក្នុង ព្រះរាជាណាចក្រកម្ពុជា ចាប់ពីថ្ងៃទី០៨ ខែ កញ្ញា ឆ្នាំ ១៩៩៥ ត្រូវតែមក ចុះបញ្ជីនៅក្រុមហ៊ុនអធិការកិច្ច ។

២.៣ : ការងារអធិការកិច្ចទំនិញ (Inspection of goods)

ទំនិញទាំងឡាយ ដែលត្រូវនាំចូលមកក្នុងព្រះរាជាណាចក្រកម្ពុជា ចាប់ពីថ្ងៃទី ០១ ខែ តុលា ឆ្នាំ ១៩៩៥ ត្រូវទទួលអធិការកិច្ចទំនិញមុនពេលផ្ទុក (PSI) ដោយក្រុមហ៊ុន អធិការកិច្ច ដែលស្ថិតនៅក្នុងប្រទេសរបស់អ្នកផ្ដល់ទំនិញនោះ មុនពេលធ្វើការដឹកជញ្ជូន ចូលមកព្រះរាជាណាចក្រកម្ពុជា ។

២.៤ : អន្តរកាល (Transitional)

អ្នកនាំចូលទំនិញទាំងឡាយអាចរៀបចំការ ដឹកជញ្ជូនទំនិញមកកាន់ ព្រះរាជាណាចក្រកម្ពុជា មុនថ្ងៃទី ០១ ខែ តុលា ឆ្នាំ ១៩៩៥ ដោយគ្មានទទួលអធិការ

កិច្ចទំនិញមុនពេលផ្ទុក (PSI) អោយតែនៅក្នុងឯកសារផ្ញើទំនិញតាមនាវាឬតាមផ្លូវអាកាសមានចុះកាលបរិច្ឆេទ មុនថ្ងៃទី ០១ ខែ តុលា ឆ្នាំ ១៩៩៥ ។

ប្រការ ៣ : ទំនិញរួចផុតពីអធិការកិច្ចទំនិញមុនពេលផ្ទុក « PSI » (GOODS EXEMPT FROM PSI)

៣.១ : ទំនិញទាំងឡាយដែលអាចរួចផុតពីអធិការកិច្ចទំនិញមុនពេលផ្ទុក (PSI) មានដូចខាងក្រោម :

ក – ត្បូងពេជ្រ និង លោហធាតុមានតំលៃ

ខ – វត្ថុសិល្បៈ

គ – គ្រឿងផ្ទះ និង ផលិតផលកាំជ្រួច

ឃ – គ្រាប់វិសេស សញ្ញាវុធ និង យោធូបករណ៍

ង – សត្វមានជីវិត

ច – សារពត៌មាន និង ទស្សនាវដ្តី

ឆ – ប្រដាប់ប្រដាគុបតែងផ្ទះផ្ទាល់ខ្លួន និង ប្រដាប់ប្រដាប្រើប្រាស់ផ្ទាល់ខ្លួន រួមទាំងយាន យន្តដែលបានប្រើប្រាស់ផ្ទាល់ខ្លួនរួចមកហើយ ។

ជ – កញ្ចប់អីវ៉ាន់ផ្ញើតាមប្រៃសណីយ៍ និង វត្ថុគំរូខាងពាណិជ្ជកម្ម

ឈ– អំណោយរបស់រដ្ឋាភិបាលប្រទេសនានា ឬអង្គការអន្តរជាតិ ចំពោះមូលនិធិ និង អង្គការមនុស្សធម៌ផ្សេងៗ ដែលត្រូវបានទទួលស្គាល់ជាផ្លូវការ ។

ញ – អំណោយ និង សំភារៈ សំរាប់បេសកកម្មទូត គណៈប្រតិភូ កុងស៊ុល និង សំរាប់ អង្គការដែលពឹងផ្អែកលើអង្គការសហប្រជាជាតិ ដែលត្រូវបាននាំចូលសំរាប់ការប្រើប្រាស់ផ្ទាល់ខ្លួន ។

៣.២ : ការនាំចូលជាបណ្តោះអាសន្ន ដោយមានការបញ្ជាក់ពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុនូវមុខទំនិញ :

ក – បារី (Cigarettes)

ខ – ទោចក្រយានយន្ត (Motocycles)

គ – ទូរទស្សន៍ (T.Vs)

ឃ – ម៉ាញ៉េតូហ្វូន (Radio / Cassette players)

ង – ម៉ាស៊ីនបញ្ចាំងរូប (VTRs)

ឋ – ផលិតផលប្រេងកាត (Petroleum Products)

ជំពូក ៣

នីតិវិធី (PROCEDURE)

ប្រការ ៤ : លក្ខខណ្ឌទូទៅ (GENERAL REQUIREMENTS)

៤.១ : ឯកសារចំលងបញ្ជាទិញ (Copies of orders)

អ្នកនាំចូលទាំងឡាយ ត្រូវផ្តល់ជូនក្រុមហ៊ុនអធិការកិច្ចនូវឯកសារចំលងបញ្ជាទិញនីមួយ ៗ ចំនួន ២ ច្បាប់ សំរាប់រាល់ការទិញ ឬការនាំចូលទំនិញ ។ ឯកសារទាំងឡាយដែលត្រូវដាក់ជូន ត្រូវមានពាក្យស្នើសុំទៅក្រុមហ៊ុនអធិការកិច្ចដែល បំពេញដោយអ្នកនាំចូល ដោយត្រូវភ្ជាប់មកជាមួយនូវអ្វីៗ ដែលពាក់ព័ន្ធទៅលើឯកសារផ្លូវការណាមួយដូចជា ពាក្យស្នើសុំទិញរូបិយប័ណ្ណ វិក័យ ប័ត្របណ្តោះអាសន្ន លិខិតបញ្ជាទិញ កិច្ចសន្យាទាំងឡាយដោយមានបញ្ជាក់អំពីយថាប្រភេទទំនិញ ឯកសារដឹកជញ្ជូន និង ឯកសារពាក់ព័ន្ធផ្សេងទៀត ។

៤.២ : ការចេញបែបបទ នៃការសុំចុះបញ្ជីនាំចូល (Isue of RIAs)

ការិយាល័យទំនាក់ទំនង នៃក្រុមហ៊ុនអធិការកិច្ច ត្រូវចុះបញ្ជីនូវរាល់ការបញ្ជាទិញទំនិញទាំងនេះ ហើយត្រូវចេញបែបបទនៃការសុំចុះបញ្ជីនាំចូល ដែលនិងត្រូវប្រគល់ជូន អ្នកនាំចូល ក្នុងរយៈពេល ២៤ ម៉ោង បន្ទាប់ពី បានទទួលបែបបទពីអ្នកនាំចូល ។

៤.៣ : លេខសំគាល់ (Reference Number)

បែបបទ នៃការសុំចុះបញ្ជីនាំចូល (RIA)ត្រូវមានលេខសំគាល់ពិសេសមួយដើម្បីបញ្ជាក់ក្នុងកិច្ចការជំនួញ និង អាចប្រើប្រាស់ក្នុងការឆ្លងឆ្លើយទាំង ឡាយជាមួយនឹងក្រុមហ៊ុន អធិការកិច្ច ។

៤.៤ : ឯកសារមិនគ្រប់លក្ខណៈ (Inadequate Documentation)

ឯកសារទាំងឡាយដែលអ្នកនាំចូល បានផ្ញើជូនក្រុមហ៊ុនអធិការកិច្ចដែលត្រូវបានចាត់ថាជាឯកសារមិនគ្រប់លក្ខណៈ គឺជាឯកសារដែលមានមិនបាន ឬមិនច្បាស់លាស់ ត្រូវតែបានបញ្ជូនត្រឡប់ជូនអ្នកនាំចូលវិញ ដើម្បីធ្វើការកែតំរូវមុន

ពេលចេញបែបបទ នៃការសុំចុះបញ្ជីនាំចូល (RIA) ។

៤.៥ : ការស្នើសុំពត៌មាន (Request for Information)

ការិយាល័យ ទំនាក់ទំនងនៃក្រុមហ៊ុនអធិការកិច្ច ត្រូវធ្វើសេចក្ដីលំអិតស្ដីពីបែបបទនៃ ការសុំចុះបញ្ជីនាំចូល (RIA) ទៅកាន់ការិយាល័យអធិការកិច្ច ឬសាខារបស់ខ្លួន នៅក្នុងប្រទេសដែលផ្ដល់ទំនិញ រួចត្រូវធ្វើសេចក្ដីស្នើជាបន្ទាន់ជូនអ្នកលក់ ដើម្បីផ្ដល់ពត៌មានអំពីមុខទំនិញ និងរៀបចំចាត់ចែងអធិការកិច្ចទំនិញមុនពេលផ្ទុក (PSI) ។

៤.៦ : ឯកសារចំលងសំរាប់ទីចាត់ការគយនិងរដ្ឋាករ (Copies to Bureau of Customs)

ក្រុមហ៊ុនអធិការកិច្ច ត្រូវបញ្ជូនអោយបានឆាប់រហ័សនូវ ឯកសារចំលងជូនទីចាត់ការគយនិងរដ្ឋាករ ដូចជាឯកសារសុំធ្វើអធិការកិច្ច និង បែបបទនៃការសុំចុះបញ្ជីនាំចូល (RIA) ។

ប្រការ ៥ : អធិការកិច្ចទំនិញមុនពេលផ្ទុក (PSI OF GOODS)

៥.១ : អធិការកិច្ចទំនិញមុនពេលផ្ទុក (PSI)

អ្នកលក់ត្រូវមកទាក់ទងជាមួយក្រុមហ៊ុនអធិការកិច្ចយ៉ាងតិច ៥ ថ្ងៃមុនដើម្បីអោយក្រុមហ៊ុនអធិការកិច្ចរៀបចំធ្វើអធិការកិច្ចទំនិញមុនពេលផ្ទុក (PSI) ។ ទោះបីអ្នកលក់ ជូនដំណឹងក្នុងរយៈពេលតិចជាង ៥ ថ្ងៃក៏ដោយ ក៏ក្រុមហ៊ុន អធិការកិច្ច មិនត្រូវពន្យាពេល វេលានៃការអនុវត្តន៍អធិការកិច្ចទំនិញមុនពេលផ្ទុក (PSI) អោយយឺតយូរឡើយ ។

៥.២ : កិច្ចតំរូវទៅលើការងារ (Required Tasks)

ក្រុមហ៊ុនអធិការកិច្ច ឬ សាខារបស់ខ្លួននៅក្នុងប្រទេសដែលផ្ដល់ទំនិញ ត្រូវអនុវត្តការងារដូចខាងក្រោម ដោយប្រើប្រាស់ពត៌មានទាំងឡាយដែលខ្លួនមាន :

ក – អធិការកិច្ចទំនិញមុនពេលផ្ទុក (PSI)

ខ – ការផ្ទៀងផ្ទាត់តំលៃសរុបនៃមុខទំនិញ

ឃ – ការកំណត់តំលៃទំនិញ ដែលត្រូវបង់ពន្ធគយអោយបានស្របតាមតារាងពន្ធគយ នៃ ព្រះរាជាណាចក្រកម្ពុជា ។

ង – ការកំណត់ចំណាត់ថ្នាក់ទំនិញអោយបានស្របតាមតារាងពន្ធគយ ។

ច – ការគណនាពន្ធគយ និងអាករផ្សេង ៗ ដែលត្រូវបង់ចំពោះមុខទំនិញទាំងឡាយនោះ ។

៥.៣ : ឯកសារដែលត្រូវផ្តល់ជូន (Documentation to be Provided)

អ្នកលក់ត្រូវផ្តល់អោយក្រុមហ៊ុនអធិការកិច្ច ឬ សាខាក្រុមហ៊ុនអធិការកិច្ច នូវឯកសារចំលងនានា នៃការបញ្ជាទិញ បញ្ជីតំលៃទំនិញ សារគណនាទាន និង ឯកសារផ្សេង ៗ ទៀត ដែលក្រុមហ៊ុនអធិការកិច្ចត្រូវការចាំបាច់ សំរាប់ការងារ អធិការកិច្ចទំនិញមុនពេលផ្ទុក (PSI) ។

៥.៤ : លំហូខំណូសំរាប់អ្នកលក់ទំនិញ (Provision of Facilities)

អ្នកលក់ត្រូវផ្តល់ជូនក្រុមហ៊ុនអធិការកិច្ច ឬសាខាក្រុមហ៊ុនអធិការកិច្ចនូវ រាល់សិណ្ឋមការចាំបាច់នានាដូចជា : វិញ្ញាបនប័ត្រធ្វើតេស្តទំនិញ បង្កលក្ខណៈ ងាយស្រួលការបង្ហាញមុខទំនិញ និង បង្ហាញគំរូទំនិញព្រមទាំងកន្លែងធ្វើតេស្ត ទំនិញដើម្បីអោយស្របតាមគោលបំណងអធិការកិច្ចទំនិញមុនពេលផ្ទុក (PSI) ។

៥.៥ : ទីកន្លែងអធិការកិច្ចទំនិញមុនពេលផ្ទុក (Place of PIS)

អធិការកិច្ច ទំនិញមុនពេលផ្ទុក (PSI) អាចអនុវត្តនៅក្នុងបរិវេណរបស់ អ្នកលក់ ឬ ទីកន្លែងសមរម្យណាមួយ មុនពេលដឹកជញ្ជូននាំចូលមកក្នុង ព្រះរាជា ណាចក្រកម្ពុជា ។ ក្រុមហ៊ុនអធិការកិច្ចមានសិទ្ធិធ្វើអធិការកិច្ចទំនិញឡើងវិញ គ្រប់ពេលវេលាមុនពេលរៀបចំធ្វើការដឹកជញ្ជូនចូលមក ក្នុងព្រះរាជាណាចក្រ កម្ពុជា ដោយត្រូវធ្វើការបិទត្រា សំគាល់លើកែស ឬ កុងទែន័រទំនិញទាំងឡាយ

ដែលយល់ថាជាការចាំបាច់ នឹងអាចអនុវត្តបាន ដោយក្រុមហ៊ុន អធិការកិច្ច ។

៥.៦ : ការពិនិត្យឡើងវិញដោយក្រុមហ៊ុនអធិការកិច្ច (Repeated Visits by Inspection Company)

ប្រសិនបើអ្នកលក់ ចាត់ចែងអោយក្រុមហ៊ុន អធិការកិច្ចធ្វើអធិការកិច្ច ទំនិញដោយមិនបានរៀបចំទំនិញដែលត្រូវធ្វើអធិការកិច្ចនោះអោយបាន ត្រឹមត្រូវ ឬ ប្រសិនបើទំនិញនោះបានផ្ទៀងផ្ទាត់ និង រកឃើញមានភាព មិនស្របគ្នាជាមួយ នឹងសេចក្តីបញ្ជាក់អំពីយថាប្រភេទ នៃ មុខទំនិញរបស់អ្នកនាំចូលនោះ សោហ៊ុយ

ចំណាយលើការងារត្រួតពិនិត្យឡើងវិញ នេះជាបន្ទុករបស់អ្នកលក់ ។

៥.៧ : ករណីគ្មានលទ្ធភាពធ្វើអធិការកិច្ច (Inability to Inspect)

ក្នុងករណីណា ដែលក្រុមហ៊ុនអធិការកិច្ច មិនអាចមានលទ្ធភាពធ្វើអធិការកិច្ចទំនិញមុនពេលផ្ទុក (PSI) ទេនោះ ក្រុមហ៊ុនអធិការកិច្ច ត្រូវជូនដំណឹងជាលាយលក្ខណ៍ អក្សរជាបន្ទាន់ ដល់លោកនាយកទីចាត់ការគយ និងរដ្ឋាករ ។

៥.៨ : វិក័យប័ត្រស្នាម និង ពត៌មានពាក់ព័ន្ធ (Final Settlement Invoice)

នៅពេលមានការឯកភាពលើអធិការកិច្ចទំនិញមុនពេលផ្ទុក (PSI) និងការផ្ទៀងផ្ទាត់ថ្លៃទំនិញដោយក្រុមហ៊ុនអធិការកិច្ច ឬ សាខាក្រុមហ៊ុនអធិការកិច្ច ហើយនោះអ្នកលក់ត្រូវចេញវិក័យប័ត្រស្នាមជូនក្រុមហ៊ុនអធិការកិច្ច ដែលមានខ្លឹមសារលំអិតដូចខាងក្រោម :

ក – ការរៀបរាប់អំពីមុខទំនិញ

ខ – ទំងន់ និង ចំណុះ

គ – មធ្យោបាយដឹកជញ្ជូន

ឃ – កំពង់ផែឬព្រលានយន្តហោះដែលត្រូវផ្ទុកទំនិញ(រួមទាំងកំពង់ផែឆ្លងកាត់)

ង – កំពង់ផែ ឬ ព្រលានយន្តហោះ ដែលត្រូវផ្ទេរទំនិញ

ច – កាលបរិច្ឆេទកំណត់នៃការដឹកជញ្ជូនចូលមកក្នុងព្រះរាជាណាចក្រកម្ពុជា។

៥.៩ : ការហាមឃាត់នៃការប្រៀបធៀបថ្លៃ (Price Comparison Restrictions)

នៅក្នុងប្រទេសណា ការប្រៀបធៀបថ្លៃត្រូវហាមឃាត់ការ ផ្ទៀងផ្ទាត់ថ្លៃត្រូវអនុវត្តតាមច្បាប់ជាធរមានរបស់ប្រទេសនោះ ហើយក្រុមហ៊ុនអធិការកិច្ចត្រូវធ្វើរបាយការណ៍ អំពីការប្រៀបធៀបថ្លៃនោះជូនរាជរដ្ឋាភិបាល ។

ប្រការ ៦ : នីតិវិធីនៃការយកទំនិញចេញ និង អធិការកិច្ចចុងក្រោយ (POST-INSPECTION AND CLEARANCE PROCEDURES)

៦.១ : ការផ្ដល់ជូនរបាយការណ៍ជាក់ស្ដែង(Issue of ROF)

ក្រោយពេលការងារអធិការកិច្ចមុនពេលផ្ទុក(PSI)បានអនុវត្តត្រឹមត្រូវរួច ហើយវិក័យប័ត្រ ស្លាក និងពតិមានពាក់ព័ន្ធត្រូវបានអ្នកនាំចូលផ្តល់ជូនក្រុមហ៊ុនអធិការកិច្ច រួចក្រុមហ៊ុនអធិការកិច្ចត្រូវផ្តល់របាយការណ៍ជាក់ស្តែង (ROF) ជូនអ្នកនាំចូល ។

៦.២ : <u>មាតិកានៃរបាយការណ៍ជាក់ស្តែង</u> (ROF)

ក – ប្រភេទទំនិញ

ខ – ចំនួន ឬ បរិមាណទំនិញ

គ – គុណភាព ឬ សេចក្តីបញ្ជាក់ពិតប្រាកដអំពីយថាប្រភេទទំនិញជាក់ស្តែង ឬ រួមទាំងពីរ

ឃ – ការផ្ទៀងផ្ទាត់ថ្លៃទំនិញ

ង – ចំណាត់ថ្នាក់ទំនិញ តាមតារាងពន្ធគយ ។

៦.៣ : <u>ឯកសារចំលងនៃរបាយការណ៍ជាក់ស្តែង</u> (Copies of ROF)

របាយការណ៍ជាក់ស្តែង (ROF) ត្រូវធ្វើអោយបានគ្រប់ចំនួន ដែលក្នុងនោះមានច្បាប់ដើមមួយច្បាប់ និងច្បាប់ចំលងប្រាំច្បាប់ ។ ក្រុមហ៊ុនអធិការកិច្ចត្រូវផ្តល់ជូនអ្នកនាំចូលច្បាប់ដើមមួយច្បាប់ និងច្បាប់ចំលងបីច្បាប់ជូនក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុមួយច្បាប់និងក្រសួងពាណិជ្ជកម្មមួយច្បាប់ ។ ពេលទទួលយកទំនិញចេញតាមរយៈសមត្ថកិច្ចគយ និង រដ្ឋាករបាយការណ៍ជាក់ស្តែង (ROF) ត្រូវតំកល់ទុកតាមកន្លែងដូច ខាងក្រោម :

ក – អ្នកនាំចូល រក្សាទុកច្បាប់ដើម

ខ – ក្រោយពីបានទទួលបានច្បាប់ចំលងចំនួនបីច្បាប់ ពីអ្នកនាំចូលរួចមកទីចាត់ការគយ និងរដ្ឋាករ ត្រូវរក្សាទុកចំនួនពីរច្បាប់ និងផ្ញើជូនក្រុមហ៊ុនអធិការកិច្ចចំនួនមួយច្បាប់

គ – ក្រសួងពាណិជ្ជកម្ម មួយច្បាប់

ឃ – ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ មួយច្បាប់

ង – ក្រុមហ៊ុនអធិការកិច្ចចំនួន មួយច្បាប់ ដែលទទួលពីទីចាត់ការគយ និងរដ្ឋាករ ក្រោយ ពេលដែលអ្នកនាំចូលបានធ្វើការទូទាត់បង់ពន្ធគយ និង

អាករផ្សេងៗទៀត ដោយមានចំណារយល់ព្រម និង សេចក្តីលំអិតអំពីការទូទាត់នេះ ។

៦.៤ : របាយការណ៍មិនស្របគ្នា (Discrepancy Report)

ក្នុងករណីដែល អធិការកិច្ចទំនិញមុនពេលផ្ទុក មិនបានទទួលការឯកភាពឬមិនបានសំរេចនោះ ក្រុមហ៊ុនអធិការកិច្ចពុំអាចចេញរបាយការណ៍ជាក់ស្តែង (ROF) បានឡើយ ។ ផ្ទុយទៅវិញក្រុមហ៊ុនអធិការកិច្ចត្រូវចេញរបាយការណ៍ មិនស្របគ្នា ហើយត្រូវផ្ញើជូនកន្លែងនានា ស្របតាមជំពូក ៣ ប្រការ ៦ ចំណុច ៦.៣ ។

៦.៥ : ការកែតំរូវលើភាពមិនស្របគ្នា (Correction of Discrepancies)

ប្រសិនបើអ្នកលក់មិនបានកែតំរូវអោយបានទាន់ពេលវេលា លើភាពមិនស្របគ្នាដែលក្រុមហ៊ុនអធិការកិច្ចបានកំណត់មុនពេលធ្វើការដឹកជញ្ជូនទំនិញទេ នោះក្រុមហ៊ុនអធិការកិច្ចត្រូវរក្សាទុករបាយការណ៍ជាក់ស្តែង (ROF) ហើយត្រូវចេញសេចក្តីបញ្ជាក់លើ មុខទំនិញដែលមិនស្រប និង មិនបានកែតំរូវតាមរយៈរបាយការណ៍មិនស្រប ។ ប្រសិនបើអ្នកលក់យល់ព្រមកែតំរូវតាមរបាយការណ៍មិនស្របគ្នា មុនពេលធ្វើការដឹកជញ្ជូនទំនិញនោះ ក្រុមហ៊ុនអធិការកិច្ចត្រូវផ្តល់របាយការណ៍ជាក់ស្តែង (ROF) ជូន ។

៦.៦ : ផ្លាកសញ្ញាធានា (Security Label)

ចំពោះការដឹកទំនិញនីមួយ ។ អ្នក លក់ត្រូវបានទទួលពីក្រុមហ៊ុនអធិការកិច្ចនូវច្បាប់ ដើមនៃវិក័យប័ត្រស្អាតដែលបានដាក់ជូនទៅក្រុមហ៊ុនអធិការកិច្ចដោយមានសេចក្តីបញ្ជាក់យ៉ាងត្រឹមត្រូវពីក្រុមហ៊ុនអធិការកិច្ចតាមរយៈផ្លាកសញ្ញាធានា ដោយបាន បញ្ជាក់ថា មុខទំនិញដែលមានចុះក្នុងវិក័យប័ត្រត្រូវបានធ្វើអធិការកិច្ច ហើយរបាយការណ៍ជាក់ស្តែង (ROF) ក៏បានចេញជូនផងដែរ ។

៦.៧ : ប្រតិវេទន៍គយ (Déclaration de Dédouanement " DDD")

អ្នកនាំចូល ត្រូវប្រើរបាយការណ៍ជាក់ស្តែង (ROF) ជាគោល សំរាប់បំពេញប្រតិវេទន៍គយ និង ទូទាត់ពន្ធគយ និង អាករ ដែលត្រូវបង់ជូនសមត្ថកិច្ចគយ និងរដ្ឋាករ នៅមាត់ច្រកនាំចូលក្នុងព្រះរាជាណាចក្រកម្ពុជា ។

ក្នុងករណីមានការកែប្រែលើអត្រាពន្ធ អ្នកនាំចូលត្រូវបំពេញបែបបទ របាយការណ៍ជាក់ស្តែងពីក្រុមហ៊ុន អធិការកិច្ច ។

៦.៨ : ការផ្តល់នូវប្រតិវេទន៍គយ (DDD)

អ្នកនាំចូលត្រូវចុះហត្ថលេខាលើ ប្រតិវេទន៍គយ តាមគំរូមានស្រាប់ ហើយប្រគល់ជូន ទីចាត់ការគយ និង រដ្ឋាករ ដោយមានភ្ជាប់ទាំងឯកសារពាក់ព័ន្ធ និងត្រូវបង់ពន្ធគយ និងអាករផ្សេងៗដូចមានបញ្ជាក់ក្នុងប្រតិវេទន៍គយ ។ គ្មានទំនិញណាមួយ ត្រូវបានយកចេញពីទីចាត់ការគយ និង រដ្ឋាករដោយគ្មានប្រតិវេទន៍គយច្បាប់ដើមដែល ត្រូវបានបំពេញនិងចុះហត្ថលេខារួច ព្រមជាមួយរបាយការណ៍ជាក់ស្តែង (ROF) ។

៦.៩ : សេចក្តីជូនដំណឹងទៅក្រុមហ៊ុនអធិការកិច្ច

ទីចាត់ការគយ និងរដ្ឋាករ ត្រូវផ្តល់នូវរបាយការណ៍ជាក់ស្តែង (ROF) ដែលមានសេចក្តីលំអិតស្តីពីពន្ធគយ និង អាករផ្សេង ។ ដែលអ្នកនាំចូលត្រូវបង់ជូនក្រុមហ៊ុន អធិការកិច្ចដោយ យោងតាមជំពូក ៣ ប្រការ ៦ ត្រង់ចំណុច ៦.៣ «គ» ឬ ផ្ញើជូនក្រុមហ៊ុន អធិការកិច្ច នូវច្បាប់ចំលងប្រតិវេទន៍គយ ដែលទីចាត់ការគយ និង រដ្ឋាករ បានទទួលតាម ជំពូក ៣ ប្រការ ៦ ចំណុច ៦.៨ ដោយត្រូវអោយមានតួអក្សរច្បាស់អាចអានបាន ។

៦.១០ : ការផ្តល់ឯកសារ

ក្រុមហ៊ុនអធិការកិច្ចត្រូវ ធ្វើសំណើចំពោះអ្នកលក់ អោយផ្ញើឯកសាររួម មានវិក័យប័ត្រស្ថាពរ បញ្ជីរាយមុខទំនិញតាមនាវា បញ្ជីរាយមុខទំនិញតាមអាកាស និងឯកសារដឹកជញ្ជូនផ្សេងៗទៀត ។ ឯកសារទាំងនេះមិនទាន់ចាត់ទុកថាជាល័ក្ខខ័ណ្ឌសំរាប់ការចេញរបាយការណ៍ជាក់ស្តែង (ROF) ។

៦.១១: អធិការកិច្ច នៅកម្ពុជា

ក្រុមហ៊ុនអធិការកិច្ច ឬ ភ្នាក់ងារតំណាងក្រុមហ៊ុនអធិការកិច្ច និងទីចាត់ការគយ និងរដ្ឋាករ មានសិទ្ធិធ្វើអធិការកិច្ចរួមគ្នាលើមុខទំនិញទាំងឡាយ នៅពេលដែលទំនិញទាំងនោះ ចូលមកដល់ ព្រះរាជាណាចក្រកម្ពុជា ។

៦.១២: អធិការកិច្ចទំនិញសារជាថ្មីឡើងវិញ

ក្រុមហ៊ុនអធិការកិច្ច ឬភ្នាក់ងារតំណាងក្រុមហ៊ុនអធិការកិច្ច និងទីចាត់ការ

គយ និងរដ្ឋាករ មានសិទ្ធិធ្វើអធិការកិច្ចរួមគ្នាជាថ្មីឡើងវិញ នៅពេលដែលទំនិញទាំងនោះបាននាំចូល មកដល់ព្រះរាជាណាចក្រកម្ពុជា នៅពេលដែលមានបញ្ហាក់ពីការចេញ របាយការណ៍មិន សមស្របគ្នា ឬ មានការមន្ទិលសង្ស័យថាទំនិញទាំងនោះមិនបានអនុលោមតាមរបាយ ការណ៍ជាក់ស្តែង (ROF) ឬក៏មានសំណើសុំអោយមានអធិការកិច្ចសាជាថ្មីឡើងវិញ ពីអ្នកនាំចូល ។

ជំពូក ៤

ប្រាក់កំរៃអធិការកិច្ច (LEVY ON GOODS)

ប្រការ ៧ : ប្រាក់កំរៃលើមុខទំនិញនាំចូល (IMORT LEVY)

៧.១ : ចំនួនប្រាក់កំរៃ

ទំនិញទាំងឡាយដែលនាំចូលមកក្នុងព្រះរាជាណាចក្រកម្ពុជា លើកលែងតែទំនិញក្នុង ជំពូក ១ ប្រការ ១ ចំណុច ១.៤ ត្រូវបង់កំរៃអធិការកិច្ចដូចមានចែងក្នុងប្រការ ១ ត្រង់ ចំណុច ១.៨ ។

៧.២ : ការបង់ប្រាក់កំរៃ

ប្រាក់កំរៃ ត្រូវបង់ចូលធនាគារជាតិនៃកម្ពុជា តាមគណនីពិសេសលេខ ៣០៨៥២១៥ មុននឹងដាក់ជូនឯកសារនាំចូល ទៅអោយការិយាល័យទំនាក់ទំនងនៃក្រុមហ៊ុនអធិការកិច្ច ដើម្បីចេញបែបបទសុំចុះបញ្ជីនាំចូល (RIA) ។

៧.៣ : ការចេញបង្កាន់ដៃបង់ប្រាក់

ពេលទទួលប្រាក់កំរៃអធិការកិច្ចធនាគារជាតិនៃកម្ពុជា ត្រូវចេញបង្កាន់ដៃទទួលប្រាក់ជូនអ្នកនាំចូល ។ ត្រូវដាក់ជូនក្រុមហ៊ុនអធិការកិច្ច នូវបង្កាន់ដៃនេះ ដោយភ្ជាប់ជាមួយ នឹងឯកសារនាំចូលផ្សេង ៗ ទៀត ។

ជំពូក ៥

ដំណោះស្រាយវិវាទ (RESOLUTION OF DISPUTES)

ប្រការ ៨ : ការវិវាទ

៨.១ : ការពិភាក្សាជាមួយនិងក្រុមហ៊ុនអធិការកិច្ច

អ្នកនាំចូលអាចធ្វើការជេញដោល ឬ ជំទាស់ទៅនឹងយោបល់របស់ក្រុមហ៊ុនអធិការកិច្ច លើរាល់បញ្ហាដែលមានការពាក់ព័ន្ធនឹងមុខទំនិញរបស់ខ្លួនតាមរយៈលិខិតជាលាយលក្ខណ៍អក្សរ ផ្ញើជូនការិយាល័យទំនាក់ទំនង នៃក្រុមហ៊ុនអធិការកិច្ចនៅភ្នំពេញ ។ ប្រសិនបើការវិវាទមិនបានដោះស្រាយក្នុងរយៈពេល ១ សប្តាហ៍ ក្រោយពីក្រុមហ៊ុនអធិការកិច្ចបានទទួលលិខិតជំទាស់ជាលាយលក្ខណ៍អក្សរ អ្នកនាំចូលអាចបញ្ជូនសំណុំរឿងនេះទៅ « គណៈកម្មការដោះស្រាយ » ។

៨.២ : ការបញ្ចេញទំនិញ

នៅពេល «គណៈកម្មការដោះស្រាយ » កំពុងធ្វើការពិនិត្យ និងពិចារណាលើសំណុំរឿងរបស់អ្នកនាំចូលនោះ អ្នកនាំចូលអាចដាក់ពាក្យសុំមកទីចាត់ការគយ និង រដ្ឋាករ ដើម្បីសុំយកទំនិញចេញដោយត្រូវបង់ប្រាក់កក់ធានា តាមការសំរេចរបស់ទីចាត់ការគយ និង រដ្ឋាករ ។

ជំពូក ៦

ការបង្កើត « គណៈកម្មការដោះស្រាយ »

ប្រការ ៩ : គណៈកម្មការដោះស្រាយ

៩.១ : ការបង្កើតគណៈកម្មការ

រាជរដ្ឋាភិបាលត្រូវបង្កើត «គណៈកម្មការដោះស្រាយ »មួយ ដើម្បីពិនិត្យវិនិច្ឆ័យលើសេចក្តីសំរេចរបស់ក្រុមហ៊ុន អធិការកិច្ច ដែលអ្នកនាំចូលបានធ្វើការតវ៉ា ។ គណៈកម្មការនេះរួមមានតំណាងមកពីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ទីចាត់ការគយនិងរដ្ឋាករ ក្រសួងពាណិជ្ជកម្ម ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា និង អង្គភាពឯកជន ។

៩.២ : ប្រធានគណៈកម្មការ

«គណៈកម្មការដោះស្រាយ » នេះ មានប្រធានមួយរូបដែលត្រូវតែងតាំងដោយរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សំរាប់អាណត្តិ ១២ ខែ ។ ប្រធានគណៈកម្មការនេះអាចបន្តមួយអាណត្តិទៀតតាមការសំរេចរបស់រដ្ឋមន្ត្រីក្រសួង

សេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ។

៩.៣ : <u>សេចក្តីសំរេចចុងក្រោយ</u>

«គណៈកម្មការដោះស្រាយ» ត្រូវសំរេចលើការវិវាទក្នុងរយៈពេល ១ ខែ យ៉ាងយូរ ក្រោយពីបានទទួលសំណុំលិខិតតវ៉ារបស់អ្នកនាំចូល ។ សេចក្តីសំរេចរបស់ « គណៈកម្មការដោះស្រាយ » គឺជាសេចក្តីសំរេចចុងក្រោយដែលក្រុមហ៊ុនអធិការកិច្ច និង អ្នកនាំចូលត្រូវគោរព និង អនុវត្តតាមជាដាច់ខាត ។

ជំពូក ៧

កាតព្វកិច្ចរបស់អ្នកនាំចូល និង អ្នកលក់

(OBLIGATIONS OF IMPORTERS AND SELLERS)

ប្រការ ១០ : ការអនុវត្តន៍បទបញ្ញត្តិដោយអ្នកនាំចូល (**COMPLIANCE BY IMPORTER**)

ការចេញរបាយការណ៍ជាក់ស្តែង (**ROF**) គឺជាភស្តុតាងមួយបញ្ជាក់ថាទំនិញបានធ្វើអធិការកិច្ចមុនពេលផ្ទុករួចហើយ ។ ការចេញរបាយការណ៍ជាក់ស្តែង (**ROF**) មិនមែនសំរាប់បន្ធូរបន្ថយអោយអ្នកនាំចូល បានប្រាសចាកពីកាតព្វកិច្ចរបស់ខ្លួន ក្នុងការគោរពច្បាប់វិន័យឬបទបញ្ញាពាក់ព័ន្ធ ទៅនឹងការនាំចូល និង ការលក់ទំនិញនៅក្នុងព្រះរាជាណាចក្រកម្ពុជានោះឡើយ ។

ប្រការ ១១ : កាតព្វកិច្ចរបស់អ្នកលក់ចំពោះអ្នកទិញ

(SELLER OBLIGATION TO IMPORTER)

អធិការកិច្ចទំនិញមុនពេលផ្ទុក (**PSI**) ដែលអនុវត្តដោយក្រុមហ៊ុនអធិការកិច្ចនោះ ពុំមានឥទ្ធិពលអ្វីទៅលើសិទ្ធិរបស់អ្នកទិញទំនិញ ដើម្បីជំទាស់ជាមួយអ្នកលក់ ហើយក៏មិនបន្ធូរបន្ថយដល់អ្នកលក់ទំនិញនូវការទទួលខុសត្រូវលើកិច្ចសន្យាចំពោះអ្នកនាំចូលទំនិញឡើយ ។

ជំពូក ៨

សារឥណទាន (LETTERS OF CREDIT)

ប្រការ ១២ : តម្រូវការ នៃសារឥណទាន (REQUIREMENTS FOR LETTERS OF CREDT)

១២.១ :ការដាក់ពាក្យសុំ

- ប្រសិនបើការទូទាត់ថ្លៃទំនិញ ធ្វើឡើងដោយសារឥណទាននោះ ការដាក់ពាក្យសុំសារឥណទានរបស់អ្នកនាំចូល ត្រូវភ្ជាប់ជាមួយនូវបញ្ជីរាយមុខទំនិញមានបញ្ជាក់អំពីយថា ប្រភេទ បរិមាណ គុណភាព និង តំលៃសរុបអោយបានច្បាស់លាស់ ។

១២.២ :ការបង់ប្រាក់តាមសារឥណទាន (Payment by letter of cerdit)

ចំពោះមុខទំនិញទាំងឡាយណា ដែលត្រូវបង់ប្រាក់តាមសារឥណទានអ្នកនិញនឹងត្រូវបង់ប្រាក់ជូនអ្នកលក់ ដរាបណាវិក័យប័ត្រច្បាប់ដើម ស្តីពីមុខទំនិញមានបិទផ្លាកសញ្ញាពាន្យមជាមួយនឹងឯកសារដឹកជញ្ជូនផ្សេងៗ ។

ជំពូក ៩

ការប្រព្រឹត្តិផ្ទុយនឹងបទបញ្ជា

ប្រការ ១៣ : ការពិន័យ

ចាប់តាំងពីថ្ងៃទី០១ ខែ តុលា ឆ្នាំ ១៩៩៥ បុគ្គលណាដែលខកខានពុំបានមកសុំធ្វើអធិការកិច្ចទំនិញមុនពេលផ្ទុក (PSI) នូវរាល់មុខទំនិញលើកលែងតែទំនិញដែលមាន ចែងក្នុងប្រការ១ ចំណុច ១.៤ ដែលត្រូវដឹកជញ្ជូនចូលមកក្នុងព្រះរាជាណាចក្រកម្ពុជា ត្រូវចាត់ទុកថា ជាអំពើផ្ទុយនឹងបទបញ្ជានេះ ហើយត្រូវទទួលពិន័យពីអាជ្ញាធរមានសមត្ថកិច្ច ។

រដ្ឋលេខាធិការ

ហត្ថលេខានិងត្រា

ស៊ុន ចាន់ថុល

២ - ទីស្តីការរដ្ឋមន្ត្រី ក្រសួងពាណិជ្ជកម្ម

ប្រកាស

រាជធានីភ្នំពេញ, ថ្ងៃទី ០២ ខែ កញ្ញា ឆ្នាំ ១៩៩៥

ប្រកាស លេខ ៣៨១ ព.ណ.ពកបប្រក

រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេច **ព្រះនរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល។
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេច **ព្រះនរោត្តមសីហនុ វរ្ម័ន** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសំរួលសមាសភាព រាជរដ្ឋាភិបាល។
- យោងអនុក្រឹត្យ ស្តីពីរបៀបរបប និងការរៀបចំការបោះឆ្នោតសភាពាណិជ្ជកម្ម របស់រាជរដ្ឋាភិបាល ចុះថ្ងៃទី ៣០ ខែ សីហា ឆ្នាំ ១៩៩៥ ។

សំរេច

ប្រការ ១ : បង្កើតគណៈកម្មការរៀបចំការបោះឆ្នោតជ្រើសរើសសមាជិកជ្រើសតាំង សភាពាណិជ្ជកម្ម ដែលមានសមាសភាពដូចខាងក្រោម :

១- ឯកឧត្តម **គុម សំ**	អនុរដ្ឋលេខាធិការក្រសួងពាណិជ្ជកម្ម	ជាប្រធាន
២- លោក **សេង រ៉ុង**	តំណាងក្រុមប្រឹក្សាអ្នកច្បាប់	ជាអនុប្រធាន
៣- លោកស្រី **ចំនួ សុរិយ៍**	តំណាងទីស្តីការគណៈរដ្ឋមន្ត្រី	ជាសមាជិក
៤- តំណាងក្រសួងមហាផ្ទៃ		ជាសមាជិក
៥- លោក **ចាន់ ឌូ**	នាយកមន្ទីរពាណិជ្ជកម្មរាជធានីភ្នំពេញ	ជាសមាជិក
៦- លោក **ឃឹម ទីន**	អនុប្រធាននាយកដ្ឋានរដ្ឋបាលទូទៅក្រសួងទេសចរណ៍	ជាសមាជិក

៧- លោក ឈឹម សាយ នាយកខុទ្ទកាល័យក្រសួងសាធារណការ និងដឹកជញ្ជូន ជាសមាជិក

៨- លោក ឈឹម ច័ន្ទកុសល តំណាងធនាគារជាតិ ជាសមាជិក

៩- លោក យឹម សំអុន តំណាងក្រសួងឧស្សាហកម្មថាមពល និងរ៉ែ ជាសមាជិក

១០-លោក គិន សេខ អនុប្រធាននាយកដ្ឋានផែនការស្ថិតិក្រសួង កសិកម្ម ជាសមាជិក

១១-លោក ម៉េង អាង តំណាងក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ជាសមាជិក

១២-លោក គីម សឿន អនុប្រធាននាយកដ្ឋានផែនការ ក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ ជាសមាជិក

១៣-លោក យូ មុនសុវណ្ណា តំណាងក្រសួងអប់រំ យុវជន និងកីឡា ជាសមាជិក

១៤-លោក ខួច សេខ តំណាងក្រសួងយុត្តិធម៌ ជាសមាជិក

១៥-លោក ម៉ៅ ថូរ៉ា ប្រធាននាយកដ្ឋានពាណិជ្ជកម្មក្រៅប្រទេស ជាលេខាធិការ

១៦-លោក ហូ សារ៉ាន់ ប្រធានការិយាល័យនីតិកម្ម ក្រសួងពាណិជ្ជកម្ម ជាលេខាធិការ

ប្រការ ២ : គណៈកម្មការរៀបចំការបោះឆ្នោតជ្រើសរើសសមាជិកជ្រើសតាំងសភាពាណិជ្ជកម្មមានភារកិច្ច :

- អនុវត្តការងារតាមមាត្រាទី ៥ របស់អនុក្រឹត្យ ស្តីពីរបៀបរបប និងការរៀបចំការបោះ ឆ្នោតសភាពាណិជ្ជកម្ម របស់រាជរដ្ឋាភិបាល ចុះថ្ងៃទី ០៣ ខែ សីហា ឆ្នាំ ១៩៩៥ ។

ប្រការ ៣ : សមាសភាពក្នុងគណៈកម្មការខាងលើ ត្រូវរួមប្រជុំតាមការអញ្ជើញរបស់ប្រធានគណៈកម្មការ ។

ប្រការ ៤ : ប្រធានមន្ទីរ ប្រធាននាយកដ្ឋានបុគ្គលិក ប្រធាននាយកដ្ឋានពាក់ព័ន្ធ របស់ក្រសួងពាណិជ្ជកម្ម និងសាមីខ្លួនត្រូវអនុវត្តតាមប្រកាសនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

ចម ប្រសិទ្ធ

* * *

៣ - ទីស្តីការរដ្ឋមន្ត្រី ក្រសួង ការបរទេស និង សហប្រតិបត្តិការអន្តរជាតិ

ប្រកាស

រាជធានីភ្នំពេញ ,ថ្ងៃទី ០៤ ខែ កញ្ញា ឆ្នាំ ១៩៩៥

ប្រកាស លេខ ០៣៣ កបខ .សអ

ស្តីពីការបង្កើតគណៈកម្មការមួយ នៅក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ១ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល និងចុះថ្ងៃទី ២៤ តុលា ១៩៩៤ ស្តីពីការតែងតាំងសំរួលសមាសភាពរាជរដ្ឋាភិបាល
- បានឃើញច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រី ដែលប្រកាស អោយប្រើតាមព្រះរាជក្រមចុះថ្ងៃទី ២០-៧-៩៤
- យោងស្មារតីសិក្ខាសាលាការងារការទូត ២៤-២៦ សីហា ១៩៩៥ ស្តីពីបង្កើតគណៈកម្មការផ្សព្វផ្សាយ
- បានឃើញការចាំបាច់របស់ក្រសួង

សំរេច

ប្រការ ១ : បង្កើតគណៈកម្មការមួយ នៅក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ដែលមានសមាសភាពដូចតទៅ ÷

- ឯកឧត្តម **ចែម ទិឡាំ** អគ្គលេខាធិការ ប្រធាន
- លោក **ហ៊ឹម ស្មើរ** ទីប្រឹក្សាមន្ត្រី អនុប្រធាន
- លោក **កែម មង្គល** ទីប្រឹក្សារដ្ឋមន្ត្រី សមាជិក
- លោក **ហោ សុធន** ប្រធាននាយកដ្ឋានសារពត៌មាន សមាជិក
- លោក **សួស សំណាង** អនុប្រធាននាយកដ្ឋានសារពត៌មាន សមាជិក
- លោក **ឌូច សែ** នាយករងរដ្ឋបាលទូទៅ សមាជិក
- លោក **នៅ ស៊ីណាត** ប្រធានការិយាល័យ សមាជិក

ប្រការ ២ : គណៈកម្មការនេះមានភារកិច្ច :

- សហការជាមួយនាយកដ្ឋានតំបន់នយោបាយក្រសួង យករបាយការណ៍ ស្តីពីសភាពការណ៍អន្តរជាតិ
- សហការជាមួយក្រសួង និងស្ថាប័ននាយកពត៌មាន ស្តីពីសភាពការណ៍ នយោបាយ សន្តិសុខ យោធាសេដ្ឋកិច្ច ។ ល ។
- សរុបសភាពការណ៍នយោបាយអន្តរជាតិ ជូនទីស្តីការគណៈរដ្ឋមន្ត្រី រៀងរាល់សប្តាហ៍ ។
- សរុបសភាពការណ៍ផ្ទៃក្នុងជាតិ និង អន្តរជាតិ រួចផ្សព្វផ្សាយជូនស្ថានឯកអគ្គរាជទូត កុងស៊ុល និងស្ថានបេសកកម្មអចិន្ត្រៃយ៍ នៃព្រះរាជាណាចក្រកម្ពុជា ប្រចាំបរទេសនៅរៀងរាល់ សប្តាហ៍ ។

ប្រការ ៣ : នាយកខុទ្ទកាល័យរដ្ឋមន្ត្រី នាយករដ្ឋបាលទូទៅ « បុគ្គលិក ហិរញ្ញវត្ថុ គណនេយ្យ » ប្រធាននាយកដ្ឋានសារពត៌មាន និងសាមីខ្លួនមានភារកិច្ច អនុវត្តប្រកាសនេះ ចាប់ពីថ្ងៃចុះ ហត្ថលេខា ។

រដ្ឋមន្ត្រី

ហត្ថលេខា និង ត្រា

អ៊ុង ហួត

៤ - ទីស្តីការរដ្ឋមន្ត្រី ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

សេចក្តីសំរេច

រាជធានីភ្នំពេញ , ថ្ងៃទី ៧ ខែ កញ្ញា ឆ្នាំ ១៩៩៥

សេចក្តីសំរេច លេខ ៥៦៧ សសរ.កសក

ស្តីពីការបង្កើតគណៈកម្មការរៀបចំគំរោងអនុវត្តប្រើប្រាស់ ថវិកាដែលជាឥណទានរបស់ធនាគារពិភពលោក

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណា ព្រះបាទសម្តេច **ព្រះនរោត្តម សីហនុ វរ្ម័ន** ព្រះ មហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជ រដ្ឋាភិបាលកម្ពុជា ។
- បានឃើញ ព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេច **ព្រះនរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា លេខ នស រកត ១០៩៤ ចុះ ថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាល កម្ពុជា ។
- បានឃើញ កិច្ចព្រមព្រៀង លើការអោយឥណទានរវាងក្រុមប្រឹក្សាជាតិជាន់ខ្ពស់ និងធនាគារពិភពលោកលេខ ២៥៥០ KH រវាងព្រះរាជាណាចក្រកម្ពុជាមួយ សមាគមអភិវឌ្ឍន៍អន្តរជាតិ ចុះថ្ងៃទី ៥ – ១១ – ៩៣ ។
- បានឃើញ អនុក្រឹត្យ លេខ ១៨ អនក្រ ចុះថ្ងៃទី ០២ ខែ តុលា ១៩៩៤ ស្តីពី តួនាទីភារកិច្ច និងរចនាសម្ព័ន្ធចាត់តាំងរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់និង នេសាទ ។
- យោងតាមការចាំបាច់របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

សំរេច

ប្រការ ១ : បង្កើតគណៈកម្មការរៀបចំគំរោងមួយដែលមានសមាសភាពដូចខាងក្រោម :

១– ឯកឧត្តម **ឈា សុខ**	រដ្ឋលេខាធិការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ	ទីប្រឹក្សា
២– ឯកឧត្តម **ច័ន្ទ តុងអ៊ីវ**	អនុរដ្ឋលេខាធិការ នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ	ប្រធាន
៣– លោក **គិត សេង**	អនុប្រធាននាយកដ្ឋានផែនការ-ស្ថិតិ	អនុប្រធាន
៤– លោក **ឡៅ នី**	មន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់. និងនេសាទ	អនុប្រធាន
៥– លោក **ឡិញ សុផល**	ប្រធានការិយាល័យសហប្រតិបត្តិការអន្តរជាតិ ទទួលបន្ទុករដ្ឋបាល	
៦– លោក **ឯម ម៉ិនធឿន**	មន្ត្រីនាយកដ្ឋានធារាសាស្ត្រឧតុនិយម និង ជលសាស្ត្រ	សមាជិក
៧– លោក **អ៊ុច សារ៉ាវុធ**	មន្ត្រីនាយកដ្ឋានក្សេត្រសាស្ត្រ	សមាជិក
៨– លោក **ឡុង ចិន្តា**	មន្ត្រីនាយកដ្ឋានផលិតកម្មបសុព្យាបាល	សមាជិក
៩– លោក **សុខ វណ្ណា**	មន្ត្រីនាយកដ្ឋានជលផល	សមាជិក
១០–លោក **ឡេង តឹកសេង**	មន្ត្រីអគ្គនាយកដ្ឋានចំការកៅស៊ូ	សមាជិក
១១–លោក **សាន វណ្ណឌី**	មន្ត្រីនាយកដ្ឋានផែនការ–ស្ថិតិ	សមាជិករាយការណ៍
១២–លោក **ហេង ឃ្មា**	មន្ត្រីនាយកដ្ឋានផែនការ–ស្ថិតិ	អ្នកវាយកុំព្យូទ័រ
១៣–លោក **ប៊ុក មុំមណ្ឌល**	មន្ត្រីនាយកដ្ឋានផែនការ–ស្ថិតិ	ជំនួយការរដ្ឋបាល

ប្រការ ២ : គណៈកម្មការនេះ មានភារកិច្ចរៀបចំគំរោងអោយបានត្រឹមត្រូវក្នុងការប្រើប្រាស់ឥណទាន ធនាគារពិភពលោក សំរាប់គំរោងស្តារ និងអភិវឌ្ឍន៍នានាតាមបណ្តាអគ្គនាយកដ្ឋាន និង នាយកដ្ឋានទាំងអស់ក្រោមឱវាទរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។

ប្រការ ៣ : ប្រធានអគ្គនាយកដ្ឋានក្រសួង អគ្គនាយកអគ្គនាយកដ្ឋានចំការកៅស៊ូ ប្រធាននាយកដ្ឋានចាត់តាំង ប្រធាននាយកដ្ឋានគណនេយ្យ ហិរញ្ញវត្ថុ ប្រធាននាយកដ្ឋាន ផែនការស្ថិតិ ប្រធាន នាយកដ្ឋានកៅស៊ូសាស្ត្រ ប្រធាននាយកដ្ឋានជលផល ប្រធាននាយកដ្ឋានធារាសាស្ត្រឧតុនិយម និង ជលសាស្ត្រ ប្រធាននាយកដ្ឋានផលិតកម្ម និងបសុព្យាបាល និងសាមីជន ដូចមានក្នុងប្រការ ១ ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសំរេចនេះ ចាប់ពីថ្ងៃ ចុះហត្ថលេខាតទៅ ។

រដ្ឋលេខាធិការ

ហត្ថលេខា និង ត្រា

ឈា សុខ

* * *

៥ - ទីស្តីការរដ្ឋមន្ត្រី ក្រសួងពត៌មាន

ប្រកាស

រាជធានី ភ្នំពេញ ,ថ្ងៃទី ០១ ខែ កញ្ញា ឆ្នាំ ១៩៩៥

ប្រកាសលេខ ២១៤/៩៥ ព.ម.ប្រក.សួន

ស្តីពីការបិទការសែត «អ្នកជាតិនិយម»

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ជំពូកអវសានបញ្ញត្តិ មាត្រាទី ១៣៩
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះបាទសម្តេច **ព្រះនរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ១ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃរាជាណាចក្រកម្ពុជា

- បានឃើញច្បាប់សារពត៌មាន ត្រូវបានរដ្ឋសភា នៃរដ្ឋកម្ពុជា អនុម័តនីតិសម័យប្រជុំវិសាមញ្ញថ្ងៃទី ៦ ខែ មេសា ឆ្នាំ ១៩៩២ នីតិកាលទី ១ ជំពូក ២ មាត្រាទី ១០ ។
- បានឃើញលិខិតអនុញ្ញាតរបស់ក្រសួងពត៌មាន លេខ ១៣០៥–៩៤ ព.ម ចុះថ្ងៃទី ២ ខែ ធ្នូ ១៩៩៤ អោយបើកកាសែត «អ្នកជាតិនិយម» ។

សំរេច

ប្រការ ១ : ដោយឃើញការមិនបានចេញផ្សាយគ្មានបញ្ជាក់មូលហេតុច្បាស់លាស់របស់កាសែត «អ្នកជាតិនិយម» ចាប់ពីឆ្នាំទី ២ លេខ ៣៦ ចុះថ្ងៃទី ២៨ ខែ មីនា ឆ្នាំ ១៩៩៥ រហូតដល់បច្ចុប្បន្ន ក្រសួងពត៌មាន សូមប្រកាសបិទកាសែតនេះជាស្ថាពរ ។

ប្រការ ២ : នាយកដ្ឋានមណ្ឌលពត៌មាន នៃក្រសួងពត៌មាន និងលោក **ឡេង ប៊ុនណា** ចាងហ្វាងការ ផ្សាយកាសែត « អ្នកជាតិនិយម » ត្រូវអនុវត្តន៍ប្រកាសនេះតាមភារកិច្ចរបស់ខ្លួន ។

ប្រការ ៣ : ប្រកាសនេះ ចូលជាធរមាន ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រដ្ឋលេខាធិការ

ហត្ថលេខា និង ត្រា

ខៀវ កាញារីទ្ធ

* * *

រាជធានីភ្នំពេញ ,ថ្ងៃទី ០៦ ខែ កញ្ញា ឆ្នាំ ១៩៩៥

ប្រកាស លេខ ២១៥/ព.ម.ប្រក.ស្តួន

ស្តីពីការបិទកាសែត «សន្តមយើង»

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ជំពូកអវសានបញ្ញត្តិ មាត្រាទី ១៣៩
- បានឃើញព្រះរាជក្រឹត្យ របស់ព្រះបាទ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រ នៃព្រះរាជា ណាចក្រកម្ពុជា ចុះថ្ងៃទី ១ វិច្ឆិកា ១៩៩៣ ស្តីពីការតែងតាំង

រាជរដ្ឋាភិបាល នៃព្រះរាជា ណាចក្រកម្ពុជា ។

- បានឃើញច្បាប់សារពត៌មាន ត្រូវបានរដ្ឋសភា នៃរដ្ឋកម្ពុជា អនុម័តនាសម័យ ប្រជុំវិសាមញ្ញ ចុះថ្ងៃទី ៦ ខែ មេសា ឆ្នាំ ១៩៩២ នីតិកាលទី ១ មាត្រាទី ១០ ។
- បានឃើញលិខិតអនុញ្ញាតិរបស់ក្រសួងពត៌មាន លេខ ១២១/៩៥ ពម.ប្រក ចុះថ្ងៃទី ១៤ ខែ មិថុនា ឆ្នាំ ១៩៩៥ អោយបើកកាសែត « សង្គមយើង » ។

សំរេច

ប្រការ ១ : ក្រសួងពត៌មានប្រកាសបិទកាសែត « សង្គមយើង »ជាស្ថាពរដោយឃើញការ ម្ចិន្តបាន ចេញផ្សាយគ្មានបញ្ជាក់អំពីមូលហេតុច្បាស់លាស់របស់កាសែត ចាប់ ពីឆ្នាំទី ២ លេខ ២២ ចុះ ថ្ងៃទី ១៧ ខែ ឧសភា ឆ្នាំ ១៩៩៥ តាមលេខកត់ត្រា លើបញ្ជីរបស់រោងពុម្ព បញ្ចពណ៌ ។

ប្រការ ២ : នាយកដ្ឋានមណ្ឌលពត៌មាន នៃក្រសួងពត៌មាន និងលោក **ឆន់ ម៉ុនលី** ចាងហ្វាងការផ្សាយកាសែត «សង្គមយើង » ត្រូវអនុវត្តប្រកាសនេះតាមភារកិច្ច របស់ខ្លួន ។

ប្រការ ៣ : ប្រកាសនេះចូលជាធរមាន ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រដ្ឋលេខាធិការ

ហត្ថលេខា និង ត្រា

ខៀវ កាញារីទ្ធ

* * *

រាជធានីភ្នំពេញ ,ថ្ងៃទី ០២ ខែ កញ្ញា ឆ្នាំ ១៩៩៥

ប្រកាស លេខ ២១៦/៩៥ ពម.ប្រក

ស្តីពីការអនុញ្ញាតអោយកាសែត «ថ្ងៃនេះ» បោះពុម្ពផ្សាយ

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ជំពូកអវសានបញ្ញត្តិ មាត្រាទី ១៣៩
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះបាទសម្តេច **ព្រះនរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ វិច្ឆិកា ឆ្នាំ ១៩៩៣

ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញច្បាប់សារពត៌មាន ដែលរដ្ឋសភា នៃរដ្ឋកម្ពុជាអនុម័ត នាសម័យប្រជុំសាមញ្ញ ថ្ងៃទី ៦ ខែ មេសា ឆ្នាំ ១៩៩២ នីតិកាលទី ១
- បានឃើញលិខិតស្នើសុំរបស់លោក អ៊ុច ឧត្តី ចាងហ្វាងការផ្សាយកាសែត «ថ្ងៃនេះ» ចុះ ថ្ងៃទី ២៦ ខែ ឧសភា ឆ្នាំ ១៩៩៥

សំរេច

ប្រការ ១ : អនុញ្ញាតអោយកាសែត «ថ្ងៃនេះ» បោះពុម្ពផ្សាយដោយមានលោក **អ៊ុច ឧត្តី** ជាចាងហ្វាង ការផ្សាយ ។

ប្រការ ២ : ខ្លឹមសារអត្ថបទ និងសកម្មភាពផ្សព្វផ្សាយត្រូវសមស្របតាមទំនៀមទំលាប់ប្រពៃណីល្អ និង ច្បាប់ នៃព្រះរាជាណាចក្រកម្ពុជា ។

ប្រការ ៣ : គោរពតាមគោលការណ៍សីលធម៌ អ្នកកាសែត និងឈរលើស្មារតីទទួលខុសត្រូវខ្ពស់លើ វិជ្ជាជីវៈរបស់ខ្លួនព្រមទាំង ស្នើប្រគល់កាសែតចំនួន ១៥ ច្បាប់រៀងរាល់លេខ ចេញផ្សាយមក តំកល់ទុកជាឯកសារនៅក្រសួងពត៌មាន ។

ប្រការ ៤ : លោក **អ៊ុច ឧត្តី** ចាងហ្វាងការផ្សាយសារពត៌មាន « ថ្ងៃនេះ » និងនាយកដ្ឋានមណ្ឌល ពត៌មាន នៃក្រសួងពត៌មាន ត្រូវអនុវត្តនូវប្រកាសនេះ ។

ប្រកាស ៥ : ប្រកាសនេះ ចូលជាធរមាន ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រដ្ឋមន្ត្រី
ហត្ថលេខា និង ត្រា
អៀង មូលី

* * *

រាជធានីភ្នំពេញ ,ថ្ងៃទី ០៤ ខែ កញ្ញា ឆ្នាំ ១៩៩៥

ប្រកាស លេខ ២១៧/៩៥ ពម.ប្រក.ស្ចន

ស្តីពីការបិទកាសែត «អ្នកប្រជាធិបតេយ្យ»

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ជំពូកអវសានបញ្ញត្តិ មាត្រាទី ១៣៩

- បានឃើញព្រះរាជក្រឹត្យរបស់ព្រះបាទសម្តេច **ព្រះនរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ១ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃ ព្រះរាជាណាចក្រកម្ពុជា
- បានឃើញច្បាប់សារពត៌មាន ត្រូវបានរដ្ឋសភា នៃរដ្ឋកម្ពុជាអនុម័តនាសម័យប្រជុំវិសាមញ្ញ ថ្ងៃទី ៦ ខែ មេសា ឆ្នាំ ១៩៩២ នីតិកាលទី ១ ជំពូក ២ មាត្រាទី ១៦ ។
- បានឃើញលិខិតអនុញ្ញាត របស់ក្រសួងពត៌មានលេខ ១២៤៤ – ៩៤ ព.ម. ចុះថ្ងៃទី ២២ វិច្ឆិកា ឆ្នាំ ១៩៩៤ អោយបើកកាសែត « អ្នកប្រជាធិបតេយ្យ » ។

សំរេច

ប្រការ ១ : ដោយឃើញការមិនបានចេញផ្សាយ ដោយគ្មានបញ្ជាក់មូលហេតុច្បាស់លាស់ របស់កាសែត «អ្នកប្រជាធិបតេយ្យ» ចាប់ពីឆ្នាំទី ១ លេខ ១៥ ចុះថ្ងៃទី ១២ ខែ ធ្នូ ឆ្នាំ ១៩៩៤ រហូតដល់បច្ចុប្បន្ន ក្រសួងពត៌មាន សូមប្រកាស បិទកាសែតនេះជាស្ថាពរ ។

ប្រការ ២ : នាយកដ្ឋានមណ្ឌលពត៌មាន នៃក្រសួងពត៌មាន និងអ្នកអង្គម្ចាស់ **នរោត្តម នរិន្ទ្រ រិទ្ធិវង្ស** ចាងហ្វាងការផ្សាយកាសែត « អ្នកប្រជាធិបតេយ្យ » ត្រូវអនុវត្តប្រកាសនេះតាមភារកិច្ចរបស់ ខ្លួន ។

ប្រការ ៣ : ប្រកាសនេះចូលជាធរមាន ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រដ្ឋលេខាធិការ

ហត្ថលេខា និង ត្រា

ខៀវ កាញារីទ្ធ

* * *

រាជធានីភ្នំពេញ ,ថ្ងៃទី ០៦ ខែ កញ្ញា ឆ្នាំ ១៩៩៥

ប្រកាស លេខ ២១៨/៩៥ ពម.ប្រក

ស្តីពីការយល់ព្រមអោយមន្ត្រីរាជការ

តាំងសិប់ក្នុងក្របខ័ណ្ឌក្រសួង

- បានឃើញព្រះរាជក្រឹត្យព្រះករុណា ព្រះបាទសម្តេចព្រះនរោត្តម **សីហនុ វរ្ម័ន** ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០៦ ន.ស ៩៤ ចុះថ្ងៃទី ១០ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការ អោយប្រើប្រាស់សហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល
- យោងសេចក្តីសំរេច លេខ ៦៤៩ សសរ.មស.ក្រខ ចុះថ្ងៃទី ០១ ខែ សីហា ឆ្នាំ ១៩៩៤ របស់រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ
- ពិនិត្យលើលក្ខណៈសម្បត្តិរបស់សាមីខ្លួន

សំរេច

ប្រការ ១ : យល់ព្រមផ្ទេរមន្ត្រីរាជការចំនួន ០៣ នាក់ អោយតាំងស៊ប់ក្នុងក្របខ័ណ្ឌក្រសួងពត៌មាន ដូចមានរាយនាមខាងក្រោម ÷

១- លោក **ស៊ៀង ចណ្ណថារ៉ា** ថ្នាក់មធ្យម

២- អ្នកស្រី **នុប ទេវិតចំនួសុគារី** ថ្នាក់មធ្យម

៣- លោក **ឃឿន សេងហាក់** កម្មករជំនាញ

ប្រការ ២ : ប្រាក់បៀវត្ស និង ប្រាក់ឧបត្ថម្ភផ្សេងៗ របស់សាមីខ្លួន ត្រូវទទួលនៅទីស្តីការរដ្ឋមន្ត្រី ចាប់ពី ថ្ងៃទី ០១ ខែ កញ្ញា ឆ្នាំ ១៩៩៥ នេះតទៅ ។

ប្រការ ៣ : នាយកដ្ឋានបុគ្គលិក និងរដ្ឋបាល នាយកដ្ឋានផែនការគណនេយ្យ និង ហិរញ្ញវត្ថុ និង សាមីខ្លួនមានភារៈអនុវត្តប្រកាស ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រដ្ឋមន្ត្រី

ហត្ថលេខា និង ត្រា

អៀង មូលី

* * *

រាជធានីភ្នំពេញ ,ថ្ងៃទី ០៦ ខែ កញ្ញា ឆ្នាំ ១៩៩៥

ប្រកាស លេខ ២២៣ /៩៥ ព.ម

អនុញ្ញាតអោយសារពត៌មាន «ភ្លើពេញពិភពលោក»ដំណើរការបោះពុម្ពផ្សាយ

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ជំពូកអវសានបញ្ញត្តិ មាត្រាទី ១៣៩
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រ នៃ ព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញច្បាប់សារពត៌មាន ត្រូវបានរដ្ឋសភា នៃរដ្ឋកម្ពុជា អនុម័តនាសម័យប្រជុំវិសាមញ្ញ ថ្ងៃទី ០៦ ខែ មេសា ឆ្នាំ ១៩៩២ នីតិកាលទី ០១
- បានឃើញសំណើសុំបើកសារពត៌មានឈ្មោះ « ភ្នំពេញពិភពលោក » របស់លោក ពេជ រចនា ចុះថ្ងៃទី ១៧ ខែ សីហា ឆ្នាំ ១៩៩៥

សំរេច

ប្រការ ១ : អនុញ្ញាតអោយសារពត៌មានឈ្មោះ « ភ្នំពេញពិភពលោក » បកប្រែពីភាសាអង់គ្លេស និងភាសាថៃ លើវិស័យបច្ចេកទេសវិទ្យាសាស្រ្ត វប្បធម៌ និងអប់រំ ដំណើរការបោះពុម្ពផ្សាយដោយ មានលោក **ពេជ រចនា** ជាចាងហ្វាងការផ្សាយ ។

ប្រការ ២ : អត្ថបទទាំងឡាយណាផ្សេងៗ ទៀតក្រៅអំពីវិស័យបច្ចេកទេស វិទ្យាសាស្រ្ត វប្បធម៌ និងអប់រំ ត្រូវហាមឃាត់ ។

ប្រការ ៣ : ខ្លឹមសារអត្ថបទ និងកម្មភាពផ្សព្វផ្សាយ ត្រូវសមស្របតាមទំនៀមទំលាប់ប្រពៃណីល្អ និង ច្បាប់ នៃព្រះរាជាណាចក្រកម្ពុជា ។

ប្រការ ៤ : គោរពតាមគោលការណ៍ក្រមសីលធម៌ អ្នកកាសែត និងឈរលើស្មារតី ទទួលខុសត្រូវខ្ពស់លើ វិជ្ជាជីវៈរបស់ខ្លួន ហើយស្នើប្រគល់កាសែតចំនួន ០៦ ច្បាប់ រៀងរាល់លេខចេញផ្សាយ ដើម្បី តំកល់ទុកជាឯកសារនៅក្រសួងពត៌មាន ។

ប្រការ ៥ : លោក **ពេជ រចនា** ចាងហ្វាងការផ្សាយកាសែត « ភ្នំពេញពិភពលោក » និងនាយកដ្ឋាន មណ្ឌលពត៌មាន នៃក្រសួងពត៌មាន ត្រូវអនុវត្តនូវប្រកាសនេះ ។

ប្រការ ៦ : ប្រកាសនេះចូលជាធរមាន ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រដ្ឋលេខាធិការ

ហត្ថលេខា និង ត្រា

ខៀវ កាញារីទ្ធ

* * *

៦ - ទីស្តីការរដ្ឋមន្ត្រី ក្រសួងសាធារណការ និង ដឹកជញ្ជូន

ប្រកាស

ភ្នំពេញ,ថ្ងៃទី ០៧ ខែ កញ្ញា ឆ្នាំ ១៩៩៥

ប្រកាសលេខ ៦២៩ ប្រក.សក.ខ

បដិសេធប្រកាស លេខ ៦១៥ ប្រក.សក.ហវ ចុះថ្ងៃទី ២៦.៨.១៩៩៥

ស្តីពីការរុះរើសាងសង់អាគារឃ្លាំង នៅរោងចក្ររដ្ឋទី១ និងប្តូរប្រព័ន្ធផលិត រដ្ឋក្បឿង នៅដា សិប្បកម្មកាត់ដេរ

ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា ចុះថ្ងៃទី ០១-១១-៩៣ ។
- បានឃើញព្រះរាជក្រឹត្យលេខ នស/ រកត / ១០.៩៤ / ៨៣ ចុះថ្ងៃទី ២៤-១០-១៩៩៤ ស្តីពីការកែសម្រួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា ។
- បានឃើញប្រកាសលេខ ៦១៥ ប្រក.សក.ហវ ចុះថ្ងៃទី ២៦-៨-១៩៩៥ ។

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ជំពូកអវសានបញ្ញត្តិ មាត្រាទី ១៣៩
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រ នៃ ព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញច្បាប់សារពត៌មាន ត្រូវបានរដ្ឋសភា នៃរដ្ឋកម្ពុជា អនុម័តនាសម័យប្រជុំវិសាមញ្ញ ថ្ងៃទី ០៦ ខែ មេសា ឆ្នាំ ១៩៩២ នីតិកាលទី ០១
- បានឃើញសំណើសុំបើកសារពត៌មានឈ្មោះ « ភ្នំពេញពិភពលោក » របស់លោក ពេជ រចនា ចុះថ្ងៃទី ១៧ ខែ សីហា ឆ្នាំ ១៩៩៥

សំរេច

ប្រការ ១ : អនុញ្ញាតអោយសារពត៌មានឈ្មោះ « ភ្នំពេញពិភពលោក » បកប្រែពីភាសាអង់គ្លេស និងភាសារថៃ លើវិស័យបច្ចេកទេសវិទ្យាសាស្ត្រ វប្បធម៌ និងអប់រំ ដំណើរការបោះពុម្ពផ្សាយដោយ មានលោក **ពេជ រចនា** ជាចាងហ្វាងការផ្សាយ ។

ប្រការ ២ : អត្ថបទទាំងឡាយណាផ្សេងៗ ទៀតក្រៅអំពីវិស័យបច្ចេកទេស វិទ្យាសាស្ត្រ វប្បធម៌ និងអប់រំ ត្រូវហាមឃាត់ ។

ប្រការ ៣ : ខ្លឹមសារអត្ថបទ និងកម្មភាពផ្សព្វផ្សាយ ត្រូវសមស្របតាមទំនៀមទំលាប់ប្រពៃណីល្អ និង ច្បាប់ នៃព្រះរាជាណាចក្រកម្ពុជា ។

ប្រការ ៤ : គោរពតាមគោលការណ៍ក្រមសីលធម៌ អ្នកកាសែត និងឈរលើស្មារតី ទទួលខុសត្រូវខ្ពស់លើ វិជ្ជាជីវៈរបស់ខ្លួន ហើយស្នើប្រគល់កាសែតចំនួន ០៦ ច្បាប់ រៀងរាល់លេខចេញផ្សាយ ដើម្បី តំកល់ទុកជាឯកសារនៅក្រសួងពត៌មាន ។

ប្រការ ៥ : លោក **ពេជ រចនា** ចាងហ្វាងការផ្សាយកាសែត « ភ្នំពេញពិភពលោក » និងនាយកដ្ឋាន មណ្ឌលពត៌មាន នៃក្រសួងពត៌មាន ត្រូវអនុវត្តនូវប្រកាសនេះ ។

ប្រការ ៦ : ប្រកាសនេះចូលជាធរមាន ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រដ្ឋលេខាធិការ

ហត្ថលេខា និង ត្រា

ខៀវ កាញារីទ្ធ

* * *

៦ - ទីស្តីការរដ្ឋមន្ត្រី ក្រសួងសាធារណការ និង ដឹកជញ្ជូន

ប្រកាស

ភ្នំពេញ,ថ្ងៃទី ០៧ ខែ កញ្ញា ឆ្នាំ ១៩៩៥

ប្រកាសលេខ ៦២៩ ប្រក.សក.ខ

បដិសេធប្រកាស លេខ ៦១៥ ប្រក.សក.ហវ ចុះថ្ងៃទី ២៦.៨.១៩៩៥

ស្តីពីការប្រើសាងសង់អគារឃ្លាំង នៅកោងចក្ររដ្ឋទី១ និងអ្នកប្រូពំនួផលិត រដ្ឋកៅស៊ូ ទៅជា សិប្បកម្មកាត់ដេរ

ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា ចុះថ្ងៃទី ០១-១១-៩៣ ។
- បានឃើញព្រះរាជក្រឹត្យលេខ នស/ រកត / ១០.៩៤ / ៨៣ ចុះថ្ងៃទី ២៤-១០-១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា ។
- បានឃើញប្រកាសលេខ ៦១៥ ប្រក.សក.ហវ ចុះថ្ងៃទី ២៦-៨-១៩៩៥ ។

សំរេច

ប្រការ ១ : បដិសេធលុបចោលប្រកាសលេខ ៦១៥ ប្រក.សក.ហវ ចុះថ្ងៃទី ២៦-៨-១៩៩៥ ដែល អនុញ្ញាត អោយរុះរើសាងសង់អាគារឃ្លាំង នៅរោងចក្រអិដ្ឋទី ១ និង ប្តូរប្រព័ន្ធសិប្បកម្មអិដ្ឋ ក្បឿង ទៅជាសិប្បកម្មកាត់ដេរដោយអសមត្ថភាព ។

ប្រការ ២ : បទបញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងសេចក្តីប្រកាសនេះត្រូវទុកជានិរាករណ៍ ។

ប្រការ ៣ : ឯកឧត្តមអនុរដ្ឋលេខាធិការទទួលបន្ទុកការងារសំណង់ លោកអគ្គនាយក នាយកខុទ្ទកាល័យ អគ្គនាយកដ្ឋានសំណង់ នាយកដ្ឋាននគរោបនីយកម្ម និងលំនៅដ្ឋាន-នាយកាវិយាល័យគណនេយ្យ ហិរញ្ញវត្ថុ និង ជំរះបញ្ជី នាយកដ្ឋានផែនការ-ហិរញ្ញវត្ថុ នៃអគ្គនាយកដ្ឋានសំណង់ ភាគី ផ្លូលរោងចក្រអិដ្ឋទី១ ត្រូវទទួលបន្ទុក និងអនុវត្តប្រកាសនេះរៀងខ្លួន អោយមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ឧបនាយករដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសាធារណការនិងដឹកជញ្ជូន
ហត្ថលេខា និងត្រា
អ៊ឹង គៀត

* * *

៧ - ទីស្តីការរដ្ឋមន្ត្រី ក្រសួងអប់រំ យុវជន និង កីឡា

ប្រកាស

ភ្នំពេញ,ថ្ងៃទី ០១ ខែ កញ្ញា ឆ្នាំ ១៩៩៥

ប្រកាស

លេខ ១៣៦១ អយក.ប្រក

ស្តីពីការប្តូរឈ្មោះវិទ្យាល័យ ថ្នល់កែង ក្នុងស្រុកកំចាយមារ
ខេត្តព្រៃវែង ទៅជា « វិទ្យាល័យ ស ខេង »

រដ្ឋមន្ត្រីក្រសួងអប់រំយុវជននិងកីឡា

- បានឃើញព្រះរាជក្រឹត្យ របស់ព្រះករុណាព្រះបាទសម្តេចព្រះបាទ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ១៩៩៣ ស្តីពីការតែងតាំងរាជ រដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើ ដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- បានឃើញក្រឹត្យ–ច្បាប់លេខ ៣០ ក្រច ចុះថ្ងៃទី ២០ ខែ វិច្ឆិកា ឆ្នាំ ១៩៨៦ ស្តីពីប្រព័ន្ធ អប់រំចំនេះទូទៅ
- បានឃើញសេចក្តីសំរេចលេខ ២៨២ អរ.សសរ ចុះថ្ងៃទី ៨ ធ្នូ ១៩៩០ ស្តីពីការបើកវិទ្យាល័យនៅក្នុងខេត្តព្រៃវែង
- តាមសំណើរបស់ប្រធានការិយាល័យអប់រំយុវជន និង កីឡាស្រុកកំចាយមារស្តីពីការសុំប្តូរឈ្មោះវិទ្យាល័យថ្នល់កែងទៅជា «វិទ្យាល័យ **ស ខេង** » តាមរយៈប្រធានមន្ទីរអប់រំយុវជន និង អភិបាលខេត្តព្រៃវែង

សំរេច

ប្រការ ១ : អនុញ្ញាតអោយប្តូរឈ្មោះវិទ្យាល័យថ្នល់កែងក្នុងស្រុកកំចាយមារ ខេត្តព្រៃវែង ទៅជា «វិទ្យាល័យ **ស ខេង** » ចាប់ពីបវេសនកាលឆ្នាំសិក្សា ១៩៩៥–៩៦ ។

ប្រការ ២ : បទបញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

ប្រការ ៣ : ប្រធានមន្ទីរ ប្រធាននាយកដ្ឋានចំនេះទូទៅ និង មត្តេយ្យសិក្សា ប្រធាននាយកដ្ឋាន បុគ្គលិក និង ប្រធាននាយកដ្ឋានផែនការ និង ហិរញ្ញកិច្ចនៃក្រសួងអប់រំយុវជន និង កីឡា មានភារកិច្ច រៀងៗខ្លួនអនុវត្តប្រកាសនេះ ។

រដ្ឋលេខាធិការ

ហត្ថលេខានិងត្រា

គា សាវាន

ភ្នំពេញ , ថ្ងៃទី ០២ ខែ កញ្ញា ឆ្នាំ ១៩៩៥

ប្រកាស

លេខ : ១៣៩៤ អយក.ប្រក

ស្តីពីការប្តូរឈ្មោះ អនុវិទ្យាល័យ ស្រវែង ក្នុងស្រុក ព្រៃឈរ

ខេត្តកំពង់ចាម ទៅជា «អនុវិទ្យាល័យ ស្រេង គីម»

រដ្ឋមន្ត្រីក្រសួងអប់រំយុវជននិងកីឡា

- បានឃើញព្រះរាជក្រឹត្យ របស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជ រដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើ ដោយព្រះរាជក្រម ចុះថ្ងៃទី ២០ កក្កដា ១៩៩៤
- បានឃើញក្រឹត្យ–ច្បាប់លេខ ៣០ ក្រច ចុះថ្ងៃទី ២០ វិច្ឆិកា ១៩៨៦ ស្តីពីប្រព័ន្ធអប់រំថ្មីនេះ ទូទៅ ។
- បានឃើញសេចក្តីសំរេចលេខ ១៦៨ អរ.សសរ ចុះថ្ងៃទី ១២ កញ្ញា ១៩៨៨ ស្តីពីការបើក សាលាមធ្យមសិក្សាកំរិត ១ នៅក្នុងខេត្តកំពង់ចាម ។
- តាមសំណើរបស់សមាគមមាតាបិតាសិស្ស ស្តីពីការសុំប្តូរឈ្មោះអនុវិទ្យាល័យស្រវែងទៅជា « អនុវិទ្យាល័យ ស្រេង គីម » តាមរយៈប្រធានមន្ទីរអប់រំយុវជន និងកីឡា និង អភិបាល ខេត្តកំពង់ចាម ។

សំរេច

ប្រការ ១ : អនុញ្ញាតអោយប្តូរឈ្មោះអនុវិទ្យាល័យ ស្រវែង ក្នុងស្រុកព្រៃឈរ ខេត្តកំពង់ចាម ទៅជា «អនុវិទ្យាល័យ **ស្រេង គីម** » ចាប់ពីបវេសនកាលឆ្នាំសិក្សា ១៩៩៥ - ៩៦ តទៅ ។

ប្រការ ២ : បទបញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

ប្រការ ៣ : ប្រធានមន្ទីរ ប្រធាននាយកដ្ឋានចំនេះទូទៅ និងមធ្យមសិក្សា ប្រធាននាយកដ្ឋានបុគ្គលិកនិង ប្រធាននាយកដ្ឋានផែនការ និងហិរញ្ញកិច្ច នៃក្រសួងអប់រំ យុវជន និងកីឡា មានភារកិច្ចរៀងៗខ្លួនអនុវត្តប្រកាសនេះ ។

រដ្ឋមន្ត្រី

ហត្ថលេខានិងត្រា

តុល ឡោះ

* * *

៤ - ទីស្តីការរដ្ឋមន្ត្រី ក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ

ប្រកាស

រាជធានីភ្នំពេញ,ថ្ងៃទី ០៦ ខែ កញ្ញា ឆ្នាំ ១៩៩៥

ប្រកាសលេខ : ១៥៤ ប្រក.វវស.ម

ស្តីពីការផ្លាស់ប្តូរកន្លែងធ្វើការរបស់មន្ត្រី

រាជការមន្ទីរវប្បធម៌ និងវិចិត្រសិល្បៈខេត្តកំពង់ចាម

រដ្ឋមន្ត្រី ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រនៃព្រះ រាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល កម្ពុជា
- យោងតាមសំណើសុំផ្លាស់ប្តូរកន្លែងធ្វើការរបស់លោក ឃួយ ញ៉ុល បុគ្គលិកមន្ទីរ វប្បធម៌ និងវិចិត្រសិល្បៈ ខេត្តកំពង់ចាម
- យោងតាមការឯកភាពយល់ព្រមពីថ្នាក់ដឹកនាំក្រសួងចុះថ្ងៃទី ២៧ ខែ កក្កដា ឆ្នាំ

សំរេច

មាត្រា ១ : លោក **ឃួយ ញឿល** បុគ្គលិក នៃមន្ទីរវប្បធម៌ និងវិចិត្រសិល្បៈ ខេត្ត កំពង់ចាម ត្រូវបានអនុញ្ញាតអោយផ្លាស់មកបំរើការងារនៅនាយកដ្ឋានបុគ្គលិក នៃក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ ។

មាត្រា ២ : មន្ទីរវប្បធម៌និងវិចិត្រសិល្បៈខេត្តកំពង់ចាម ត្រូវផ្ទេរប្រាក់បៀវត្ស របបឧបត្ថម្ភ ផ្សេង ៗ របស់ សាមីខ្លួន និងក្របខ័ណ្ឌមួយកន្លែងជូនក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ ។

មាត្រា ៣ : ខុទ្ទកាល័យ អគ្គនាយកដ្ឋានរដ្ឋបាល មន្ទីរវប្បធម៌និងវិចិត្រសិល្បៈ ខេត្ត កំពង់ចាម និងលោក **ឃួយ ញឿល** មានភារកិច្ចអនុវត្តប្រកាសនេះ ។

រដ្ឋមន្ត្រី

ហត្ថលេខានិងត្រា

នុត ណារ៉ាង

* * *

៩ - ទីស្ដីការគណៈរដ្ឋមន្ត្រី ក្រសួង ស្ថាប័ន

[illegible]

[illegible]

[illegible] កញ្ញា [illegible]

[illegible]

[illegible]

ថ្ងៃទី ២៣-១១-១៩៩៤

ដើម្បីធានាប្រសិទ្ធភាពក្នុងការអនុវត្ត [illegible] លេខ ៥៧ អនក្រ.បក ចុះថ្ងៃទី ១២-៦-៩៥ ដែលកំណត់យកថ្ងៃទី ២៣ [illegible] ជារៀងរាល់ ឆ្នាំជាទិវាអនាម័យបរិស្ថានជាតិ ក្រសួង [illegible] ជំរាបមកគ្រប់ក្រសួង

រដ្ឋលេខាធិការដ្ឋាន អភិបាលខេត្ត-ក្រុងអោយបានជ្រាបថា នៅថ្ងៃទី ២៣ ខែ វិច្ឆិកា ឆ្នាំ ១៩៩៥ ខាងមុខនេះ ជាឆ្នាំទី១ នៃការចាប់ផ្តើមអនុវត្តអនុក្រឹត្យនេះ ។

ដូច្នេះ ដើម្បីអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អប្រសើរ ក្រសួងសូមលើកឡើងនូវគោលការណ៍ណែនាំអនុវត្តលើខ្លឹមសារមួយចំនួនដូចតទៅ :

I <u>**អំពីគោលបំណងនិងសំណូមពរ**</u> :

១-<u>គោលបំណង</u> :

- ដើម្បីរួមចំណែកអនុវត្តអោយកាន់តែមានប្រសិទ្ធភាព ចលនាប្រឡងប្រណាំង កែលំអសោភ័ណភាព ខេត្ត-ក្រុង ទូទាំងប្រទេស ។
- ដើម្បីរួមវិភាគទាន ក្នុងកិច្ចការពារ និង ថែរក្សាគុណភាពបរិដ្ឋាន ព្រមទាំងរាំងស្កាត់រាល់ សកម្មភាពអសកម្មប៉ះពាល់ដល់កិច្ចគាំពារ សុខមាលភាពប្រជារាស្ត្រ ក្នុងទិសដៅជំរុញការ លើកកំពស់ជីវភាពខាងសំភារៈ និងខាងស្មារតីបំរើតម្រូវ ការសង្គម ។
- អប់រំប្រជាពលករអោយមានស្មារតីភ្ញាក់រលឹក យល់ដឹងអំពីសារប្រយោជន៍ នៃការគាំពារគុណភាពបរិដ្ឋាន អំពីភាពចាំបាច់នៃការកែលំអសោភ័ណ្ឌភាពខេត្ត-ក្រុង ។
- បង្ហាញអោយប្រជាពលរដ្ឋយល់ច្បាស់ថា ការលើកកំពស់គុណភាពបរិដ្ឋាន និងការកែលំអ សោភ័ណភាពខេត្ត-ក្រុង វាជាភារកិច្ចរួមរបស់ជនរួមជាតិគ្រប់រូប និងគ្រប់ស្ថាប័នទាំងអស់ ។

២-<u>សំណូមពរ</u> :

ដើម្បីសំរេចបានលទ្ធផលជាវិជ្ជមានក្នុងទិវាអនាម័យបរិដ្ឋានជាតិ នៅថ្ងៃទី ២៣ ខែ វិច្ឆិកា ឆ្នាំ ១៩៩៥ ខាងមុខនេះ ក្រសួងគ្រប់គ្រងបរិដ្ឋាន ចាត់តាំងអោយគ្រប់មន្ទីរគ្រប់គ្រងបរិដ្ឋានខេត្ត-ក្រុង ជូនយោបល់អភិបាលខេត្ត-ក្រុង រៀបចំផែនការកម្មវិធីអោយបានច្បាស់លាស់ គួបផ្សំដោយការបំផុសចលនា ប្រជាពលករ ព្រះសង្ឃ កងកំលាំងប្រដាប់អាវុធ មន្ត្រីរាជការ សិស្ស និស្សិតគ្រប់ភូមិសិក្សា អាជីវករគ្រប់ផ្នែកអោយបានច្រើនកុះករចូលរួមធ្វើពលកម្មអនាម័យ រៀបចំសួនច្បារ សួនកំសាន្ត ទីលានសាធារណៈលំនៅដ្ឋាន និងត្រៀមលក្ខណៈ

ឧបករណ៍ សំភារៈ ផែនការ ចាត់តាំងអនុវត្តអោយបានច្បាស់លាស់ និងម៉ត់ចត់ ។

II - ការចាត់តាំងអនុវត្ត :

–ក្រសួងគ្រប់គ្រងបរិដ្ឋាន សហការជាមួយគណៈកម្មាធិការរៀបចំបុណ្យជាតិអន្តរជាតិ គណៈ កម្មាធិការជាតិកែលំអសោភ័ណភាពខេត្ត-ក្រុង ធ្វើផែនការកម្មវិធីជាក់ស្តែងសំរាប់បណ្តាក្រសួង រដ្ឋលេខាធិការដ្ឋានក្នុងការធ្វើអនាម័យ នេះ ។

មន្ទីរគ្រប់គ្រងបរិដ្ឋានខេត្ត-ក្រុង ធ្វើជាសេនាធិការអោយអភិបាលខេត្ត-ក្រុង ក្នុងការរៀបចំផែនការកម្មវិធីអនុវត្ត ដោយយោលទៅលើផែនការរបស់ អនុគណៈកម្មការប្រឡងប្រណាំង កែលំអសោភ័ណ្ឌភាពខេត្ត-ក្រុង ។ ទន្ទឹមនេះក៏ត្រូវសុំយោបល់ឯកភាពពីអភិបាលខេត្ត-ក្រុង និងសហការអោយបានល្អជាមួយគ្រប់ មន្ទីរ ស្ថាប័ន និងរដ្ឋអំណាចមូលដ្ឋាន ។

ដើម្បីធានាប្រសិទ្ធភាពក្នុងការអនុវត្តន៍ទិវាអនាម័យបរិដ្ឋានជាតិ ក្រសួងស្នើលើកឡើងនូវវិធាន ការជាក់ស្តែងមួយចំនួន ដើម្បីគួបផ្សំជាមួយគំនិតច្នៃប្រឌិតបន្ថែមរបស់មូលដ្ឋានជូនមកគ្រប់មន្ទីរបរិដ្ឋាន ខេត្ត-ក្រុង ដូចតទៅ ÷

១–<u>ការធ្វើផែនការអនុវត្ត</u> :

ចលនានេះ ចាប់ផ្តើមអនុវត្តចាប់ពីពេលនេះទៅ ដោយឆ្លៀតយករាល់ព្រឹកថ្ងៃសៅរ៍បំផុសការងារអនាម័យនេះ ឈានទៅអបអរសាទរទិវាអនាម័យបរិដ្ឋានជាតិ ២៣ វិច្ឆិកា ដែលជាថ្ងៃផ្តាច់ព្រ័ត ប្រចាំឆ្នាំនីមួយ ៗ ។

<u>ផែនការសំខាន់ៗមាន</u> :

–បំផុសចលនាប្រជាពលរដ្ឋ ព្រះសង្ឃ កងយោធពលខេមរភូមិន្ទ នគរបាល អ្នករាជការគ្រប់ថ្នាក់ គ្រប់ផ្នែក សិស្សនិសិត្សគ្រប់ភូមិសិក្សាចូលរួមធ្វើពលកម្មអនាម័យ រៀងរាល់ព្រឹកថ្ងៃសៅរ៍ ។ ទន្ទឹមនេះ ត្រូវមានផែនការកម្មវិធីច្បាស់លាស់សំរាប់អនុវត្តតាមដំណាក់កាលនីមួយ ៗ ។

–ចាត់តាំងអង្គមិទ្ទិញមហាជន នៅថ្ងៃទី ២៣ វិច្ឆិកា រៀងរាល់ឆ្នាំ

–ត្រៀមលក្ខណៈសម្បត្តិ ឧករណ៍ សំភារៈ មធ្យោបាយផ្សេង ៗ អោយបានគ្រប់គ្រាន់

–បែងចែកមុខសញ្ញា និងតំបន់ពលកម្ម អនាម័យអោយបានច្បាស់លាស់

-រៀបចំសមាសភាព គណៈកម្មការបោះឆ្នោត និង [illegible] ព្រមទាំងជ្រើសរើស កន្លែងបោះឆ្នោតអោយបានគ្រប់គ្រាន់ ។

-ប្តូរសម្ភារៈ [illegible] ក្រសួង និងស្ថាប័នពាក់ព័ន្ធ [illegible] លទ្ធផលការងារ ។

២-ការរៀបចំអង្គមិទ្ទិញមហាជន និង [illegible]

[illegible]

-ថ្នាក់ដឹកនាំខេត្ត ក្រុង

-ថ្នាក់ដឹកនាំក្រសួងពាក់ព័ន្ធ

-មន្ត្រីរាជការខេត្ត ក្រុង

-សិស្ស និស្សិត គ្រូបង្រៀន

-ប្រជាពលរដ្ឋ

ម៉ោង : 7h 30 - 8h 30

[illegible] 8h 30 - 11h 30

៣-ខ្លឹមសារ [illegible]

-[illegible]

-[illegible]

[illegible]

-ជូសជុលរៀបចំសួនឧទ្យាន សួនលំហែដែលមានស្រាប់ និងបង្កើតថ្មីសំរាប់ការសំរាកលំហែ របស់ពលរដ្ឋតាមទីប្រជុំជន និងកន្លែងដែលអាចធ្វើបាន ។

-ត្រូវជ្រើសរើសរកកន្លែងចាក់សំរាមអោយបានសមរម្យ

-ត្រូវបំផុសប្រជាជនអោយចូលរួមធ្វើអនាម័យនៅតាមលំនៅដ្ឋានរបស់ខ្លួនអោយបានស្អាត ជានិច្ច ។

-តូបលក់ឥវ៉ាន់តាមទីផ្សារត្រូវកំណត់អោយអ្នកម្ចាស់តូប ម្ចាស់ការក្នុងការបោសសំអាត និង រៀបចំអោយមានសណ្តាប់ធ្នាប់អនាម័យល្អ ចំណតរថយន្តនិងផ្សារដែលមានទីតាំងជាប់ផ្លូវជាតិក៏ត្រូវរៀបចំ ឡើងវិញអោយបានត្រឹមត្រូវធានាសុវត្ថិភាពធ្វើដំណើរ ។

-កំណត់អោយការដ្ឋានសំណង់នានារៀបចំធ្វើកន្លែងដាក់សំភារៈសាងសង់និងសំណល់សេសសល់អោយបានសមរម្យ ជៀសវាងការដាក់គ្រឿងសំណង់ និងសំណល់សេសសល់រាយប៉ាយប៉ះពាល់ចំណីផ្លូវ និងផ្លូវសាធារណៈ ។ បណ្តាការដ្ឋានសំណង់ទាំងអស់តាមដងផ្លូវវិថីធំៗ ត្រូវរៀបចំធ្វើរបាំងបិទបាំង របស់ខ្លួនដើម្បីថែរក្សាសណ្តាប់ធ្នាប់ របៀបរៀបរយ និងសោភ័ណភាពខេត្ត-ក្រុង ។

-ជំរុញម្ចាស់រោងចក្រ សហគ្រាស ក្រុមហ៊ុននានា រៀបចំធ្វើអាងស្តុកកាកសំណល់ ដើម្បីធ្វើការច្រោះសំអាតសារធាតុពុល មុនបញ្ចេញចោលទៅទីសាធារណៈ ឬនៅក្នុងលូប្រឡាយទឹកផ្សេងៗ ។

-រាល់ម៉ាស៊ីនភ្លើងត្រូវរៀបចំកែច្នៃបច្ចេកទេសដើម្បីកុំអោយផ្សែង និងសំឡេងបំពុលបរិយាកាសនិងប៉ះពាល់ដល់សន្តិសុខប្រជាពលករជុំវិញ ។

-អនុវត្តវិធានការរដ្ឋបាល ឬសេដ្ឋកិច្ចចំពោះអំពើវង្វេសបង្កភាពអាប់អួរដល់បរិដ្ឋាន ដោយសុំកិច្ចសហការពីអាជ្ញាធរខេត្ត-ក្រុង និងមន្ទីរដែលពាក់ព័ន្ធ ។ ទន្ទឹមនេះដែរ ត្រូវលើកសរសើរឬជូន រង្វាន់អ្នកមានស្នាដៃក្នុងការរួមវិភាគទានកែលំអសោភ័ណភាពខេត្ត-ក្រុង ឬការពារគុណភាពបរិដ្ឋាន ។

IV - ការបូកសរុបលទ្ធផល :

ធ្វើរក្រប់ក្រាំងបរិដ្ឋានខេត្ត-ក្រុង មានភារកិច្ចក្តាប់ខ្ចីមសារ និងលទ្ធផលការងារពលកម្មរបស់ ប្រជាពលរដ្ឋ មន្ត្រីរាជការខេត្ត-ក្រុង ក្នុងទិវាខាងលើព្រមទាំងលើកការជោគជ័យគណៈកម្មការប្រឡងប្រណាំង កែលំអសោភ័ណភាពខេត្ត-

ក្រុង និងអាជ្ញាធរខេត្ត-ក្រុង ដើម្បីបូកសរុបលទ្ធផលជាក់ស្តែង រាយការណ៍មកក្រសួងអោយបានមុនថ្ងៃទី ៣០-១១-៩៥ ដើម្បីក្រសួងធ្វើការបូកសរុបជូនសហប្រធានគណៈកម្មការកែលំអ សោភ័ណភាពខេត្ត-ក្រុង និងជូនគណៈរដ្ឋមន្ត្រី ។

ក្រសួងសង្ឃឹមថា បណ្តាក្រសួង រដ្ឋលេខាធិការដ្ឋាន អាជ្ញាធរខេត្ត-ក្រុង ប្រាកដជាយកអស់ កំលាំងស្មារតី និងកំលាំងកាយអនុវត្តតាមខ្លឹមសារ អនុក្រឹត្យលេខ ៤៧ អនក្រ.បក ចុះថ្ងៃទី ១២-៦-៩៥ របស់រាជរដ្ឋាភិបាល ក្នុងមនសិការស្នេហាជាតិលើកស្ទួយបរិដ្ឋានជាតិ ដែលជាកាតព្វកិច្ចរបស់យើងទាំង អស់គ្នារួមចំណែកអនុវត្តអោយបានជោគជ័យ សំណូមពរ និងគោលបំណងរបស់រាជរដ្ឋាភិបាល ។

អគ្គនាយក ខុទ្ទកាល័យ នាយកដ្ឋានចំណុះ មន្ទីរគ្រប់គ្រងបរិដ្ឋានខេត្ត-ក្រុង មានភារៈជំរុញ និងតាមដានការអនុវត្តសេចក្តីណែនាំនេះ ។

រដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

បណ្ឌិត ម៉ុក ម៉ារ៉េត

* * *

រាជធានីភ្នំពេញ,ថ្ងៃទី ០៥ ខែ កញ្ញា ឆ្នាំ ១៩៩៥

ប្រកាស

លេខ : ១៦០៤ បគ.បស្ត

ស្តីពីការទទួលស្គាល់ និង ប្រគល់ភារកិច្ច

ជូនមន្ត្រី រាជការ

រដ្ឋមន្ត្រីក្រសួងគ្រប់គ្រងបរិដ្ឋាន

- បានឃើញព្រះរាជក្រឹត្យរបស់ពេះករុណា ព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រនៃព្រះ រាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣

- បានឃើញព្រះរាជក្រឹត្យរបស់ព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រនៃព្រះ រាជាណាចក្រកម្ពុជា លេខ នស.រកត ១០-៩៤-៨៣ ចុះថ្ងៃទី ២៤ តុលា ១៩៩៤
- បានឃើញច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់គណៈរដ្ឋមន្ត្រី ដែលប្រកាសអោយ ប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- យោងប្រកាសលេខ : ៤០៦ បល.ប្រក ចុះថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ ១៩៩៥ របស់ក្រសួង ឧស្សាហកម្មរ៉ែ និងថាមពល
- យោងប្រកាសលេខ : ១៦៣ ប្រ.ស ចុះថ្ងៃទី ៤ ខែ មេសា ឆ្នាំ ១៩៩៥ របស់ក្រសួងមហាផ្ទៃ ។
- ផ្អែកតាមតំរូវការចាំបាច់របស់ក្រសួងគ្រប់គ្រងបរិដ្ឋាន ។

សំរេច

ប្រការ ១ : ទទួលស្គាល់ និងប្រគល់ភារកិច្ចជូនមន្ត្រីរាជការ អោយបំរើការងារនៅមន្ទីរគ្រប់គ្រងបរិដ្ឋាន រាជធានីភ្នំពេញ ដូចមានរាយនាមខាងក្រោម ÷

១-លោក **ជៀប ស៊ីនែ**
២-លោក **ឃួន គីមនី**
៣-លោក **ខូវ ឌុង**
៤-លោក **សេង ត្រី**
៥-លោក **ចក់ សារិន**
៦-លោក **យ៉ាន លឹម**
៧-លោក **សរ សុខ**
៨-លោក **ពុំ ស៊ឿ**
៩-លោក **អ៊ឹង គីមឈី**
១០-លោក **ស៊ូ ខៃ**

ប្រការ ២ : ប្រាក់បៀវត្ស និងរបបឧត្តមផ្សេងៗ របស់សាមីខ្លួន ក្រសួងគ្រប់គ្រងបរិដ្ឋានជាអ្នកគ្រប់គ្រង បន្ត នៅពេលមានវិញ្ញាបនប័ត្រផ្តាច់ប្រាក់ពីអង្គភាពដើម ។

ប្រការ ៣ : អគ្គនាយក ខុទ្ទកាល័យ អង្គភាពដែលពាក់ព័ន្ធ និងសាមីខ្លួនទទួលបន្ទុក អនុវត្តប្រកាសនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រដ្ឋមន្ត្រី
ហត្ថលេខានិងត្រា
បណ្ឌិត ម៉ុក ម៉ារ៉េត

១០ - ទីស្តីការក្រសួង ធម្មការ និង សាសនា

សេចក្តីសម្រេច

ភ្នំពេញ , ថ្ងៃទី ០៤ ខែ កញ្ញា ឆ្នាំ ១៩៩៥

លេខ : ១៧៧ /៩៥ កធស

ស្តីពីការអនុញ្ញាតអោយបង្កើតសមាគមព្រះពុទ្ធសាសនាអ៊ីក្វាន់តាវ

រដ្ឋលេខាធិការ ក្រសួងធម្មការ និងសាសនា

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រនៃព្រះ រាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរដ្ឋមន្ត្រី រដ្ឋលេខា ធិការ នៃរាជរដ្ឋាភិបាល កម្ពុជា
- បានឃើញពាក្យសុំរបស់តំណាងសមាគម អ៊ីក្វាន់តាវ ចុះថ្ងៃទី ០២ ខែ កញ្ញា ឆ្នាំ ១៩៩៥ ។

សម្រេច

ប្រការ ១ : អនុញ្ញាតជាគោលការណ៍អោយបើក « សមាគមព្រះពុទ្ធសាសនាអ៊ីក្វាន់តាវ » មួយកន្លែងដែល មានទីតាំងស្ថិតនៅផ្ទះលេខ ១៣ ផ្លូវព្រះមន្ទីរវង្ស សង្កាត់ បឹងត្របែកខ័ណ្ឌចំការមន រាជធានី ភ្នំពេញ ។

ប្រការ ២ : សមាគមព្រះពុទ្ធសាសនាអ៊ីក្វាន់តាវ ត្រូវបានអនុញ្ញាតអោយផ្សព្វផ្សាយនូវ លទ្ធិសាសនា ដែល មានលក្ខណៈជាសាសនាសុទ្ធសាធ ។

ប្រការ ៣ : សមាគមព្រះពុទ្ធសាសនាអ៊ីក្វាន់តាវ ត្រូវគោរពអោយបានម៉ឺងម៉ាត់តាមច្បាប់ នៃ ព្រះរាជាណាចក្រកម្ពុជា និងបទបញ្ញត្តិផ្សេងៗ របស់ក្រសួងធម្មការ និងសាសនា សន្យាជាដាច់ខាត មិនធ្វើ អោយប៉ះពាល់ដល់សិទ្ធិសេរីភាព ខាងជំនឿសាសនា និងសណ្តាប់ធ្នាប់សង្គម ។

ប្រការ ៤ : នាយកដ្ឋានសាសនា និងមន្ត្រីរាជការគ្រប់លំដាប់ថ្នាក់ ដែលពាក់ព័ន្ធត្រូវសហការ អនុវត្តសេចក្តីសំរេចនេះ អោយមានប្រសិទ្ធភាពខ្ពស់ ។

ប្រការ ៥ : សេចក្តីសំរេចនេះមានអនុភាពគតិយុត្ត ចាប់ពីថ្ងៃដែលបានចុះហត្ថលេខានេះតទៅ ។

ហត្ថលេខានិងត្រា

ហឿន វណ្ណារិត្ត

* * *

១១ - ទីស្តីការក្រសួង ប្រៃសណីយ៍ និង ទូរគមនាគមន៍

ប្រកាស

រាជធានីភ្នំពេញ,ថ្ងៃទី ០៨ ខែ កញ្ញា ឆ្នាំ ១៩៩៥

ប្រកាស

លេខ : ១១២ មទ.ប្រក

ស្តីពីការបង្កើតគណៈកម្មការកណ្តាល និងអនុគណៈកម្មការរៀបចំតាំងពិព័រណ៍បង្ហាញសមិទ្ធផលឆ្នាំ ១៩៩៣- ១៩៩៥

រដ្ឋលេខាធិការក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រនៃព្រះ រាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល កម្ពុជា
- បានឃើញច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើ ដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤

- បានឃើញសេចក្តីសំរេចលេខ : ៦១ សសរ ចុះថ្ងៃទី ៣១ ខែ សីហា ឆ្នាំ ១៩៩៥ របស់រាជរដ្ឋាភិបាល
- បានឃើញការងារចាំបាច់របស់ក្រសួង ។

សំរេច

ប្រការ ១ : បង្កើតគណៈកម្មការកណ្តាល និងអនុគណៈកម្មការសំរាប់រៀបចំពិពរ៌ណ៍ ស្តីពី សមិទ្ធផលលើ វិស័យប្រៃសណីយ៍និងទូរគមនាគមន៍ ក្នុងរយៈពេលពីរឆ្នាំ (០២ វិច្ឆិកា ១៩៩៣ - ០២ វិច្ឆិកា ១៩៩៥) ។

ប្រការ ២ : គណៈកម្មការកណ្តាល និងអនុគណៈកម្មការ មានសមាសភាពដូចតទៅ ÷

ក-គណៈកម្មការកណ្តាល :

១-ឯកឧត្តម **ឡូយ គឹមស៊ា**	ជាប្រធាន
២-លោក **ឡុយ ពុំ**	អនុប្រធាន
៣-លោក **ញ៉ាណា ស្រស់**	សមាជិក
៤-លោក **នេត ឡើង**	សមាជិក
៥-លោក **ឡុង ម៉ាន់ហាន**	សមាជិក
៦-លោក **ឡា ណារ៉ាត**	សមាជិក
៧-លោក **គុប សុខខួន**	សមាជិក
៨-លោក **ចាប សាមិទ្ធ**	លេខា

ខ-អនុគណៈកម្មការ :

១-លោក **ឡុយ ពុំ**	ប្រធាន
២-លោក **កែវ ឧត្តរិន**	អនុប្រធាន
៣-លោក **ឈុម សំអាន**	សមាជិក
៤-លោក **លី សំអាន**	សមាជិក
៥-លោក **ចា ស៊ីម**	សមាជិក
៦-លោក **ទៀង ម៉ិនឡើង**	សមាជិក
៧-លោក **មាស តារាវុធា**	សមាជិក

៨-លោក ឈី កាយឫទ្ធិ សមាជិក

៩-លោក សួន សុខ សមាជិក

១០-លោក សរ សារុន សមាជិក

១១-លោក ស កន សមាជិក

១២-តំណាងក្រុមហ៊ុនវិនិយោគទុនទាំងអស់ សមាជិក

១៣-លោក សុទ្ធ គឹមស៊ា លេខា

ប្រការ ៣ : គណៈកម្មការកណ្តាល និង អនុគណៈកម្មការមានភារកិច្ច ÷

- រៀបចំតាំងពិពរណ៍បង្ហាញសមិទ្ធផលឆ្នាំ ១៩៩៣- ១៩៩៥ របស់វិស័យ ប្រៃសណីយ៍និងទូរគម នាគមន៍ ។
- លើកគំរោងការចងក្រងឯកសារខ្លី និងផ្តល់រូបថតមានអត្ថាធិប្បាយខ្លីៗ ។
- សំរបសំរួលទំនាក់ទំនងការងារជាមួយបណ្តានាយកដ្ឋានពាក់ព័ន្ធ និងគណៈ កម្មការអន្តរក្រសួង ដើម្បីជំរុញការអនុវត្តគំរោងការនេះអោយបានប្រសិទ្ធភាព
- ធ្វើរបាយការណ៍បូកសរុប និងលើកគំរោងចំណាយដើម្បីលើកជាយោបល់ ជូនឯកឧត្តមរដ្ឋ លេខាធិការពិនិត្យសំរេចក្នុងករណីចាំបាច់ ។

ប្រការ ៤ : ខុទ្ទកាល័យ , អធិការដ្ឋាន , នាយកដ្ឋានផែនការគណនេយ្យ-ហិរញ្ញកិច្ច , គណៈកម្មការកណ្តាល និងអនុគណៈកម្មការត្រូវទទួលបន្ទុកអនុវត្តន៍ តាមខ្លឹមសារ នៃសេចក្តីសំរេចនេះចាប់ពីថ្ងៃចុះហត្ថ លេខាតទៅ ។

រដ្ឋលេខាធិការ

ហត្ថលេខានិងត្រា

សូ ឃុន

បោះពុម្ពនៅរោងពុម្ពទីស្តីការគណៈរដ្ឋមន្ត្រី
លើកទី ១ ចំនួន ២៨០០ ច្បាប់

តម្លៃ ១៩៥៦ រៀល